Theology on the Web.org.uk

Making Biblical Scholarship Accessible

This document was supplied for free educational purposes. Unless it is in the public domain, it may not be sold for profit or hosted on a webserver without the permission of the copyright holder.

If you find it of help to you and would like to support the ministry of Theology on the Web, please consider using the links below:

Buy me a coffee https://www.buymeacoffee.com/theology

PATREON https://patreon.com/theologyontheweb

PayPal https://paypal.me/robbradshaw

A table of contents for *Honeycomb* can be found here:

https://biblicalstudies.org.uk/articles_honeycomb.php




ព្រឹត្តិបត្រទេវសាស្ត្រទ្វេភាសា ខ្មែរ-អង់គ្លេស ផ្តល់នូវចំណេះដឹងផ្នែកព្រះគម្ពីរ
ដល់លោកអ្នក ប្រៀបដូចជាទឹកឃ្មុំផ្តល់កម្លាំងដល់អ្នកដំណើរដែលកំពុងខ្សោយល្វើយ ។

**A bilingual Khmer-English Theological Journal to give biblical knowledge to its readers as a honeycomb gives strength to exhausted travelers.**

---

ឆ្នាំទី ៣ លេខ ២ ខែ មេសា ឆ្នាំ ២០០២

Vol. 3, No. 2 April 2002

គម្រោងកម្មវិធីហ្វឹកហ្វឺន ធីម៉ូថេ បានបោះពុម្ពព្រឹត្តិបត្រ *សំណុំទឹកឃ្មុំ* នេះឡើង ។
© រក្សាសិទ្ធិដោយ គម្រោងកម្មវិធីហ្វឹកហ្វឺន ធីម៉ូថេ ២០០២
ទាក់ទងតាមការិយាល័យប្រៃសណីយ៍ ប្រអប់សំបុត្រលេខ ៤៧៩ ភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទលេខ (៨៥៥) ២៣ ២១៦ ០៥២ ទូរសារលេខ (៨៥៥) ២៣ ២១៦ ៤២០
សារអេឡិចត្រូនិច: Russell_Bowers@wvi.org
បណ្ណាធិការ Russell H. Bowers, Jr.
ផ្នែកប្រែសម្រួល: អ៊ួន សិលា
ពិនិត្យផ្ទៀងផ្ទាត់ភាសាខ្មែរ: ម៉ម បាណាបាស
ផ្នែកបច្ចេកទេស: ម៉ាក ច័ន្ទស៊ីថា
សំណោរអត្ថបទ និង ការទាក់ទងផ្សព្វផ្សាយ ត្រូវដាក់ជូនមកបណ្ណាធិការ
បោះពុម្ពនៅទីក្រុងភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

*Honeycomb* is published by Training of Timothys
© 2002 by Training of Timothys
Central Post Office, P.O. Box 479, Phnom Penh, Kingdom of Cambodia
Email, Russell_Bowers@wvi.org
Editor, Russell H. Bowers, Jr.
Translation, Uon Seila
Khmer proofreading, Barnabas Mam
Technical support, Mark Chann Sitha

Manuscripts and communications should be addressed to the editor.
Printed in Phnom Penh, Kingdom of Cambodia.

# From the Editor

Busy Christians have so many things to think about—and all are important! Budgets, plans, meetings with government officials, sermons, discipleship, church discipline. So we push lesser matters aside.

But sometimes in the crush to get things done we forget what truly is important.

It happened in Jesus' day. He met crowds who hung on his words, spies trying to trap him in his speech, lame and blind who cried for his healing touch. This is important stuff! So what should he do when mothers bring their children for him to hold?

The disciples confused bigness with importance, and shooed the doting parents and their squirmy kids away. But Jesus' idea of what is important often differed from his compatriots' view. "Let the little children come to me, and do not hinder them, for the kingdom of God belongs to such as these."

For many people, adults are important, money is important, power and prestige are important, sensual stimulation is important. Children are either nuisances . . . or expendable tools to help us gain some of these. Even church leaders and Christian parents can forget the priceless value of our little ones.

But the scriptures bring us back to reality. "Sons are a heritage from Yahweh, children a reward from him. Like arrows in the hands of a warrior are sons born in one's youth. Blessed is the man whose quiver is full of them." "I prayed for this child, and Yahweh has granted me what I asked of him." "[F]rom infancy you have known the holy Scriptures, which are able to make you wise for salvation." "Unto us a child is born."

This issue of *Honeycomb* is dedicated to our children. May its articles encourage us to see children the way God sees them, and to love, nurture, and defend them.

# ការជូនដំណឹងពីបណ្ណាធិការ

គ្រីស្ទបរិស័ទរវល់រកពេលទំនេរគ្មាន មានរឿងរ៉ាវជាច្រើនដែលត្រូវគិត ហើយរឿងទាំងអស់នោះទៀតសោតសុទ្ធតែសំខាន់ៗ! ការរៀបចំគម្រោងថវិកា ការរៀបចំផែន ការជួបប្រជុំជាមួយមន្ត្រីរដ្ឋាភិបាល ការរៀបចំសេចក្តីអធិប្បាយ ការបង្កើតសិស្ស និងការកែតម្រង់ដល់ក្រុមជំនុំជាដើម ។ ដូច្នេះយើងត្រូវរុញការណាដែលមិនសូវសំខាន់ទុកដោយឡែកសិន ។

ប៉ុន្តែជួនកាលដោយព្រោះតែមមាញឹកក្នុងការខំសម្រេចការងារជាច្រើននោះ យើងបែរទៅជាភ្លេចនូវការងារមួយដែលសំខាន់បំផុតនោះទៅវិញ ។

រឿងនេះគឺវាបានកើតឡើងនៅក្នុងសម័យព្រះយេស៊ូរួចទៅហើយ ។ ព្រះអង្គជួបជាមួយនឹងហ្វូងមនុស្សដែលរង់ចាំស្តាប់ព្រះបន្ទូលរបស់ព្រះអង្គ មានអ្នកកំពុងព្យាយាមឈ្លបចាប់កំហុសនៅពេលដែលព្រះអង្គមានព្រះបន្ទូល ឯអ្នកខ្វិន និងអ្នកខ្វាក់កំពុងតែព្យាយាមស្រែកដង្ហើយហៅសុំឲ្យព្រះអង្គប្រោសគេឲ្យជា ។ ការទាំងនេះសុទ្ធតែសំខាន់! ចុះតើត្រូវឲ្យព្រះអង្គធ្វើយ៉ាងណា នៅពេលដែលម្តាយៗនាំយកកូនក្មេងមកឲ្យព្រះអង្គលើកពរនោះ?

ពួកសិស្សរបស់ព្រះអង្គច្រឡំធំមែនទែនចំពោះការសំខាន់នោះ ហើយគេបានដេញឪពុកម្តាយ និងកូនរបស់គេចេញពីព្រះយេស៊ូ ។ ប៉ុន្តែព្រះរាជតំរិះរបស់ព្រះយេស៊ូចំពោះការដែលព្រះអង្គរាប់ថាជាសំខាន់នោះ តែងតែផ្ទុយពីគំនិតរបស់បណ្តារាស្ត្ររបស់ព្រះអង្គ ។ "ចូរឲ្យក្មេងៗចូលមកឯខ្ញុំចុះ កុំឲ្យឃាត់វាឡើយ ដ្បិតនគរស្ថានសួគ៌មានសុទ្ធតែមនុស្សដូចវារាល់គ្នា" ។

ចំពោះមនុស្សជាច្រើនគេរាប់មនុស្សពេញវ័យថាសំខាន់ លុយសំខាន់ អំណាច និងមុខមាត់នោះសំខាន់ ការមានអារម្មណ៍ល្អនៅក្នុងខ្លួន (ត្រេកត្រអាល) នោះគេគិតថាសំខាន់ ។ កុមារគឺអាចជាឧបករណ៍ដែលគេប្រើជាឈ្នាន់ ដើម្បីបំពេញនូវមហិច្ឆតាទាំងអស់នោះ ។ សូម្បីតែអ្នកដឹកនាំក្រុមជំនុំ និងឪពុកម្តាយដែលជឿព្រះហើយនោះ ក៏អាចភ្លេចនូវតម្លៃដែលរកអ្វីប្រៀបផ្ទឹមពុំបានរបស់កូនតូចៗរបស់យើងនោះដែរ ។

ប៉ុន្តែបទគម្ពីរបាននាំយើងឲ្យវិលត្រឡប់មករកធាតុពិតចំពោះការនោះឡើងវិញ ។ "កូនចៅជាមត៌កមកពីព្រះយេហូវ៉ា ជារង្វាន់ដែលមកពីព្រះអង្គ ។ ដូចជាផ្លែព្រួញនៅក្នុងដៃអ្នកចំបាំង គឺជាកូនដែលឯងបង្កើតកាលពីនៅក្មេង ។ មានពរហើយអ្នកណាដែលមានព្រួញពេញក្នុងបំពង់នោះ" ។ "ខ្ញុំបានទូលសុំកូននេះពីព្រះជាអម្ចាស់ ហើយព្រះអង្គក៏ប្រទានកូននេះមកឲ្យខ្ញុំ" ។ "តាំងពីក្មេងមកអ្នកចេះព្រះគម្ពីរបរិសុទ្ធ ដែលធ្វើឲ្យអ្នកមានប្រាជ្ញាសំរាប់ការសង្គ្រោះ" ។ "មានព្រះបុត្រតូចមួយនឹងប្រសូតមកសំរាប់យើង" ។

ព្រឹត្តិបត្រ សំណុំទឹកឃ្មុំ ចេញផ្សាយលេខនេះ គឺយើងសូមឧទ្ទិសយ៉ាងសំខាន់ចំពោះកុមារៗរបស់យើង ។ សូមឲ្យអត្ថបទទាំងនេះជួយជំរុញលើកទឹកចិត្តឲ្យយើងមើលឃើញកុមារៗដូចជាការដែលព្រះជាម្ចាស់ព្រះអង្គទតមើលមកពួកគេដែរ ហើយសូមឲ្យយើងស្រឡាញ់ថែបំប៉ន និងគាំពារគេឲ្យបានល្អផង ។

VOLUME 3 APRIL 2002 NUMBER 2

# Honeycomb


**"Such as these"—A Framework for Understanding our Children** 1
*Heather FORBES*

"ដូចជាកូនក្មេងទាំងនេះ" គម្រោងការសំរាប់ស្វែងយល់ អំពីកូនរបស់យើង ១០
*ហេធ័រ ហ្វបស៍*

កូនស្រីពិការពិត តែចិត្តមិនពិការឡើយ ២៥
*សួន នាង*

**A Determined Disabled Daughter** 34
*SOUN Neang*

**A Christian Response to Disability in Cambodia** 41
*Glenn MILES*

ការឆ្លើយតបរបស់គ្រីស្ទបរិស័ទចំពោះភាពពិការ នៅក្នុងប្រទេសកម្ពុជា ៥៥
*គ្លេន ម៉ៃល*

**An Unexpectedly Precious Gift** 75
*Susan CALDWELL*

អំណោយទានដ៏មានតម្លៃ ដែលមិនបានគិតទុកជាមុន ៨៤
*ស៊ូសាន ខដវែល*

**Responding to The Rape of Cambodian Children** 100
*Steve GOURLEY*

ការឆ្លើយតបចំពោះការចាប់រំលោភកុមារកម្ពុជា ១១២
*ស្ទីវ ហ្គ័រលី*

**Confronting Pornography: Choosing Life** 134
*Glenn MILES*

ការជ្រើសរើសយកជីវិត ជាកិច្ចប្រឈមមុខទៅនឹងរូបអាសអាភាស ១៣៩
*គ្លេន ម៉ៃល*


First listing of an article is the language in which the article was originally written.

HONEYCOMB 3/2 (April 2002): 1–9



# "Such as these"— A Framework for Understanding our Children

*Heather FORBES*

When I was pregnant with my first child, it seemed that everyone—family, friends, even complete strangers—felt compelled to give me child-rearing advice. Some of my most interesting conversations on this topic happened at the local supermarket, while picking through broccoli or beans alongside women of varying cultural backgrounds. These fellow shoppers gave me a world of advice about my upcoming baby, starting with predictions about its gender:

> "Your nose is wider now than a few weeks ago, so you're having a girl!"
> "Is the baby active? Then you must be having a boy!"
> "Your body is shaped like a pear, not an apple, so you must be having a girl."

Naturally, advice from others became more serious and more frequent as the baby's due date drew near. Relatives talked about baby care. Church members recommended books they had read. Our doctor registered us for childbirth education classes. Four years later, here in Cambodia, the advice continues. My neighbor across the road tells

me how to dress my daughters for the heat and mosquitoes. On a recent trip to China, we were often scolded for not putting enough layers of clothing on the kids.

Why do so many of us have something to say about parenting? The volume of advice so readily given hints at the profound nature of the job. It is at once the most sobering and most joyful of undertakings. When our first child was born, I lost a lot of sleep, but not only because of a wakeful, needy baby. In those weeks, even after we had put her down to sleep, my mind continued to churn with the overwhelming wonder of this new life, and the responsibilities ahead of us. God had given us the privilege of bringing a whole person, with an eternal soul, into this world, and her tiny presence in our home left me awestruck.

Thankfully, the God who gave us this awesome responsibility has also provided guidelines for the job. Proverbs 22:6 says, "Train a child in the way he should go, and when he is old he will not turn from it." God would not have us underestimate the impact we have on our children. This verse tells us that the way we parent our children is bound to have long-term effects on them, whether for their good or ill.

Dr. William Sears, one of America's most renowned pediatricians and an outspoken Christian, says that the training of a child begins from the moment of her birth and involves every interaction we have with her. He refers to this task of training a child as the process of "discipline." Discipline, he says, is a process of "imparting God's Word to such a degree that it becomes part of each child's inner self, his inner controls, his base of operations ... in short ... to instill a sense of direction."[1]

If, then, we are always in the process of instilling a sense of direction in our children, whether consciously or not, how do we make sure we are guiding them in "the way [they] should go"? Two interpretations of Proverbs 22:6 have been helpful in my efforts to discipline my own children. First, it can be read as a call to train our children to follow God's commandments. A second way to understand the phrase "in the way she should go" is as a reference to God's *specific*,

---

[1]William Sears, *Christian Parenting & Child Care* (Nashville: Broadman & Holman, 1997), 328.

*unique* plan for each child. In other words, nurturing our children according to their own "bent," or the nature God has given them. I believe both interpretations are helpful: that as we teach our children to walk in God's ways, we should do so with recognition of their God-given uniqueness. However, what are some of the principles that will enable us to succeed at this awesome challenge?

## Becoming a Student of Your Child

Instilling a sense of godly direction in a child begins with getting to know him or her and establishing a secure relationship built on trust. Discipline, Dr. Sears says, is something done *with*—not *to*—a child. Early in our marriage, my husband and I heard a piece of practical marriage advice that has proven to be a gold mine for promoting understanding, renewing loving feelings and enabling communication between the two of us. That statement was: study your spouse. Likewise, studying our children—finding out what really makes them "tick"—will lay a foundation of understanding that keeps our communication lines open, even as they grow and change. This will enable us to establish a climate in which loving, effective discipline can thrive.

## A Child is a Whole Person

Our study of our children must begin with what God says about them. A foundational principle in understanding our children is that every child is a person created in God's image.

> So God created humankind in his own image,
> in the image of God he created him;
> male and female he created them.[2]

Like the first humans and all that have come since, children are created in and for relationships with their creator, with other humans, and with the world around them. The highest commandments, identified by Jesus, are about those relationships.

---

[2]Gen 1:27.

"The most important [commandment]," answered Jesus, "is this: 'Hear, O Israel, the Lord our God, the Lord is one. Love the Lord your God with all your heart and with all your soul and with all your mind and with all your strength.' The second is this: 'Love your neighbor as yourself.' There is no commandment greater than these."[3]

A child, like all humans, is a whole person—a physical, mental, emotional, social and moral being. We can see from the above verses that God created children, as whole human beings, to live in whole relationships with God and others, involving every aspect of their personhood.

Parents of very young children might ask how we can possibly relate on all these levels to infants who seem to have constant physical needs but no words to express thoughts. Once again, the Bible is encouraging in this endeavor. To Judah's prophet Jeremiah, God confided: "Before I formed you in the womb I knew you."[4] Israel's King David understood that:

My frame was not hidden from you,
  when I was being made in the secret place.
When I was woven together in the depths of the earth,
  your eyes saw my unformed body.
All the days ordained for me
  were written in your book
  before one of them came to be.[5]

Pastor Gary Chapman and physician Ross Campbell encourage parents that an infant is capable of receiving care on more than just the physical level. They say that a

great deal of research indicates that the emotional foundation of life is laid in the first eighteen months of life, particularly in the mother/child relationship. The "food" for future emotional health is physical touch, kind words, and tender care.[6]

---

[3]Mark 12:30–31.

[4]Jer 1:5.

[5]Ps 139:15–16.

[6]Gary Chapman and Ross Campbell, *The Five Love Languages of Children* (Chicago: Northfield, 1997), 24.

Such nurture will enable the child to have healthy trusting relationships with God and with others as he or she grows.

Linguists tell us that a young child's mind is processing verbal input even when we don't see it happening—that a child receives and understands much more than he says. Because of this, Dr. Sears says your child will begin to have a concept of God before being able to articulate it. "Your child will understand better the concept of God if she has been saturated with hearing about God from birth. By the time she is two years old, she hears the words God and Jesus spoke in association with love and protection. By the time she is three years old, she feels God's presence."[7]

Seeing my own daughters' young responses to Christ has convinced me of this. Dylan, now four, has been listening to Bible stories since before she was one year old, and she now knows them backwards and forwards. Moreover, her sensitive spirit has internalized their truth and she is cultivating a real relationship with God. At times, we have seen her pause in the middle of what she is doing, and when we ask, she says that she is "listening to God." Two-year-old Zoe often initiates prayer at our dinner table and before bedtime. One night last year she woke up crying for our night guard, and we prayed for him. The next day we found out he had been injured in a car accident that same night. Seeing this type of spiritual sensitivity in our young children should encourage us to involve God-talk at the heart of our family lives. Pray, tell stories, and sing together, with the confidence that God's spirit is moving in your children. Or, in the words of Deuteronomy 6:6–9,

> These commandments that I give you today are to be upon your hearts. Impress them on your children. Talk about them when you sit at home and when you walk along the road, when you lie down and when you get up. Tie them as symbols on your hands and bind them on your foreheads. Write them on the doorframes of your houses and on your gates.

---

[7]Sears, *Christian Parenting*, 332.

## A Child is a Unique Person

While children are whole human beings and should be treated as such, each child is also unique. It is easy to interpret a child's perspective as less virtuous or important than an adult's; in a world where adults hold the power and authority, a child's opinion or needs are easily forgotten or discounted. On the other hand, God has given children special position in his kingdom, and throughout the gospels Jesus affirmed the value of the "least of these." In the gospel of Mark, we see Jesus contradicting the disciples' demeaning assumptions about children who came to see him. "Let the little children come to me," he says, "for the kingdom of God belongs to such as these."[8] In the story of the miraculous feeding of the crowd, it is a child's gift, a small lunch of bread and fish, that Christ used to bless thousands of adults.[9] The radical choice of God to be incarnated among us as an infant first, rather than appearing as an adult, speaks volumes about the value he ascribes to the nature of a child.

People who have good rapport with children often interact with them at the children's own eye level. Literally getting down on a child's level during times of play, comfort, and correction helps the adult see from the child's perspective and communicates understanding to the child. When Christian adults make the effort to get on the level of the children in our communities and incorporate some of their perspective into our community life and worship, we become more like the kingdom of God. Pastor Jim Brenneman of Pasadena Mennonite Church comments: "The church can only be a better place if, every now and again, we sit at our children's feet to listen to what they have to teach us."[10]

Children are unique not only as a group, but also as individuals. Psalm 139 is a beautiful testament to the intimate craftsmanship of a creator who "knit [the child] together in [his] mother's womb" and who declares each child "fearfully and wonderfully made." Our discipline should recognize the uniqueness of each child. What my

---

[8]Mark 10:14.

[9]John 6:9.

[10]James E. Brenneman, Sermon 346, 27 February 2000.

husband and I learned about parenting through our sensitive, creative older daughter has not always been helpful with her spunky, extroverted little sister.

An exciting framework for conducting "research" on our children is to discover the unique ways they receive and give love. This is an idea promoted in several Christian child-raising books. One set of these "love languages"[11] includes physical touch, words of affirmation, quality time, gifts, and acts of service. Each culture might have its own categories of expressing and receiving love, or at least different variations within these categories. However, for all parents, it is good to ask ourselves: Do I know what really communicates love to my child? Have I noticed how my child most consistently expresses love to others? Training up a child in the way he should go can best be done when we have made the effort to know and affirm our children, in their unique gifts and personalities, just as God knows us intimately ,and knows best how to train us. Only then can we help them develop their gifts and communicate our love most clearly to them.

Learning our children's specific inner workings will help us understand reasons behind common areas of conflict with them. For example, I recently came to understand that a major source of tension between my daughter and me relates to the different speeds at which we operate. I am fast-paced and decisive; she is thoughtful, needing more time between transitions. Now that I understand this, I can better distinguish between what is a moral issue and what is just a difference in personality. If it is a personality conflict, depending on the situation, I can try to accommodate Dylan, since she is the one with less understanding, and by doing so, model humility and express love to her. Or, if it is not possible to accommodate her, I can try to teach her to adjust according to the situation, but do so gently, understanding her need for transition time.

---

[11]Chapman and Campbell, *Five Love Languages*, 7.

## A Child is a Person in Need of Direction

In order to know our children as God knows them, we must recognize that just as they are designed by God as whole and unique people with potential for relationship with God and humans, so also they are also fallen people who, like the rest of us, need redemption. "Folly is bound up in the heart of a child," says Proverbs 22:15. Who of us with a two- or three-year-old doesn't know this? Sometimes the folly I see demonstrated in my kids is only an area of poor judgment, like jumping up and down while riding a cyclo in traffic, or running into the street during play. But other times the issue is a moral one. Discipline, or guidance, in times of correction is one of the most challenging aspects of our parenting role. But it is essential in order to guide the child into her God-given potential and into the blessing of walking with God.

To write about the specifics of correction is not my intention in this article. However, as in all aspects of discipline, keeping open communication lines through a continuing study of your child is essential. The sustained effort we put into knowing our children will assist in this aspect of discipline as well. For the kind of communication that springs from a relationship built on trust will help us to:

- approach correction within the context of the goal of all discipline: to impart understanding and build godly character in the child.[12]
- present our children with clear, consistent choices and consequences in a way they can comprehend.
- create structure and conditions in our homes that encourage desirable behavior.

This will help us to maintain the right attitude in our correction, so that we do not act out of anger, but rather with the self-control that mirrors God's own correction of his children.

---

[12]See Heb 12:10–11.

## The Power of a Parent's Influence

We have seen that God has a lot to say about who a child is: made in the image of God; a whole person with all the traits of personhood; unique in childlike nature, and created one-of-a-kind; capable of relationship but needing redemption to live in right relationship with God and neighbor. With all of these basics in place, Sears invites us to take up the challenge of studying our children, as a gardener knows the plants in his garden. This means to learn the right climate for best raising our children, and to be aware of the kinds of weeds that our children are especially susceptible to. Approaching discipline in this way, our guidance will be neither overly permissive nor abusive, because we will be viewing them with the wise and grace-filled eyes through which God sees us, and guiding them in his wisdom.

សំណុំនិកាយ ៣/២ (មេសា ២០០២)៖ ១០-២៤



# “ដូចជាកូនក្មេងទាំងអស់នេះ” គម្រោងការសំរាប់ស្វែងយល់អំពីកូនរបស់យើង

*អ្នកស្រី ហេឌរ ហូបស៍*

នៅពេលដែលខ្ញុំមានផ្ទៃពោះកូនដំបូងរបស់ខ្ញុំ គឺវាហាក់បីដូចជាមនុស្សគ្រប់គ្នាទាំងអស់ មិនថា ក្រុមគ្រួសារ មិត្តភក្តិ សូម្បីមនុស្សមិនដែលស្គាល់គ្នាសោះ ក៏ខំមកជួយផ្តល់ដំបូន្មានដល់ខ្ញុំស្តីពីការបីបាច់ថែទាំកូនដែរ ។ ការសន្ទនាដ៏គួរឲ្យចាប់អារម្មណ៍របស់ខ្ញុំចំពោះរឿងនេះ គឺនៅក្នុងផ្សារទិញឥវ៉ាន់ នៅពេលដែលខ្ញុំកំពុងរកមើលទិញខាត់ណា ឬទិញសណ្តែកក្នុងចំណោមស្ត្រីជាច្រើនដែលមានសាវតានៃទំនៀមទម្លាប់ផ្សេងៗពីគ្នា ។ អ្នកដែលបានដើរទិញឥវ៉ាន់នៅផ្សារជាមួយគ្នា បានឲ្យដំបូន្មានយ៉ាងច្រើនធំធេងណាស់ស្តីពីកូនរបស់ខ្ញុំដែលបំរុងនឹងកើតមក ដោយអ្នកខ្លះចាប់ផ្តើមទាយពីភេទរបស់កូននោះដោយនិយាយថា៖

> "ច្រមុះរបស់អ្នកទូលាយជាងប៉ុន្មានអាទិត្យមុន ដូច្នេះអ្នកប្រាកដជាបានកូនស្រីហើយ!"
> "តើកូនបំរះខ្លាំងទេ? អ៊ីចឹងប្រហែលជាបានកូនប្រុសហើយ!"
> "ពោះរបស់អ្នកនៅពេលមានទម្ងន់អ៊ីចឹងទៅរាងដូចជាផ្លែសារី មិនដូចជាផ្លែប៉ោមទេ ដូច្នេះអ្នកប្រាកដជាបានកូនស្រីហើយ ។"

តាមធម្មតា ដំបូន្មានពីអ្នកដទៃកាន់តែប្រាកដប្រជាឡើង និងកាន់តែញឹកញាប់ឡើងៗ នៅពេលដែលថ្ងៃប្រសូតកាន់តែជិតមកដល់ ។ ញាតិសន្តាននាំគ្នានិយាយពីការថែទាំដល់ទារក ។ សមាជិកក្រុមជំនុំណែនាំឲ្យអានសៀវភៅដែលគេធ្លាប់បានអាន ។ វេជ្ជបណ្ឌិតរបស់យើងបានចុះឈ្មោះឲ្យយើងចូលរៀនពីរបៀបថែទាំកូន ។ មកដល់ប្រទេសខ្មែរបួនឆ្នាំក្រោយមក ដំបូន្មាននោះនៅតែបន្តទៀត ។ អ្នកជិតខាងរបស់ខ្ញុំដែលរស់នៅទល់នឹងផ្ទះរបស់ខ្ញុំបានប្រាប់ខ្ញុំពីរបៀបដែលខ្ញុំត្រូវស្លៀកពាក់ឲ្យកូនស្រីរបស់ខ្ញុំ ដ្បិតធាតុអាកាសក្តៅ និងមានមូសច្រើន ។ នៅពេលថ្មីៗនេះខ្ញុំបានទៅលេងនៅប្រទេសចិន យើងតែងតែទទួលនូវការស្តីបន្ទោសដោយមិនបានពាក់អាវឲ្យបានច្រើនជាន់ឲ្យកូនៗរបស់យើង ។

ហេតុអ្វី បានជាយើងភាគច្រើនតែងតែមានពាក្យនិយាយពីការបីបាច់ថែទាំកូនដូច្នេះ? ទំហំដ៏ធំធេងនៃដំបូន្មាននេះប្រុងប្រៀបជាស្រេច ដើម្បីបង្ហើបប្រាប់ពីលក្ខណៈស៊ីជម្រៅនៃការងារនោះ ។ ដំបូន្មានទាំងនោះភាគច្រើនយើងទទួលយកភ្លាមដោយអំណរ និងយកជាការប្រាកដប្រជាភ្លាមតែម្តង ។ នៅពេលកូនច្បងរបស់យើងកើត ខ្ញុំដេកមិនលក់សោះ ប៉ុន្តែមិនមែនដោយសារកូនយំទារបៅ ឬត្រូវការផ្លាស់កន្ទបប៉ុណ្ណោះទេ ។ នៅក្នុងពេលប៉ុន្មានអាទិត្យនោះ សូម្បីតែនៅពេលដែលខ្ញុំបានដាក់វាឲ្យដេកហើយក្តី ក៏អារម្មណ៍របស់ខ្ញុំកំពុងជ្រួលច្របល់ឆ្ងល់ចំពោះជីវិតថ្មីរបស់កូនតូចនេះ និងការទទួលខុសត្រូវទាំងឡាយរបស់យើងចំពោះកូននេះនៅថ្ងៃខាងមុខ ។ ព្រះជាម្ចាស់បានផ្តល់ឲ្យយើងនូវឯកសិទ្ធិនៃការនាំយកនូវមនុស្សមួយរូប ដែលមានព្រលឹងអស់កល្បជានិច្ចចូលមកក្នុងលោកយើងនេះ ហើយព្រមទាំងវត្តមានដ៏នៅតូចរបស់គេនៅក្នុងផ្ទះរបស់យើង យើងខ្ញុំមានការកោតខ្លាចចំពោះព្រះជាខ្លាំង ។

អរព្រះគុណចំពោះព្រះជាម្ចាស់ ដែលព្រះអង្គបានប្រគល់ការទទួលខុសត្រូវដែលប្រកបដោយការកោតខ្លាចនេះមកយើង ព្រមទាំង

ផ្ដល់ឲ្យយើងនូវគោលការណ៍ណែនាំក្នុងធ្វើការងារនេះ ។ សុភាសិត ២២:៦ បានចែងថា៖ "ចូរបង្ហាត់កូនក្មេងឲ្យប្រព្រឹត្តតាមផ្លូវដែលគួរប្រព្រឹត្ត នោះវានឹងមិនលះបង់ពីផ្លូវនោះដរាបដល់ចាស់" ។ ព្រះជាម្ចាស់មិនបានឲ្យយើងព្រងើយកន្ដើយចំពោះការអប់រំកូនរបស់យើងនោះឡើយ ។ ខគម្ពីរនេះប្រាប់យើងពីរបៀបដែលយើងត្រូវបីបាច់ថែរក្សាកូន គឺវាមានឥទ្ធិពលយូរអង្វែងចំពោះជីវិតរស់នៅរបស់កូនយើង មិនថាកូននោះជាកូនមានសុខភាពល្អ ឬកូននោះឈឺអ្វីនោះឡើយ ។

វេជ្ជបណ្ឌិត *វីល្លាម ស៊ា* (William Sears) ជាអ្នកល្បីល្បាញម្នាក់ផ្នែកជម្ងឺកុមារនៅប្រទេសអាមេរិក ហើយក៏ជាគ្រីស្ទបរិស័ទដែលមានវេហារនិយាយថា ការស្ដីប្រដៅដល់កូនចាប់ផ្ដើមឡើងតាំងពីកូននោះកើតឡើងភ្លាមម៉្លេះ គឺវាទាក់ទងទៅនឹងគ្រប់ផ្នែកនៃការដែលយើងធ្វើអ្វីៗជាមួយកូននោះ ។ គាត់បាននិយាយយោងទៅដល់ការងារហ្វឹកហ្វឺនដល់កូន គឺជាដំណើរការ "ប្រដៅតម្រង់" ។ គាត់និយាយថា ការប្រដៅតម្រង់នោះ គឺជា "ការបញ្ចូលព្រះបន្ទូលរបស់ព្រះជាម្ចាស់ដល់កិរិតមួយដែលអាចក្លាយទៅជាផ្នែកមួយរបស់កូន គឺជាការគ្រប់គ្រងផ្នែកខាងក្នុងរបស់ក្មេងផ្នែកលើកិច្ចប្រតិបត្តិការនានា និយាយឲ្យខ្លីទៅគឺចាក់ឫសនៃគំនិតដែលមានទិសដៅនៅក្នុងគំនិតរបស់គេ ។"[១]

អ៊ីចឹងបើសិនយើងស្ថិតនៅក្នុងដំណើរការនៃការចាក់ឫសនៅក្នុងគំនិតរបស់កូនយើងឲ្យគេចេះមានគំនិតដែលប្រកបទៅដោយទិសដៅនោះ មិនថាឡើយយើងធ្វើការទាំងដឹងខ្លួន ឬមិនដឹងខ្លួននោះឡើយ តើយើងដឹងច្បាស់ដោយរបៀបណាបាន ថាយើងកំពុងដឹកនាំកូនរបស់យើង "ដើរក្នុងផ្លូវមួយដែលគេគួរតែដើរនោះ"? មានការបកស្រាយពីរយ៉ាងនៅត្រង់បទគម្ពីរ

---

[1] William Sears, *Christian Parenting & Child Care* (Nashville: Broadman & Holman, 1997), 328.

សុភាសិត ២២:៦ ដែលមានប្រយោជន៍មែនទែនដល់ការខំប្រឹងប្រែងរបស់ខ្ញុំក្នុងការស្ដីប្រដៅកូនរបស់ខ្ញុំផ្ទាល់ ។ ទីមួយ បទគម្ពីរនេះគ្រាន់តែអានទៅដូចជាការត្រាស់ហៅមួយបែបពីព្រះជាម្ចាស់ ដើម្បីហ្វឹកហ្វឺនកូនរបស់យើងឲ្យចេះដើរតាមព្រះរាជបញ្ញារបស់ព្រះជាម្ចាស់ ។ របៀបទីពីរក្នុងការយល់ពីឃ្លាដែលបានចែងថា "ផ្លូវដែលគួរដើរ" នោះគឺទាក់ទងទៅនឹងផែនការដ៏ជាក់លាក់របស់ព្រះជាម្ចាស់យ៉ាងពិសេសគ្មានពីរសំរាប់កុមារម្នាក់ៗ ។ គឺមានន័យថា ការមើលថែទាំកូនរបស់យើងស្របតាម "ទំនោរ" របស់វាផ្ទាល់ ឬតាមលក្ខណៈរបស់ព្រះជាម្ចាស់ដែលព្រះអង្គបានផ្ដល់ឲ្យគេ ។ ខ្ញុំជឿថាការបកស្រាយទាំងពីរនេះមានប្រយោជន៍គឺ៖ មានន័យថានៅពេលដែលយើងបង្រៀនកូនរបស់យើងឲ្យដើរតាមផ្លូវរបស់ព្រះជាម្ចាស់ នោះយើងត្រូវទទួលស្គាល់ពីលក្ខណៈពិសេសដែលព្រះជាម្ចាស់ប្រទានឲ្យគេ ។ ទោះបីជាយ៉ាងណាក៏ដោយ តើមានគោលការណ៍អ្វីខ្លះទៀត ដែលអាចជួយឲ្យយើងទទួលជោគជ័យក្នុងការទទួលខុសត្រូវដោយគោរពកោតខ្លាចនេះបាន?

## ការក្លាយទៅជាសិស្សរបស់កូនខ្លួនឯង

ការចាក់ឫសក្នុងគំនិតដែលមានទិសដៅប្រកបដោយការកោតខ្លាចព្រះ ចំពោះកុមារចាប់ផ្ដើមឡើងដោយការស្គាល់ចរិតលក្ខណៈរបស់កូននោះ និងការបង្កើតឲ្យមានភាពដែលអាចទុកចិត្តបានចំពោះទំនាក់ទំនង ។ វេជ្ជបណ្ឌិត *ស៊ា* មានប្រសាសន៍ថា ការប្រដៅតម្រង់កូនចៅ គឺជាការងារដែលត្រូវធ្វើជាមួយកូន មិនមែនជាការធ្វើសំរាប់កូននោះទេ ។ មុនពេលយើងរៀបការប្ដីរបស់ខ្ញុំ និងខ្ញុំបានពុះពារបួន្មានសំខាន់ៗខ្លះស្ដីពីអាពាហ៍ពិពាហ៍ដែលបង្ហាញឲ្យឃើញថានោះជាអណ្ដូងរ៉ែមាស ដែលយើងត្រូវខំជីកកាយរកការយល់ដឹង និងការកែលំអនូវអារម្មណ៍ស្រឡាញ់ឲ្យថ្មីឡើងរហូត និងជំរុញឲ្យមានការប្រាស្រ័យទាក់ទងរវាងយើងទាំងពីរកាន់តែប្រសើរឡើង ។ ការថ្លែងប្រាប់ពី

ដំបូន្មាននោះគឺ៖ ចូររៀនឲ្យស្គាល់ពីដៃគូជីវិតរបស់អ្នក ។ ដូចគ្នានេះដែរ ចូរយើងរៀនឲ្យស្គាល់ពីនិស្ស័យលក្ខណៈរបស់កូនយើង គឺមានន័យថា ការស្វែងរកនូវអ្វីដែលពិតជាធ្វើឲ្យកូននោះ "ជាមនុស្សល្អ" ការនេះនឹងជួយចាក់គ្រឹះដល់ការយល់ដឹងដែលអាចជួយឲ្យយើងមានឱកាសប្រាស្រ័យទាក់ទងបានរហូត ទោះបីកូននោះគេធំឡើង និងមានការផ្លាស់ប្តូរយ៉ាងណាក៏ដោយ ។ ចំពោះការយល់ដឹងនេះនឹងជួយឲ្យយើងអាចបង្កើតឡើងនូវសេចក្តីស្រឡាញ់ដល់កំពូលដែលមានប្រសិទ្ធិភាពដល់ការប្រដៅតម្រង់ដ៏ប្រកបដោយជោគជ័យ ។

## កុមារគឺជាបុគ្គលពេញលក្ខណៈ

ការសិក្សាស្រាវជ្រាវឲ្យស្គាល់កូនរបស់យើង ត្រូវតែចាប់ផ្តើមឡើងជាមួយនឹងអ្វីៗដែលព្រះជាម្ចាស់មានព្រះបន្ទូលស្តីអំពីកូននោះ ។ គោលការណ៍គ្រឹះដ៏សំខាន់ក្នុងការស្វែងយល់ពីកូនរបស់យើងនោះគឺ កុមារទាំងឡាយជាមនុស្សដែលព្រះជាម្ចាស់បង្កើតមកជារូបឆ្លុះរបស់ព្រះអង្គ ។

> ទ្រង់ក៏បង្កើតមនុស្សឲ្យដូចរូបអង្គទ្រង់ គឺបានបង្កើតគេឲ្យចំនឹងរូបអង្គទ្រង់នោះឯង ក៏បង្កើតគេឡើងជាប្រុសជាស្រី ។[២]

ដូចជាមនុស្ស និងរបស់ទាំងអស់ដែលព្រះជាម្ចាស់បង្កើតមក កុមារទាំងឡាយក៏ព្រះអង្គបង្កើតមកសំរាប់ឲ្យគេប្រាស្រ័យទាក់ទងជាមួយនឹងព្រះអាទិកររបស់គេ ព្រមទាំងប្រាស្រ័យទាក់ទងជាមួយមនុស្សដទៃទៀត និងពិភពលោកដែលនៅជុំវិញពួកគេដែរ ។ បញ្ញត្តិដ៏សំខាន់ជាងគេបំផុតដែលព្រះយេស៊ូបានបង្ហាញឲ្យឃើញនោះ គឺស្តីអំពីទំនាក់ទំនងទាំងនោះឯង ។

---

[២] *លោកុ. ១:២៧*

ព្រះយេស៊ូមានបន្ទូលឆ្លើយថា ឯបញ្ញត្តិដែលសំខាន់ជាងគេនោះ គឺថា៖ "ចូរស្តាប់ចុះ អ៊ីស្រាអែលអើយ ព្រះអម្ចាស់ជាព្រះនៃយើងខ្ញុំ ទ្រង់ជាព្រះអម្ចាស់តែមួយព្រះអង្គទ្រង់ ហើយឯងត្រូវស្រឡាញ់ដល់ព្រះអម្ចាស់ជាព្រះនៃឯង ឲ្យអស់អំពីចិត្ត អស់អំពីព្រលឹង អស់អំពីគំនិត ហើយអស់អំពីកម្លាំងនៃឯង" នោះហើយជាបញ្ញត្តិទីមួយ ឯបញ្ញត្តិទីពីរក៏បែបដូចគ្នាគឺថា "ត្រូវឲ្យស្រឡាញ់អ្នកជិតខាងដូចខ្លួនឯង គ្មានបញ្ញត្តិណាទៀតធំជាងបទទាំងពីរនេះទេ" ។[៣]

កុមារមានលក្ខណៈជាមនុស្សពេញលេញដូចជាមនុស្សទាំងអស់ដែរ គឺគេមានរូបកាយ ចិត្ត សតិអារម្មណ៍ ការទាក់ទងក្នុងសង្គម និងផ្នែកសីលធម៌ ។ យើងអាចមើលឃើញនៅក្នុងខគម្ពីរខាងលើនោះដឹងរួចហើយថា កុមារទាំងឡាយព្រះជាម្ចាស់ជាអ្នកបង្កើតគេមកជាមនុស្សគ្រប់លក្ខណៈ ដើម្បីឲ្យគេរស់នៅក្នុងទំនាក់ទំនងគ្រប់លក្ខណៈជាមួយព្រះជាម្ចាស់ និងជាមួយអ្នកដទៃ ដែលទាក់ទងគ្រប់វិស័យនៃលក្ខណៈជាមនុស្សរបស់គេទាំងស្រុង ។

ឪពុកម្តាយដែលមានកូននៅតូចៗ ប្រហែលជាអាចសួរថា ធ្វើម៉េចអាចឲ្យយើងទាក់ទងទៅគ្រប់ផ្នែករបស់កូនតូចៗទាំងនោះបាន ដែលហាក់បីដូចជាគេត្រូវការផ្នែករូបកាយនោះរហូត តែគ្មានពាក្យសំដីណាមកបញ្ជាក់ប្រាប់ពីគំនិតរបស់គេឡើយ ។ ចំពោះព្យាការីរបស់ជនជាតិយូដា គឺលោកយេរេមា ព្រះជាម្ចាស់បញ្ជាក់យ៉ាងច្បាស់ថា៖ "មុនដែលអញបានជប់បង្កើតឯងនៅក្នុងពោះម្តាយ នោះអញស្គាល់ឯងហើយ..."[៤] ស្តេចអ៊ីស្រាអែលបានយល់យ៉ាងច្បាស់ថា៖

---

[៣] *ម៉ាកុស ១២:២៩-៣១*

[៤] *យេរេមា ១:៥*

កាលទូលបង្គំកើតមាននៅទីកំបាំង ហើយបានសូនធ្វើបែបចម្លែកៗ នៅទីទាបនៃផែនដី នោះគ្រោងកាយរបស់ទូលបង្គំមិនកំបាំងនឹងទ្រង់ទេ ព្រះនេត្រទ្រង់បានឃើញធាតុនៃទូលបង្គំក្នុងកាលដែលមិនទាន់មានរូបរាងនៅឡើយ ទាំងអស់បានកត់ទុកក្នុងបញ្ជីរបស់ទ្រង់...[៥] ។

លោកគ្រូគង្វាល *ហ្គារី ឆែបមិន* និងលោកវេជ្ជបណ្ឌិត*រ៉ូស ខាំបែល* បានលើកទឹកចិត្តដល់ឪពុកម្តាយថា កូនតូចៗគេមានសមត្ថភាពនឹងទទួលការថែទាំពីឪពុកម្តាយលើសពីការិតផ្នែករូបកាយទៅទៀត ។ លោកទាំងពីរបាននិយាយថា យោងតាមការស្រាវជ្រាវដ៏ធំមួយបានបង្ហាញថា គ្រឹះសំខាន់នៃអារម្មណ៍របស់ក្មេងក្នុងអំឡុងដែលគេមានអាយុ១៨ខែដំបូង ជាពិសេសនៅក្នុងទំនាក់ទំនងរវាងម្តាយនឹងកូន ។ "ចំណីអាហារ" ដ៏ល្អសំរាប់សុខភាពផ្នែកអារម្មណ៍ គឺកើតឡើងដោយសារបីបមថ្នមថៃ ការប្រើពាក្យពិរោះ និងការថ្នាក់ថ្នមយ៉ាងស្រទន់ពីឪពុកម្តាយ ។[៦]

ការបីបាច់ថ្នាក់ថ្នមបែបនោះ អាចជួយឲ្យកុមារមានទំនុកចិត្តក្នុងទំនាក់ទំនងជាមួយព្រះជាម្ចាស់ និងជាមួយអ្នកដទៃនៅពេលដែលកូននោះធំឡើង ។

លោក *លីងហ្គិស* ប្រាប់យើងថា គំនិតរបស់កុមារទទួលបានដោយសារការនិយាយ ទោះបីជាគេមិនបានឃើញការនោះកើតឡើងនៅចំពោះមុខគេក៏ដោយ គឺមានន័យថាកុមារនោះគេទទួលបាន និងយល់បានច្រើនជាងអ្វីដែលអាចនិយាយចេញមកដោយខ្លួនគេបាន ។ ដោយសារតែហេតុនេះ

---

[៥] *ទំនុក.១៣៩:១៥-១៦*

[៦] Gary Chapman and Ross Campbell, The Five Love Languages of Children (Chicago: Northfield, 1997), 24.

ហើយ វេជ្ជបណ្ឌិត *ស៊ា* និយាយថា កូនរបស់អ្នកនឹងចាប់ផ្ដើមមានគំនិតយល់ដឹងពីព្រះជាម្ចាស់ មុនពេលដែលគេអាចសំដែងចេញឲ្យឃើញពីគំនិតរបស់គេពីការនោះបាន ។ "កូនរបស់អ្នកនឹងអាចយល់បានប្រសើរឡើងចំពោះគំនិតដែលទាក់ទងនឹងព្រះជាម្ចាស់ បើកូននោះបានឮគេនិយាយពីព្រះជាម្ចាស់កាលពីទើបនឹងកើតភ្លាម ។ នៅពេលដែលកូននោះមានអាយុ២ឆ្នាំ គេបានឮពាក្យគេនិយាយពីព្រះ និងពីព្រះយេស៊ូដែលគេនិយាយទាក់ទងនឹងសេចក្ដីស្រឡាញ់ និងការគាំពារថែរក្សារបស់ព្រះអង្គ ។ នៅពេលដែលគេមានអាយុ៣ឆ្នាំ គេមានអារម្មណ៍ទទួលបាននូវព្រះវត្តមានរបស់ព្រះជាម្ចាស់" ។[៧]

ការសង្កេតមើលអំពីការឆ្លើយតបរបស់កូនខ្ញុំចំពោះរឿងស្ដីពីព្រះគ្រីស្ដបានបង្ហាញឲ្យខ្ញុំដឹងច្បាស់ពីការនេះ ។ *ឌីឡាន* ឥឡូវនេះអាយុ ៤ឆ្នាំ ហើយ នាងបានស្ដាប់រឿងនៅក្នុងព្រះគម្ពីរតាំងពីនាងអាយុមិនទាន់មួយឆ្នាំម្ល៉េះ ហើយនាងចេះចាំរឿងនោះច្បាស់ណាស់តាំងពីដើមដល់ចប់ ។ លើសពីនេះទៅទៀតនោះ ស្មារតីដ៏វាងវៃរបស់នាងមានការចាក់ឫសជ្រៅក្នុងសេចក្ដីពិត ហើយនាងកំពុងតែចំរើនលូតលាស់ផ្នែកទំនាក់ទំនងដ៏ពិតប្រាកដជាមួយព្រះជាម្ចាស់ ។ ជួនកាលយើងសង្កេតឃើញនាងផ្អាកពាក់កណ្ដាលនូវអ្វីដែលនាងកំពុងធ្វើ ហើយនៅពេលដែលយើងសួរនាងថា ម៉េចបានជាផ្អាកអ៊ីចឹង នាងឆ្លើយថា នាងកំពុងតែ "ស្ដាប់ព្រះសូរសៀងព្រះជាម្ចាស់" ។ កូនរបស់យើងអាយុពីរឆ្នាំ ឈ្មោះ *ហ្ស* តែងតែជាអ្នកផ្ដើមអធិស្ឋានមុនគេនៅឯតុអាហាររបស់យើង និងនៅមុនពេលចូលគេង ។ យប់មួយនោះកាលពីឆ្នាំទៅ នាងភ្ញាក់ឡើងយំនៅពេលយប់ យំរកអ្នកយាមពេលយប់របស់យើង ហើយក៏នាំគ្នាអធិស្ឋានឲ្យគាត់ ។ នៅពេលព្រលឹមឡើងយើងបានដឹងថាអ្នកយាមរបស់យើងត្រូវទទួលគ្រោះថ្នាក់ចរាចរមានរបួស គឺនៅពេលយប់ដែលកូនរបស់

[៧] Sears, Christian Parenting, 332.

យើងសួររកគាត់នោះឯង ។ ដោយការសង្កេតឃើញពីការប្រាប់ឲ្យដឹងផ្នែកវិញ្ញាណរបៀបនេះតាមរយៈកូនតូចរបស់យើង ការនោះជួយជំរុញឲ្យយើងដឹងថា ព្រះជាម្ចាស់មានព្រះបន្ទូលមកកាន់ដួងចិត្តនៃជីវិតគ្រួសាររបស់យើង ។ យើងអធិស្ឋាន និទានរឿង និងច្រៀងសរសើរព្រះជាមួយគ្នាដោយដឹងប្រាកដថា ព្រះវិញ្ញាណរបស់ព្រះជាម្ចាស់កំពុងធ្វើការនៅក្នុងដួងចិត្តកូនរបស់យើង ។

> "សេចក្តីទាំងនេះដែលអញបង្គាប់ដល់ឯងនៅថ្ងៃនេះ នោះត្រូវនៅជាប់ក្នុងចិត្តឯងចុះ ត្រូវឲ្យប្រិតប្រៀនសេចក្តីទាំងនេះដល់កូនចៅឯង ព្រមទាំងនិយាយដំណាលក្នុងកាលដែលអង្គុយនៅក្នុងផ្ទះ ហើយដើរតាមផ្លូវក្នុងកាលដែលដេក ហើយក្រោកឡើងផង ត្រូវចងសេចក្តីទាំងនេះជាប់នៅដៃឯងទុកជាទីសំគាល់ ហើយត្រូវធ្វើជាស្លាកនៅកណ្តាលថ្ងាសឯងផង ក៏ត្រូវកត់នៅក្របទ្វារផ្ទះឯង ហើយនៅទ្វារកំផែងរបស់ឯងផង ។" (ចោទិយកថា ៦:៦-៩)

## កុមារជាមនុស្សពិសេសម្នាក់

ដោយយល់ថាកុមារទាំងឡាយជាមនុស្សពេញលក្ខណៈ នោះយើងត្រូវប្រព្រឹត្តចំពោះគេឲ្យសមនឹងតម្លៃលក្ខណៈពិសេសរបស់គេនោះឯង ។ វាជាការងាយចំពោះយើងក្នុងការបកស្រាយការយល់ឃើញរបស់កុមារថាមានតម្លៃទាប ឬមិនសូវសំខាន់ដូចជាមនុស្សចាស់ នៅក្នុងប្រព័ន្ធគ្រប់គ្រងនៅលោកិយ មនុស្សពេញវ័យកាន់អំណាច និងមានសិទ្ធិអំណាច ការបញ្ចេញគំនិតរបស់កុមារ ឬអ្នកក្រីក្រនោះងាយនឹងត្រូវគេបំភ្លេច ឬឲ្យតម្លៃទាប ។ ផ្ទុយទៅវិញ ព្រះជាម្ចាស់ផ្តល់តួនាទីពិសេសចំពោះកុមារនៅក្នុងអាណាចក្ររបស់ព្រះអង្គ ហើយនៅក្នុងដំណឹងល្អទាំងមូល ព្រះយេស៊ូបញ្ជាក់ពីតម្លៃនៃ

"មនុស្សតូចៗទាំងនេះ" ។ នៅក្នុងដំណឹងល្អលោកម៉ាកុស យើងឃើញថា ព្រះយេស៊ូមានការឈ្វេងយល់ផ្ទុយពីពួកសិស្សរបស់ព្រះអង្គ ស្តីពីកុមារទាំងឡាយដែលគេចូលមករកព្រះអង្គ ។ ព្រះអង្គមានបន្ទូលថា៖ "ទុកឲ្យកូនក្មេងមកឯខ្ញុំចុះ កុំឃាត់វាឡើយ ដ្បិតនគរព្រះមានសុទ្ធតែមនុស្សដូចវារាល់គ្នាដែរ"[៨] នៅក្នុងរឿងនៃអព្ភូតហេតុអស្ចារ្យដែលព្រះយេស៊ូបានផ្តល់ចំណីអាហារដល់ហ្វូងមនុស្ស រឿងនោះកើតឡើងដោយសារអំណោយរបស់កុមារម្នាក់ដែលមាននំបុ័ង និងត្រីថ្វាយដល់ព្រះយេស៊ូ ហើយពេលនោះព្រះគ្រីស្ទប្រើអាហាររបស់កុមារនោះទៅចំអែតដល់មនុស្សពេញវ័យរាប់ពាន់នាក់ ។[៩] ការជ្រើសរើសដ៏មានឥទ្ធិពលធំធេងនោះ គឺការដែលព្រះអង្គយាងមកយកនិស្ស័យជាមនុស្សនៅក្នុងចំណោមយើងរាល់គ្នា ដោយព្រះអង្គឆ្លងកាត់កុមារភាពជាមុនដំបូង ព្រះអង្គមិនបានលេចមកឲ្យយើងឃើញជាមនុស្សពេញវ័យតែម្តងទេ ព្រះអង្គមានបន្ទូលឲ្យតម្លៃសំខាន់ទៅលើការលូតលាស់និស្ស័យលក្ខណៈរបស់កុមារ ។

មនុស្សដែលមានភាពស្និតស្នាលជាមួយក្មេង តែងតែទាក់ទងជាមួយក្មេងក្នុងកំរិតនៃការយល់ដឹងរបស់កុមារនោះផ្ទាល់តែម្តង ។ ជាទូទៅគឺចាប់ផ្តើមយល់ពីកំរិតយល់ដឹងរបស់កុមារនៅពេលដែលចំណាយពេលលេងជាមួយកុមារនោះ ផ្តល់ភាពកក់ក្តៅ និងការកែតម្រង់ជួយឲ្យមនុស្សពេញវ័យយល់ឃើញពីគំនិតរបស់កុមារ និងធ្វើឲ្យមានការយល់ដឹងប្រាប់ដល់កុមារ ។ នៅពេលគ្រីស្តបរិស័ទដែលជាមនុស្សពេញវ័យខំប្រឹងប្រែងយល់ពីកំរិតយល់ដឹងរបស់កុមារនៅក្នុងសហគមន៍របស់យើង ហើយបញ្ចូលគំនិតខ្លះរបស់កុមារទៅក្នុងការរស់នៅជាសហគមន៍ និងការថ្វាយបង្គំព្រះជាម្ចាស់

[៨] *ម៉ាកុស ១០:១៤*

[៩] *យ៉ូហាន ៦:៩*

របស់យើង នោះយើងកាន់តែអាចក្លាយដូចជាការរស់នៅមួយបែបនៃអាណាចក្ររបស់ព្រះជាម្ចាស់ ។ លោកគ្រូគង្វាល *ជីម ប្រិនណឺមែន* ពីក្រុមជំនុំ *ប៉ាសាឌីណា ម៉េណូណៃ* បានឲ្យយោបល់ថា៖ "ក្រុមជំនុំអាចជាកន្លែងមួយដែលប្រសើរនោះ ដរាបណាជារឿយៗយើងព្រមអង្គុយស្តាប់នូវអ្វីដែលកូនរបស់យើងគេបង្រៀនយើង" ។[១០]

កុមារមានលក្ខណៈទោល មិនមែនគ្រាន់តែជាមនុស្សមួយក្រុមប៉ុណ្ណោះទេ គឺគេមានលក្ខណៈពិសេសរៀងៗខ្លួនតែម្តង ។ ទំនុកតម្កើង ១៣៩ គឺជាប្រយោគមួយដ៏ល្អប្រណិតដែលថែងពីជំនាញដ៏ប៉ិនប្រសប់របស់ព្រះអាទិករដែលព្រះអង្គបាន "ផ្សំគ្រឿង ឬផ្សំបញ្ចូលគ្នាឲ្យទារកលូតលាស់នៅក្នុងផ្ទៃរបស់ម្តាយគេនោះ" ហើយដែលបានប្រកាសថា កុមារម្នាក់ៗព្រះអង្គបាន "បង្កើតគេមកគួរឲ្យកោតសរសើរ និងគួរអស្ចារ្យ " ពីស្នាព្រះហស្តរបស់ព្រះអង្គ ។ ការប្រដៅតម្រង់របស់យើង ត្រូវទទួលស្គាល់ពីលក្ខណៈទោលរបស់កុមារម្នាក់ៗ ។ អ្វីដែលខ្ញុំ ហើយនិងប្តីរបស់ខ្ញុំរៀនបានពីការបីបាច់ថែទាំកូននោះ គឺបានតាមរយៈការយល់ដឹងពីអារម្មណ៍ ប្រឌិតញាណរបស់កូនស្រីច្បងរបស់យើង ដែលមិនមែនតែងតែមានប្រយោជន៍រហូតចំពោះប្អូនស្រីរបស់នាងដែលមានលក្ខណៈក្លាហាន និងរួសរាយរាក់ទាក់នោះទេ ។

គ្រោងការដ៏គួរឲ្យចាប់អារម្មណ៍ចំពោះការ "ស្វែងយល់" ពីកូនរបស់យើងនោះគឺត្រូវតែស្វែងរកឲ្យឃើញពីលក្ខណៈទោលគ្មានពីរ ដែលគេបានទទួលពីព្រះជាម្ចាស់ដែលផ្តល់សេចក្តីស្រឡាញ់ដល់គេ ។ នេះគឺជាគំនិតដែលបានលើកឡើងនៅក្នុងសៀវភៅណែនាំពីរបៀបចិញ្ចឹមកូនរបស់គ្រីស្តបរិស័ទជាច្រើន ។ មានដំបូន្មានមួយបានចែងថា "និយាយភាសាដែលបង្ហាញពីសេចក្តីស្រឡាញ់"[១១] រួមទាំងការបីបមថ្នមថៃថ្នែករាងកាយ ពាក្យសំដីលើក

---

[១០] James E. Brenneman, Sermon 346, 27 February 2002.

[១១] Chapman and Campbell, *Five Love Languages*, 7.

ទឹកចិត្ត គុណភាពនៃពេលវេលា ការជូនអំណោយ (កាដូ) និងសកម្មភាពដែលបង្ហាញពីការបំរើ ។ ទំនៀមទម្លាប់នីមួយៗមានរបៀបជាផ្នែកៗរបស់ខ្លួនផ្ទាល់ក្នុងការបង្ហាញ និងការទទួលនូវសេចក្តីស្រឡាញ់ ឬយ៉ាងហោចណាស់ក៏មានការខុសប្លែកគ្នានៅក្នុងផ្នែកទាំងនោះដែរ ។ ទោះបីជាយ៉ាងណាក៏ដោយ ចំពោះមាតាបិតាទាំងអស់ ការដែលប្រសើរនោះគឺគេត្រូវសួរខ្លួនឯងថា៖ តើខ្ញុំពិតជាដឹងនូវរបៀបបង្ហាញសេចក្តីស្រឡាញ់ដល់កូនមែនដែរទេ? តើខ្ញុំបានសំគាល់ឃើញនូវរបៀបដែលកូនរបស់ខ្ញុំបង្ហាញសេចក្តីស្រឡាញ់ដល់អ្នកដទៃជាប្រចាំដែរទេ? ការបង្វឹកបង្ហាត់កូនក្នុងរបៀបមួយដែលគេគួរធ្វើ អាចធ្វើទៅបានសម្រេចប្រសើរបំផុតនៅពេលដែលយើងខំប្រឹងប្រែងស្គាល់ និងបញ្ជាក់យ៉ាងច្បាស់ពីអំណោយទានពិសេស និងបុគ្គលិកលក្ខណៈរបស់កូនយើង គឺដូចជាការដែលព្រះជាម្ចាស់ស្គាល់យើងច្បាស់យ៉ាងជិតស្និទ្ធ ហើយព្រះអង្គដឹងពីរបៀបដែលត្រូវបង្វឹកបង្ហាត់យើងដូច្នោះដែរ ។ មានតែធ្វើយ៉ាងនោះទេទើបយើងអាចជួយពង្រឹងអំណោយទានរបស់គេ និងបង្ហាញពីសេចក្តីស្រឡាញ់ដ៏ធំធេងទៅដល់គេបាន ។

ការរៀនឲ្យស្គាល់ពីគំនិតជាក់លាក់ណាមួយរបស់កូនយើង នឹងជួយឲ្យយើងយល់ពីហេតុផលដែលនៅពីក្រោយទំនាស់ ដែលយើងតែងមានជាមួយគេនោះ ។ ឧទាហរណ៍ នៅពេលថ្មីៗនេះ ខ្ញុំបានយល់ឃើញនូវមូលហេតុសំខាន់នៃភាពតានតឹងរវាងខ្ញុំនិងកូនស្រីរបស់ខ្ញុំ គឺយើងមានល្បឿនខុសគ្នា ។ ខ្ញុំបោះជំហានលឿន និងសម្រេចចិត្តអ្វីមួយលឿន ឯកូនស្រីរបស់ខ្ញុំវិញនាងជាមនុស្សប្រើគំនិតគិតច្រើន នាងត្រូវការពេលគិតមុននឹងផ្លាស់ប្តូរអ្វីមួយនោះ ។ ឥឡូវនេះខ្ញុំយល់ ហើយខ្ញុំអាចសំគាល់ឃើញនូវភាពខុសប្លែកគ្នារវាងផ្នែកសីលធម៌ និងការដែលគ្រាន់តែខុសប្លែកគ្នារវាងបុគ្គលិកលក្ខណៈតែប៉ុណ្ណោះ ។ បើសិនមានទំនាស់រវាងបុគ្គលិកលក្ខណៈដែលមិនត្រូវគ្នានោះ គឺវាអាស្រ័យលើស្ថានភាព គឺខ្ញុំអាចព្យាយាមផ្តល់ឱកាសដល់

*ឌីឡាន* ជាកូនរបស់ខ្ញុំ ដោយព្រោះនាងជាមនុស្សម្នាក់ដែលមានការយល់ដឹងតិចតួច ហើយដោយការធ្វើបែបនោះ គឺបង្ហាញពីគំរូនៃការបន្ទាបខ្លួន និងការបង្ហាញពីសេចក្ដីស្រឡាញ់ដល់នាង ឬបើសិនជាខ្ញុំមិនអាចធ្វើការនោះបានទេ ខ្ញុំអាចព្យាយាមបង្រៀនឲ្យនាងចេះថ្លឹងថ្លែងយោងតាមស្ថានការណ៍ ប៉ុន្តែការធ្វើការនោះ គឺខ្ញុំធ្វើដោយចិត្តសុភាព ដោយយល់ដល់នាង ព្រោះនៅក្នុងពេលដែលនាងត្រូវប្ដូរការលូតលាស់ពីមួយដំណាក់ទៅមួយដំណាក់ទៀតនោះ ។

## កុមារជាមនុស្សដែលត្រូវការចំពោះការកែតម្រង់

ដើម្បីស្គាល់កូនរបស់យើងឲ្យបានច្បាស់ដូចដែលព្រះជាម្ចាស់ស្គាល់យើងនោះ យើងត្រូវតែទទួលស្គាល់ថា ព្រះជាម្ចាស់ជប់សូនបង្កើតគេឲ្យមានលក្ខណៈបែបហ្នឹង គឺមានលក្ខណៈពិសេស ហើយប្លែកពីអ្នកដទៃដែលមានសក្ដានុពលចំពោះទំនាក់ទំនងជាមួយព្រះជាម្ចាស់ និងជាមួយមនុស្ស ដូច្នេះចូរយើងយល់ថាគេជាមនុស្សបថុជ្ជនដូចយើង គឺត្រូវការការប្រោសលោះដូចគ្នាដែរ ។ សុភាសិត ២២:១៥ ចែងថា៖ "សេចក្ដីចំកួតរមែងនៅជាប់ក្នុងចិត្តរបស់កូនក្មេង" ។ ចំពោះអ្នកដែលមិនមានកូនអាយុពីរ ឬបីឆ្នាំដូចយើងមិនដឹងពីការនេះទេ ។ ជួនកាលសេចក្ដីចំកួតនោះ ខ្ញុំសង្កេតឃើញនៅក្នុងការប្រព្រឹត្តិរបស់កូនខ្ញុំ ដូចជាការលោតចុះលោតឡើងនៅលើស៊ីក្លូពេលដែលស៊ីក្លូកំពុងតែធ្វើដំណើរ ឬក៏រត់លេងលើថ្នល់ ។ ប៉ុន្តែពេលខ្លះ បញ្ហានោះទាក់ទងលើផ្នែកសីលធម៌រស់នៅ ។ ការប្រដៅតម្រង់ ឬការដឹកនាំឲ្យទាន់ពេលដែលត្រូវកែតម្រូវ នោះគឺជាគំនិតមួយដ៏ល្អបំផុតចំពោះតួនាទីរបស់យើងដែលជាឪពុកម្ដាយនោះ ។ ប៉ុន្តែការនោះគឺជាការចាំបាច់បំផុតដើម្បីដឹកនាំកូនឲ្យទៅតាមអំណោយទានប្រកបដោយសក្ដានុពលដែលព្រះជាម្ចាស់ប្រទានមកឲ្យកូនយើង និងនាំឲ្យគេបានទទួលព្រះពរចំពោះការដែលដើរជាប់ជាមួយនឹងព្រះជាម្ចាស់ ។

នៅក្នុងអត្ថបទនេះ ខ្ញុំគ្មានបំណងដើម្បីសរសេរពីរបៀបប្រដៅតម្រង់កូនចៅដ៏ជាក់លាក់ណាមួយនោះឡើយ ។ តែទោះជាយ៉ាងណាក៏ដោយ នៅគ្រប់ផ្នែកនៃការប្រដៅតម្រង់កូនចៅរបស់យើង ត្រូវទុកឱកាសសំរាប់ប្រាស្រ័យទាក់ទងជាមួយកូន ដោយការបន្តសិក្សាឲ្យស្គាល់ពីលក្ខណៈនិស្ស័យរបស់កូន នោះជាការសំខាន់ណាស់ ។ ការខំប្រឹងប្រែងគាំទ្រដែលនាំឲ្យយើងបានស្គាល់ពីលក្ខណៈនិស្ស័យរបស់កូនយើង នឹងជួយសម្រួលដល់ការប្រដៅតម្រង់កូនបានមួយចំណែកដែរ ។ ដ្បិតការប្រាស្រ័យទាក់ទងនេះឯងដែលផុសចេញពីការទំនាក់ទំនងបង្កើតឲ្យមានការទុកចិត្តបែបនេះនឹងជួយយើងបាន គឺៈ

- វិធានការប្រដៅតម្រង់ នៅក្នុងគោលដៅទាំងអស់នៃការដាក់ពិន័យគឺៈ ត្រូវឲ្យកូនយល់ និងពង្រឹងចរិតលក្ខណៈដែលកោតខ្លាចព្រះនៅក្នុងគំនិតរបស់កូន ។ [១២]
- បង្ហាញឲ្យកូនរបស់យើងឃើញច្បាស់ ផ្តល់ឲ្យគេមានជំរើស និងឲ្យគេឃើញពីផលវិបាកតាមរបៀបមួយដែលគេអាចប្រើគំនិតយល់បាន ។

ចូរបង្កើតរចនាសម្ព័ន និងលក្ខខ័ណ្ឌនានានៅក្នុងផ្ទះរបស់យើងដែលអាចជំរុញលើកទឹកចិត្តកូនរបស់យើងឲ្យមានចិត្តចង់មានឥរិយាបថមួយដែលជាទីគួរឲ្យប្រាថ្នាចង់បាន ។ ការនេះនឹងជួយឲ្យយើងរក្សានូវឥរិយាបថដ៏ត្រឹមត្រូវក្នុងការកែតម្រូវស្តីប្រដៅកូនរបស់យើង ប្រយោជន៍មិនឲ្យយើងប្រព្រឹត្តដោយប្រើកំហឹង តែត្រូវឲ្យយើងមានចិត្តធូរវិញ ដែលឆ្លុះបញ្ចាំងពីការដែលព្រះជាម្ចាស់ប្រដៅតម្រង់បុត្រធីតារបស់ព្រះអង្គ ។

---

[១២] *សូមមើល ហេព្រើរ ១២:១០-១១*

## អំណាចនៃឥទ្ធិពលរបស់ឪពុកម្តាយ

យើងបានឃើញថាព្រះជាម្ចាស់មានព្រះបន្ទូលជាច្រើនស្តីអំពីកុមារ គឺព្រះជាម្ចាស់ជាអ្នកបង្កើតគេមកជារូបឆ្លុះរបស់ព្រះអង្គ ជាមនុស្សដែលមានបុគ្គលិកលក្ខណៈទាំងអស់ មាននិស្ស័យលក្ខណៈជាកុមារភាព ហើយព្រះអង្គបានបង្កើតគេមកតាមបែបផែនមួយដែលមានសមត្ថភាពក្នុងការធ្វើទំនាក់ទំនង ប៉ុន្តែទំនាក់ទំនងនោះត្រូវការការប្រោសលោះ ដើម្បីឲ្យគេបានរស់នៅក្នុងទំនាក់ទំនងដ៏សុចរិតត្រឹមត្រូវជាមួយព្រះជាម្ចាស់ និងជាមួយអ្នកជិតខាងខ្លួន។ ដោយយោងតាមការទាំងនេះ វេជ្ជបណ្ឌិត *ស៊ា* បបួលយើងឲ្យចាប់យកគំនិតដែលយើងត្រូវខំសិក្សាពីកូនរបស់យើង ប្រៀបដូចជាអ្នកថែសួនស្គាល់ពីរុក្ខជាតិទាំងឡាយដែលដុះនៅក្នុងសួនរបស់គាត់ដូច្នេះដែរ ។ ការនេះមានន័យថា ត្រូវរៀនឲ្យស្គាល់របៀបត្រឹមត្រូវក្នុងការបីបាច់ចិញ្ចឹមកូនរបស់យើង ហើយត្រូវប្រយ័ត្នពីឧបសគ្គទាំងឡាយដែលធ្វើឲ្យកូនរបស់យើងងាយរងគ្រោះនោះ ។ ដោយប្រើវិធីនៃការប្រដៅតម្រង់របៀបនេះ ការណែនាំរបស់យើងមិនធូររលុងពេក និងមិនតឹងតែងខ្លាំងពេក ពីព្រោះយើងពិនិត្យមើលរបៀបប្រដៅតម្រង់របស់យើងដោយប្រាជ្ញា និងដោយភ្នែកដែលពោរពេញដោយព្រះគុណរបស់ព្រះជាម្ចាស់ ដូចដែលព្រះជាម្ចាស់ទតមើលមកយើង ហើយព្រះអង្គដឹកនាំការទាំងនោះតាមគតិបណ្ឌិតរបស់ព្រះអង្គដែរ ។

សំណុំទឹកឃ្មុំ ៣/២ (មេសា ២០០២)៖ ២៥-៣៣



# កូនស្រីពិការពិត
# តែចិត្តមិនពិការឡើយ

*អ្នកស្រី សួន នាង*

កណ្ដាលរាត្រីដ៏សែនស្ងាត់ មានសំលេង ង៉ា ង៉ា បន្លឺចេញពីផ្ទះឈើមួយខ្នង ។ ង៉ា ង៉ា ជាសំលេងទារិកាម្នាក់ដែលទើបនឹងបើកភ្នែកទទួលពន្លឺនៃសេចក្ដីស្រឡាញ់ពីឪពុកម្ដាយ ទទួលភាពកក់ក្ដៅពីដៃជីដូនជីតា និងទទួលធាតុក្ដៅត្រជាក់ពីព្រះអាទិត្យ និងព្រះច័ន្ទ ។ សំលេង ង៉ា ង៉ា ចង់ប្រាប់ថានាងឃ្លាន នាងភ័យ ព្រោះពីពេលនេះទៅនាងត្រូវប្រឹងប្រែងដោយខ្លួនឯង ។ គឺនាងត្រូវដកដង្ហើមខ្លួនឯង ត្រូវប្រឹងជញ្ជក់ទឹកដោះម្ដាយហើយលេបខ្លួនឯង ។

មនុស្សទាំងអស់នៅក្នុងគ្រួសារញញឹម សប្បាយរីករាយ ព្រោះបានសមាជិកាថ្មីម្នាក់ទៀត ។ ជីដូនជីតាស្រឡាញ់ចៅស្រីណាស់ ហើយបានដាក់ឈ្មោះថា *សៀវ លី* ។ គ្មានអ្នកណាម្នាក់នឹកបារម្ភពីអ្វីដែលនឹងត្រូវធ្លាក់មកលើគ្រួសារនេះឡើយ ។

មួយឆ្នាំបានកន្លងទៅ... ។

ថ្ងៃមួយនោះបុគ្គលិកពេទ្យភូមិដើរចាក់ថ្នាំការពារជំងឺ៦មុខឲ្យក្មេងៗ ។ ម្តាយ *សៀវ លី* រួសរាន់អញ្ជើញពេទ្យចាក់ថ្នាំឲ្យកូន ។ ពេទ្យសួរថា កូនអ្នកមានក្តៅខ្លួនទេ? គាត់ឆ្លើយថា អត់ក្តៅខ្លួនទេ ។ គ្រូពេទ្យចាក់ថ្នាំរួចទើបគាត់នឹកឃើញថា ពីយប់មិញគាត់បានឲ្យកូនញ៉ាំថ្នាំប៉ារ៉ា ។ គាត់គ្រាន់តែនឹកឃើញមួយភ្លែតក៏ភ្លេចទៅវិញភ្លាម ព្រោះរវល់លួងលោមកូនឲ្យបាត់យំ ។

យប់នោះ *សៀវ លី* ក្តៅខ្លួនខ្លាំងណាស់ កន្ត្រាក់ដៃ កន្ត្រាក់ជើង ម្តាយ *សៀវ លី* ឲ្យកូនញ៉ាំប៉ារ៉ាទៀត តាមការណែនាំរបស់គ្រូពេទ្យដែលបានចាក់ថ្នាំពីព្រឹក ។

ព្រឹកឡើង ម្តាយ សៀវ លី មានការបារម្ភខ្លាំងជាងពីយប់ ព្រោះក្រៅពីកំដៅមិនចុះ ដៃជើងកូនគាត់ហាក់ដូចជាពិបាកកំរើកខុសពីពេលធម្មតា ។ ញាតិជិតខាងខ្លះឲ្យយោបល់ថាគួរតែនាំកូនទៅមន្ទីរពេទ្យ ប៉ុន្តែខ្លះថា មិនអីទេ ចាក់ថ្នាំការពារធ្វើទុក្ខអីចឹងហើយ ។ មួយអាទិត្យកន្លងទៅ ជំងឺ *សៀវ លី*នៅតែដដែល ដូច្នេះគាត់ក៏សំរេចចិត្តយក *សៀវ លី* ទៅមន្ទីរពេទ្យ ។ គាត់បានសំរាកនៅមន្ទីរពេទ្យបីសប្តាហ៍ ។ *សៀវ លី* បាត់ក្តៅខ្លួនហើយ តែអាការៈដៃជើងខ្លួនប្រាណធ្វើឲ្យគាត់អស់សង្ឃឹម ។ មាត់វៀច ម្រាមដៃស្តាំក្តាប់យ៉ាងតឹង ម្រាមឆ្វេងលាត ហើយប្រឹងឡើងរឹង ។ ប្រអប់ជើងរមួលខ្ទេចូលក្នុង ឯម្រាមជើងកាច់ចុះក្រោម ។

ទុក្ខសោកបានគ្របដណ្តប់គ្រួសារដ៏អភ័ព្វនេះ ។ ម្តាយឪពុក ជីដូនជីតា តែងតែរត់ទៅរកគ្រូគ្រប់ទីកន្លែងដែលគេប្រាប់ និងបន់ស្រន់ដូនតាសែនអារក្សអ្នកតាគ្រប់ពេលដែលហោរាណែនាំ ។

ពេលវេលាចេះតែកន្លងទៅ ។

នៅពេលដែល *សៀវ លី* អាយុ៦ឆ្នាំ នាងអាចអង្គុយបាន ប៉ុន្តែមិននឹងល្អ ហើយអាចនិយាយបាន ប៉ុន្តែអ្នកក្រៅគ្រួសារស្តាប់មិនយល់ទេ ។ *សៀវ*

*លី* មិនអាចដើរបានឡើយ ។ ឪពុកម្ដាយចាប់ផ្ដើមអស់សង្ឃឹមមែនទែន គាត់ឈប់រកគ្រូ ហើយឈប់ជឿ បន់ដូនបន់តា គាត់គិតតែពីរកស៊ីវិញម្ដង ។

ថ្វីត្បិតតែ *សៀវ លី* ដើរមិនរួច ប៉ុន្តែរូបរាងកាយចេះតែរីកដុះដាល ធំធាត់ទៅតាមអាយុកាលដែរ ។ ឥឡូវនេះ *សៀវ លី* អាយុ១២ឆ្នាំហើយ ។ នាងតែងរំកិលចុះតាមកាំជណ្ដើរឲ្យគេជួយលើកដាក់លើអង្រឹងនៅក្រោមផ្ទះ។ ដោយដៃជើងនាងរឹងក្រញ៉ឹងក្រញង់ នាងធ្លាក់ពីលើអង្រឹង ឬទោងញយដង។ ការធ្លាក់ញយដងនេះ ជាវិធីសំងាត់ដែលជំរុញឲ្យនាងប្រឹងងើបឈរដោយខ្លួនឯង ។ នៅអាយុ១៣ឆ្នាំ *សៀវ លី* អាចងើបឈរដោយខ្លួនឯងបានយ៉ាងត្រដាបត្រដួស ប៉ុន្តែមិនអាចឈានដើរឡើយ ។

ថ្ងៃមួយនោះ ជាថ្ងៃដែលព្រះជាម្ចាស់ប្រទានពរឲ្យ *សៀវ លី* ។ មានស្ត្រីចំណាស់ម្នាក់ មានរបរជាគ្រូព្យាបាលជំងឺបន្តិចបន្តួចតាមបែបបុរាណ បានឃើញ *សៀវ លី* ហើយបានសុំយកនាងទៅព្យាបាលនៅផ្ទះគាត់ ។ ឪពុកម្ដាយមិនមានសង្ឃឹមអ្វីទេលើលោកយាយម្នាក់នោះ ប៉ុន្តែគាត់ចង់សាកល្បងមើល ។ ដូច្នេះគាត់ក៏សំរេចចិត្តនាំ *សៀវ លី* ទៅផ្ទះលោកយាយ ។ លោកយាយមិនអនុញ្ញាតឲ្យមានក្រុមគ្រួសារណាម្នាក់នៅជាមួយ *សៀវ លី* ឡើយ ឪពុកម្ដាយស្រក់ទឹកភ្នែកអាណិតកូនពេលចាកចេញត្រលប់ទៅផ្ទះវិញ ព្រោះ *សៀវ លី* ត្រូវរស់នៅជាមួយលោកយាយក្នុងខួមជរា ។

លោកយាយចងឫស្សីមួយដើមភ្ជាប់ទៅនឹងដើមស្លា ដើម្បីធ្វើស្ពា រាល់ថ្ងៃ លោកយាយឲ្យ *សៀវ លី* ក្រោកពីយប់ដើម្បីហាត់ប្រាណ ។ លំហាត់ប្រាណគឺត្រូវតោងឈរ ។ ទោះបី *សៀវ លី* ដួលប៉ុន្មានដងក៏ដោយ ក៏លោកយាយមិនខ្វល់ដែរ គឺដាច់ខាតត្រូវតែប្រឹងតោងឈរឲ្យទាល់តែបាន និងខំតោងដើរទៅមុខ ។ ក្រៅពីហាត់ប្រាណមិនឲ្យទំនេរទេ ត្រូវធ្វើការបន្តិចបន្តួចជានិច្ច ដូចជា បាចអង្ករឲ្យមាន់ លាងចានឆ្នាំង ដាំបាយ បោចស្មៅ ។

នៅពេលដែលខ្ញុំធ្វើការនៅជំរំជនភៀសខ្លួន សាយធូ មានមនុស្សជំទង់មួយក្រុមដែលគេបញ្ជូនឲ្យទៅនៅចុងជំរំម្ខាងគឺជាកន្លែង "មណ្ឌលកុមារកំព្រា" សំរាប់ក្មេងប្រុសដែលបាត់បង់អវយវៈដោយសារតែគ្រាប់មីននៅពេលដែលគេចូលប្រយុទ្ធក្នុងសមរភូមិ ។ ទោះបីជាគេប្រយុទ្ធក្នុងបុព្វហេតុប្រទេសជាតិរបស់ខ្លួនក៏ដោយ ពួកគេត្រូវទទួលនូវការស្អប់ខ្ពើមពីសំណាក់អ្នកដែលរស់នៅក្នុងសហគមន៍ ដោយសារតែពួកគេត្រូវធ្លាក់ខ្លួនពិការ ។ ដូច្នេះគេត្រូវទទួលរងនូវវិនាសកម្មពីរដង គឺទីមួយការបាត់បង់អវយវៈរបស់ខ្លួន និងទីពីរការបាត់បង់ការគាំទ្រពីអ្នកដែលជាទីស្រឡាញ់របស់ខ្លួន ។ ជនពិការមួយចំនួនមានការធ្លាក់ទឹកចិត្តយ៉ាងខ្លាំង ដែលជាហេតុបណ្តាលឲ្យគេហ៊ានទៅស៊ីឈ្នួលសម្លាប់មនុស្ស ។ ខ្ញុំសប្បាយរីករាយណាស់ដោយឃើញថា ក្រុមជំនុំមានចំណែកជួយមនុស្សជំពូកនេះនៅថ្ងៃអាទិត្យ

ហើយខ្ញុំនៅចាំបានថាខ្ញុំបានសួរក្មេងប្រុសម្នាក់ថា តើចង់ឲ្យយើងអធិស្ឋានអ្វីសំរាប់វា ។ វាមិនបានសុំឲ្យយើងអធិស្ឋានឲ្យជើងរបស់វាដុះឡើងវិញនោះទេ តែវាបានសុំឲ្យយើងអធិស្ឋានសំរាប់ការផ្សះផ្សាដួងចិត្តរបស់វាទៅវិញ ។ យើងបានអធិស្ឋានសុំការប៉ះពាល់ពិសេសពីព្រះជាម្ចាស់ ប៉ុន្តែបែរទៅជាបានការសោកសៅទៅវិញ ។

វេជ្ជបណ្ឌិត *ស៊ូ ជែក* នៃអង្គការបំរើជនក្រីក្របានពណ៌នាប្រាប់ពីបញ្ហាខ្លះថា គឺមិនអាចកែកុនបានឡើយ ។ "ពីព្រោះ ៩៥% នៃប្រជាជនកម្ពុជាជាអ្នកកាន់តាមលទ្ធិព្រះពុទ្ធសាសនា ការធ្លាក់ខ្លួនពិការនេះ ជារឿយៗទាក់ទងទៅនឹងកម្មផលរបស់ឪពុកម្តាយ ឬរបស់កូននោះទៅវិញទេ ។ បញ្ហាសង្គម និងបញ្ហាហិរញ្ញវត្ថុ ដើរស្របនឹងការយល់ឃើញលើកម្មផលនេះតែម្តង ។ ដូច្នេះការមានអារម្មណ៍កណ្តោចកណ្តែងនោះក៏ដូចគ្នាដែរ ដោយហេតុថា គេបានយកការរងរបួសនេះទៅផ្អែកលើ "ព្រេងវាសនា" ទៅវិញ ទើបគ្មានអ្វីដែលអាចកែប្រែបានឡើយ ។ គ្រួសារទាំងឡាយដែលបរាជ័យក្នុងការស្វែងរកជំនួយពីគ្រូខ្មែរនោះ គឺមិនសូវចាប់អារម្មណ៍ក្នុងការស្វែងរកជំនួយផ្នែកជនពិការដែលមាននៅក្នុងប្រទេសកម្ពុជាប៉ុន្មានទេ ។ ការមានអារម្មណ៍ថាមិនអាចកែកុនបាន និងការមានវាសនាអកុសល មានន័យថា កុមារតែងតែ "ខំលាក់ខ្លួន" ពួនអាត្មា គេចមុខពីគេឯង និងតាមធម្មតាមិនអើពើក្នុងការថែទាំពីអ្នកដទៃ ដូច្នេះយើងយល់ឃើញថា កុមារត្រូវការឲ្យមានការផ្តួចផ្តើមយ៉ាងសស្រាក់សស្រាំបំផុត" ។

### តើអង្គការគ្រីស្តបរិស័ទដោះស្រាយបញ្ហានេះដោយរបៀបណា?

ដូចគ្នានេះដែរព័ន្ធកិច្ចរបស់ព្រះសហគមន៍កាតូលិក ដែលធ្វើការជាមួយនឹងជនពិការនៅវត្តថាន់ ហើយនិងសាលា *ម៉ារីស ឡារ៉ាឡា* មានអង្គការផ្នែកនិកាយប្រូតេស្តង់មួយចំនួនទៀតដែលធ្វើការជាមួយនឹងជនពិការដែរ ។

ការដែលគួរឲ្យចាប់អារម្មណ៍ណាស់នោះគឺ ការដែលយើងបានឃើញអង្គការមនុស្សធម៌ ដូចជាអង្គការបំរើជនក្រីក្របានលើកបញ្ហាពិការភាពនេះឡើងនៅក្នុងសហគមន៍របស់គេ នៅក្នុងស្រុកមានជ័យ ។

វេជ្ជបណ្ឌិត *ស៊ូ ជែក* រៀបរាប់ពីការងាររបស់អង្គការបំរើជនក្រីក្រថាៈ "យើងខំព្យាយាមប្រមូលកុមារឲ្យចូលរៀនឲ្យបានច្រើនតាមដែលអាចធ្វើទៅបាន ធ្វើការតស៊ូមតិនៅក្នុងសាលារៀននៅតាមមូលដ្ឋានជំនួសឲ្យកុមារទាំងឡាយនោះ ហើយផ្តល់សម្ភារៈសិក្សាដែលចាំបាច់ ដើម្បីជំរុញឲ្យកុមារទាំងនោះចូលសាលារៀនតាមដែលអាចធ្វើបាន ។ ឧទាហរណ៍ យើងសាងសង់កន្លែងសំរាប់កុមារលេង ។ មួយអាទិត្យម្តងយើងមានពេលសំរាប់ឲ្យកុមារលេង ឬព្យាបាលដោយចលនាដល់កុមារ ដែលអ្នកថែទាំកុមាររបស់យើងបង្រៀនលំហាត់ប្រាណដ៏សមរម្យដល់កុមារ ជួយជំរុញលើកទឹកចិត្ត និងផ្តល់នូវដំបូន្មានស្តីពីការថែទាំកូនដល់ឪពុកម្តាយ" ។

អង្គការបំរើជនក្រីក្រមិនផ្តល់ឲ្យឪពុកម្តាយមានការច្រឡំឡើយ ។ "យើងបញ្ជាក់ថា វាគឺជាការប្តូរផ្តាច់របស់អ្នកថែទាំដល់កុមារនោះទៅវិញទេ ដែលថានឹងជួយឲ្យក្មេងនោះមានភាពប្រសើរឡើង មិនមែនជាឯកទេសរបស់យើងទេ ហើយយើងបញ្ជាក់ទៀតថា គឺវាត្រូវស៊ីពេលយូរ មានដំណើរការយឺត ។ ហេតុដូច្នេះហើយ យើងធ្វើនូវអ្វីទាំងអស់ដែលយើងអាចធ្វើបាន ដើម្បីបន្តគាំទ្រគ្រួសារទាំងមូល ដោយបញ្ជាក់ឲ្យគេដឹងច្បាស់ពីដំបូន្មានដែលយើងបានផ្តល់គេ ឧទាហរណ៍ ដូចជារបៀបហាត់ធ្វើចលនានៃសរីរាង្គ ។ ការងាររបស់យើងក៏ផ្តល់ឱកាសដ៏សំខាន់សំរាប់ឲ្យគ្រួសារគេបានជួបជុំគ្នា ។ យើងសម្របសម្រួលក្នុងការតភ្ជាប់រវាងគ្រួសារចាស់ និងគ្រួសារថ្មី ដើម្បីឲ្យគេអាចលើកទឹកចិត្តគ្នាតាមការចំរើនលូតលាស់ដែលអាចកើតឡើងនោះ ។ ការធ្វើបែបនេះមានទម្ងន់ធ្ងន់ និងជះឥទ្ធិពលយ៉ាងខ្លាំងច្រើនជាងនូវអ្វីដែលយើងគ្រាន់តែនិយាយទៅទៀត" ។

គេក៏ត្រូវទទួលរងនូវការមានគំនិតអគតិចំពោះពិការភាពផងដែរ ដែលអ្នកខ្លះត្រូវទទួលរងការមានគំនិតអគតិចំពោះជាតិសាសន៍ផងដែរ ។ "យើងកំពុងសំគាល់ឃើញថា ខ្មែរ ចាម (ខ្មែរអ៊ីស្លាម) និងចំនួនក្មេងនៃជនជាតិវៀតណាមកំពុងកើនឡើង ។ បុគ្គលិកម្នាក់របស់យើងអាចនិយាយភាសាវៀតណាមបានល្អណាស់ ហើយមណ្ឌលសុខភាពរបស់យើងនៅប្រចាំស្រុកនោះ មានគ្រួសារវៀតណាមជាច្រើនដែលសង្គមគេមិនសូវរាប់រក ហេតុដូច្នេះហើយទើបមានការពិបាកក្នុងការទទួលការថែទាំសុខភាពនៅប្រទេសកម្ពុជា" ។



រូបទី២ លោក សំអឿន

នាយកសមាគមកម្ពុជាសំរាប់អភិវឌ្ឍកសិករ និងអ្នកក្រីក្រ

មានអង្គការមួយទៀតកំពុងធ្វើការក្នុងវិស័យនេះដែរ គឺសមាគមកម្ពុជាសំរាប់អភិវឌ្ឍកសិករ និងអ្នកក្រីក្រនៅខេត្តកំពត ។ លោក សំអឿន ជានាយករបស់សមាគម(រូបទី២) ខ្លួនឯងផ្ទាល់ជាជនពិការ ហើយដើរត្បួសំខាន់ ជាគំរូដ៏ប្រពៃ ។ គាត់បានបង្ហាញប្រាប់ថា ដោយសារមានជំនួយមកពីព្រះជាម្ចាស់ និងការប្តេជ្ញាចិត្តផ្ទាល់ខ្លួន បុគ្គលរូបនោះអាចធ្វើការពិសេសទាំងឡាយបាន ។ នៅពេលថ្មីនេះគាត់បានប្រមូលផ្តុំចងក្រងរូបថតរបស់កុមារពិការជាច្រើននៅក្នុងសហគមន៍ (សូមមើលរូបទី៣)



*រូបទី ៣ក) កុមារកំពុងលេង*



*រូបទី ៣ខ) កុមារជួយធ្វើកិច្ចការផ្ទះ*

នៅក្នុងការបង្ហាញរូបថតនោះ តាមទស្សនៈរបស់គាត់បញ្ជាក់ប្រាប់ថា បើសិនអំពើអ្វីមួយដែលយើងអាចធ្វើបាន នោះគួរតែប៉ុនប៉ងធ្វើឲ្យបានទៅ ។ កុមារចូលសាលារៀន ដាំស្ល លេង ជួយធ្វើការផ្ទះ និងការងារស្រែចំការជាមួយនឹងមិត្តភក្តិរបស់ខ្លួន ។ កម្មវិធីរបស់អង្គការនោះ គឺជួយគាំទ្រដល់គ្រួសារក្រីក្រតាមរយៈធនាគារគោ ជ្រូក ដែលអាចជួយដល់គ្រួសារទាំងឡាយណាដែលលំបាកតោកយ៉ាកជាងគេ ដោយព្រោះមានកូនពិការនៅក្នុងបន្ទុក (ឧទាហរណ៍ នៅពេលដែលសមាជិកគ្រួសារនោះមិនអាចធ្វើការបាន ព្រោះត្រូវនៅមើលថែកូនពិការ) ។

កុមារទាំងនោះជួនកាលពិការធ្ងន់ធ្ងរ ដែលជាហេតុធ្វើឲ្យគ្រួសារនោះមិនចង់ទុក ឬមិនអាចថែរក្សាគេបាន ។ ឪពុកម្តាយខ្លះដែលមានកូនពិការធ្ងន់ធ្ងរនោះ បែរទៅរកការចង់ធ្វើឃាតកុមារនោះ ។ សូម្បីតែការនេះមិនបានកើតមានឡើងកាលពីនៅទារកក៏ដោយចុះ តែអាចស្លាប់ដោយសារជម្ងឺកង្វះជីវជាតិ គ្រុនចាញ់ ឬជម្ងឺផ្លូវដង្ហើមនៅពេលអាយុមួយខួបដំបូង ។ បើសិនជាកុមារនោះអាចឆ្លងផុតពីការស្លាប់នៅពេលជាទារក កុមារនោះប្រហែលជាអាចរស់នៅមួយរយៈពេល ហើយការនោះតម្រូវឲ្យមានការប្តូរផ្តាច់ក្នុងការថែរក្សារយៈពេលយូរ ។

ការផ្តល់ការថែទាំជាក្រុមនៅតាមផ្ទះនៅពេលថ្មីៗនេះ ដែលគាំទ្រដោយអង្គការ *វ៉ាយវ៉ាម* និង *អ៊ីរ្វក ផាក់* ចំពោះកុមារខ្លះដែលមានបញ្ហាពិការធ្ងន់ធ្ងរ ។ ពួកគេបានចាប់ផ្តើមឡើងក្នុងគោលបំណងបង្កើតស្ថាប័នដ៏ធំមួយសំរាប់កុមារដែលពិការ ហើយត្រូវគេបោះបង់ចោល ។ ការងារនោះទទួលស្គាល់ពីសមត្ថភាពរបស់កុមារដែលកុមារត្រូវទទួលបាន ដូចជាសិទ្ធិទទួលភាពថ្លៃថ្នូរ សេចក្តីស្រឡាញ់ ការគាំទ្រ និងការថែទាំនៅក្នុងសហគមន៍ ។ ការមានសេចក្តីមេត្តាករុណាដ៏សកម្មចំពោះកុមារពិការនោះ ហាក់បីដូចកើតចេញមកពីចរិកលក្ខណៈរបស់គ្រីស្តបរិស័ទជាចម្បង ។ រីឯជំនឿគ្រីស្តបរិស័ទមិនមែនគ្រាន់

តែជាជំនឿតែមួយគត់ ដែលត្រូវមានសេចក្ដីមេត្តាករុណានោះទេ មានអង្គការមួយចំនួនទៀតដែលបានធ្វើការជាមួយកុមារពិការផុសចេញពីជំនឿផ្សេងនោះគឺមានតិចតួចណាស់ ។

## តើអ្វីទៅជាភាពពិការ និងអ្វីទៅជាភាពចុះខ្សោយ?

អង្គការ *ធាហ្វាន់* ជឿជាក់ថា យើងគួរផ្ដោតចិត្តទុកដាក់លើអ្វីដែលកុមារអាចធ្វើបានជាជាងលើអ្វីដែលគេមិនអាចធ្វើបាន ។ អង្គការសុខភាពពិភពលោកមានចែងច្បាប់ជាពិសេសសំរាប់បែងចែកឲ្យដាច់ពីភាពទន់ខ្សោយ និងភាពពិការ (មើលនៅរូបភាពទី៤) ដែលជួយបំរើឲ្យគោលគំនិតនៃការអសមត្ថភាព ។ ការនេះជួយឲ្យជៀសចេញពីគំរូផ្នែកសុខាភិបាលដ៏តឹងតែងដែលមានបំណងចង់បង្ហាញពីមូលហេតុទាំងឡាយ និងផលប៉ះពាល់ពីភាពពិការនេះតាមមធ្យោបាយមួយ ដែលបង្ហាញពីចំណុចវិជ្ជមានឲ្យបានប្រសើរឡើងថែមទៀត ។ ពាក្យថា អសមត្ថភាព និងពិការ គឺគេបានយកគំនិតវិជ្ជមាននៃសកម្មភាព និងការចូលរួមមកដាក់ជំនួសវិញ ។ ទោះបីជាយ៉ាងណាក៏ដោយ យើងត្រូវចងចាំថា "ពាក្យសំដីអាចកែស្ថានការណ៍នយោបាយបាន និងមានការផ្សាភ្ជាប់បានល្អណាស់ ប៉ុន្តែមនុស្សដែលពិការភាគច្រើន គឺនៅឯកោ ត្រមង់ត្រមោចតែឯង គ្មានទិសដៅក្នុងជីវិត គ្មានមនុស្សរាប់រក និងជាទូទៅគេបានកាត់ចេញពីសង្គមតែម្ដង"[៦] ការគ្រាន់តែប្រើពាក្យសំដីនោះមិនគ្រប់គ្រាន់ទេ ទាល់តែអាកប្បកិរិយាដ៏ស្មោះសរដូចជាព្រះគ្រីស្ទក្នុងឋានៈជាអ្នកបំរើនោះទេវិញទេដែលប្រសើរ ។

---

[៦] Nigel Poulton of World Corncer, personal communication.

| ពាក្យ | និយមន័យ |
|---|---|
| ភាពទន់ខ្សោយ | ការបាត់បង់ ឬការមានភាពមិនធម្មតាចំពោះអវៈយវៈណាមួយ (គឺមានន័យថា រចនាសម្ព័ន្ធនៃរាងកាយ) ឬក៏មុខណាមួយរបស់រាងកាយ(ដូចជាផ្នែកមុខងារផ្លូវចិត្ត) ។ ផ្នែកនេះគឺគិតរួមទាំងមុខងាររបស់ខួរក្បាល ។ |
| សកម្មភាព | មនុស្សម្នាក់អាចធ្វើសកម្មភាពងាយៗបាន (ដូចជាការចាប់កាន់ កំរើកជើង សំឡឹងមើល) រហូតជំនាញពិបាកៗ និងអាកប្បកិរិយាពិបាកៗជាច្រើន (ដូចជាការនឹកចងចាំពីព្រឹត្តិការណ៍កាលពីអតីតកាល ឬការល្បងផ្នែកចំណេះដឹង) ។ |
| សកម្មភាពដែលមានដែនកំណត់ (មានភាពពិការពីមុន) | ពិបាកក្នុងការសម្តែងអ្វីមួយ ក្នុងការសម្រេចឲ្យបានអ្វីមួយ ឬការបំពេញបានកិច្ចរបស់មនុស្សនេះ ដោយសារតែមានការឈឺចាប់ មានភាពមិនប្រក្រតី ធ្វើការនោះយឺតពេក លឿនពេក ឬមិនត្រូវចំពេល មិនត្រូវចំកន្លែង ។ |
| ការចូលរួម | ការចូលរួមមានគ្រប់ផ្នែកទាំងអស់នៃទិដ្ឋភាពរបស់-ជីវិតរស់នៅរបស់មនុស្សរួមទាំងការពាក់ព័ន្ធ ការប្រព្រឹត្តិ ទំនៀមទំលាប់ ឬការធ្វើអ្វីមួយដែលមានលក្ខណៈរួមជាសង្គម ។ |
| ការចូលរួមដែលមានដែនកំណត់ | ភាពមិនអំណោយផលរបស់មនុស្សម្នាក់ ដែលភាពទន់ខ្សោយនោះមានការកើតឡើង ឬក៏កាន់តែយ៉ាប់យ៉ឺនខ្លាំងឡើងថែមទៀត ដោយសារតែស្ថានការណ៍នៅជុំវិញ និងកត្តាខ្លះៗនៃបុគ្គលនោះផ្ទាល់តែម្តង ។ |

Source: WHO ICIDH - 2 (1997)

*រូបទី ៤: WHO International Classification of Impairments and Handicaps.*

គំរូផ្នែកវេជ្ជសាស្ត្រស្តីពីភាពពិការនោះ គឺផ្សារភ្ជាប់គ្នាបានល្អណាស់ ដោយមានវេជ្ជបណ្ឌិតជាច្រើនសំឡឹងឃើញភាពទន់ខ្សោយនោះថា "ជាការលូតលាស់មិនធម្មតា" ដែលត្រូវការ "ការកែតម្រូវ" "ការព្យាបាល" ឬ "ការជំនះលើការទាំងនោះឲ្យបាន" ។ ការនេះគឺផ្អែកទៅលើគំនិតដែលថា រូបកាយរបស់មនុស្សអាចកែកុនបាន តែបរិយាកាសសង្គមរស់នៅមិនអាចកែកុនបានឡើយ ។ ភាពពិការដែលមើលតាមគំរូរបស់សង្គមរស់នៅនោះ គឺកើតឡើងដោយគ្រូពេទ្យនៅតាមសហគមន៍ដែលបានសង្កត់ធ្ងន់ថា ភាពពិការឬការអសមត្ថភាពនេះ គឺមានទំនាក់ទំនងទៅនឹងបុគ្គលនោះផ្ទាល់ និងបរិយាកាសរស់នៅរបស់គេ ហើយបានសង្កត់ធ្ងន់ទៀតថា សង្គមមានតួនាទីសំខាន់ក្នុងការធ្វើឲ្យមនុស្សម្នាក់នោះក្លាយជាមនុស្សពិការរហូតនោះ[២] ។

## តើព្រះគម្ពីរចែងយ៉ាងម៉េចអំពីភាពពិការនេះ?

*ប៉ុន្តែអស់ទាំងអវយវៈក្នុងរូបកាយដែលមើលទៅដូចជាខ្សោយជាងគេនោះ មានប្រយោជន៍ជាជាងវិញ ហើយអវយវៈណាក្នុងរូបកាយ ដែលយើងស្មានថាមិនគួររាប់អានប៉ុន្មាន នោះយើងរាប់អានលើសទៅទៀត... អ្នករាល់គ្នាជារូបកាយនៃព្រះគ្រីស្ទ ហើយជាអវយវៈរបស់រូបកាយរៀងខ្លួន* [៣] ។

កុមារម្នាក់ៗព្រះជាម្ចាស់បង្កើតមកមានលក្ខណៈពិសេសជារូបឆ្លុះរបស់ព្រះអង្គ ហើយមានតម្លៃជាទីបំផុត[៤] ។ បើសិនភាពចំរើនវ័យធំឡើងត្រូវកំណត់ឲ្យឃើញច្បាស់ថាជា "ការសម្រេចតាមខ្នាតយ៉ាងពេញលេញរបស់ព្រះគ្រីស្ទនោះ"[៥] ដែលព្រះអង្គដ៏ជាព្រះមកគង់នៅក្នុងរូបកាយរបស់

---

[២] Hartley, Sally, and Sheilah Wirz, 1993.

[៣] *១កូរិន. ១២:២២-២៣,២៧*

[៤] *លោកុ. ១:២៦*

[៥] *អេភេសូរ ៤:១៣*

មនុស្ស"[៦] អ៊ីចឹងកុមារទាំងអស់ក៏ត្រូវមានដែនកំណត់សំរាប់ការលូតលាស់ដែរមុននឹងឈោងទៅដល់វ័យមួយដែលគេត្រូវសម្រេចឲ្យបាននោះ ។ គ្រីស្តបរិស័ទត្រូវជឿចំពោះការនេះថាជាការពិត មិនថាឡើយកុមារនោះមានបញ្ហាក្នុងការចំរើនលូតលាស់ផ្នែករូបកាយ ឬផ្នែកសតិបញ្ញានោះទេ ។ តាមពិតទៅគ្មាននរណាម្នាក់មានលក្ខណៈគ្រប់ពេញលេញ ឬមានការចំរើនលូតលាស់ល្អឥតខ្ចោះនោះទេមុនពេលដែលយើងឡើងទៅស្ថានសួគ៌ ។ សូម្បីតែព្រះយេស៊ូក៏ត្រូវរស់នៅក្នុងសណ្ឋានជាមនុស្សដែលមានដែនកំណត់ដែរ ។ លោកវេជ្ជបណ្ឌិត *ភីធើ សែបូថាំ* ដែលធ្លាប់ធ្វើការជាមួយអង្គការបំរើជនក្រីក្រនៅក្នុងប្រទេសកម្ពុជាបាននិយាយថា "កុមារដែលមានភាពមិនប្រក្រតី ឬគ្មានអវយវៈណាមួយនោះ ត្រូវការការលើកទឹកចិត្តដើម្បីឲ្យគេអាចឈោងចាប់ដល់កំរិតជាសក្តានុពលមួយដែលព្រះប្រទានឲ្យដល់គេនោះ" ។

ទោះបីជាយ៉ាងណាក៏ដោយ "គំនិតស្តីអំពីភាពគ្រប់លក្ខណៈ គឺជាផ្នែកមួយសំខាន់ចំពោះការទទួលស្គាល់ និងការយល់ថា មានភាពមិនប្រក្រតីនោះចាត់ទុកថាជាផ្នែកមួយតូចក្នុងនិស្ស័យលក្ខណៈរបស់បុគ្គលរូបនោះទៅវិញទេ" ។ ហេតុដូច្នេះហើយបានជា បណ្ឌិត *ណាន់ស៊ីឡេន* ដែលខ្លួនគាត់ផ្ទាល់ជាអ្នកពិការនិយាយថា កុមារដែលមានភាពពិការ គឺមាន "ភាពពេញលេញជាមនុស្ស" តាមលក្ខណៈរបស់គេទៅហើយ គឺគ្រាន់តែមានការជិតដាមជាប់នូវផ្នត់គំនិតថាខ្លួនឯងមិនជាបើប៉ុណ្ណោះ ។ "ការនេះក៏ធ្វើឲ្យផ្នត់គំនិតដែលថារាងកាយពិការនោះ មានន័យថាមិនមែនពិការទាំងអស់នោះទេ បានសេចក្តីថាគេមានគំនិត សមត្ថភាពក្នុងការរួមភេទ មានសេចក្តីត្រូវការ និងមានបំណងប្រាថ្នាដូចជាអ្នកដែលមិនពិការនោះដែរ"[៧]។

---

[៦] *កូឡុស ២:៩*

[៧] *ណាន់ ស៊ី ឡេន នៅផ្នែកប្រាស្រ័យទាក់ទងបុគ្គលិក*

តែផ្ទុយទៅវិញ នៅក្នុងប្រទេសកម្ពុជា កុមារដែលមានភាពពិការនោះ តែងតែគេមើលមកហាក់ដូចជារស់នៅដើម្បីបង្ហិនធនធាន ។ ហេតុដូច្នេះ ហើយបានជាសហគមន៍ដូចជាមិនសូវរាប់រកគេ ភាគច្រើនផ្នែករដ្ឋាភិបាល និងមន្ទីរសុខាភិបាល ហើយសូម្បីតែគ្រួសាររបស់គេផ្ទាល់នោះក៏មិនសូវរាប់រកដល់គេប៉ុន្មានដែរ ។

យើងទាំងអស់គេត្រូវតែពិសោធនូវសេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់ ។ តែគួរឲ្យសោកស្ដាយណាស់ដែលកុមារពិការទាំងឡាយបែរជាទទួលនូវការមិនអើពើ និងមិនទទួលបាននូវភាពកក់ក្ដៅនៃក្ដីស្រឡាញ់តាំងពីនៅតូចមកម្ល៉េះ ។ ដូច្នេះក្រុមជំនុំត្រូវតែឆ្លើយតប ត្រូវតែផ្ដល់ជំរើសដ៏ល្អមួយ និងផ្ដល់បរិយាកាសដែលប្រកបដោយសេចក្ដីស្រឡាញ់ ។ ប្រាកដជាមានការឈឺចាប់មែនហើយចំពោះការដែលមាន "លក្ខណៈខុសពីគេឯងនោះ" ប៉ុន្តែនៅក្នុងអាណាចក្ររបស់ព្រះមានលក្ខណៈផ្ទុយពីនោះ "ដើម្បីនឹងធ្វើឲ្យអ្នកប្រាជ្ញមានសេចក្ដីខ្មាសវិញ ទ្រង់បានរើសពួកកំសោយនៅលោកីយ៍នេះ ដើម្បីនឹងធ្វើឲ្យពួកខ្លាំងពូកែមានសេចក្ដីខ្មាស"[៨] ។

តួអង្គសំខាន់ខ្លះដូចជាលោកម៉ូសេ[៩] និង លោកប៉ូល[១០] មានភាពទន់ខ្សោយ ។ លោក *ម៉េល ហាន* មកពី "សកម្មភាពក្រុមជំនុំចំពោះភាពពិការ" បានបង្ហាញការណែនាំឲ្យយោបល់ថា "មិនអាចករណីបែបនេះកើតឡើងឡើយ បើព្រះជាម្ចាស់មិនឲ្យមានអ្នកទន់ខ្សោយនៅជុំវិញយើងទេនោះ" ។ ទាំងលោកម៉ូសេ និងលោកប៉ូល ព្រះជាម្ចាស់បានជ្រើសរើសជាពិសេសសំរាប់ការងារផ្សាយព្រះរាជសាររបស់ព្រះអង្គ តែទោះជាយ៉ាងណាក៏ដោយព្រះជាម្ចាស់បង្ហាញឲ្យដឹងពីលោកម៉ូសេដែលទាក់ទងពីសំដីជំឡាន់របស់គាត់

[៨] *១កូរិន. ១:២៨-៣១*

[៩] *និក្ខមនំ ៤:១០-១១*

[១០] Faith Bowers, 1996.

"អញបង្កើតឯងមកដូច្នេះឯង" ។ សេចក្តីបង្រៀនរបស់លោកប៉ូលដែលប្រៀបធៀបពីរូបកាយនៅក្នុងបទគម្ពីរ១កូរិនថូស ១២ បានបង្ហាញឲ្យឃើញថាព្រះជាម្ចាស់បង្កើតមនុស្សទាំងអស់(រួមទាំងកុមារដែលមានការលូតលាស់មិនប្រក្រតីផង) មកដើម្បីបង្ហាញពីការពឹងពាក់អាស្រ័យគ្នាទៅវិញទៅមករបស់មនុស្ស (ជាជាងពឹងលើខ្លួនឯង ឬក៏គ្រាន់តែសន្មត់លើភាពជាម្ចាស់លើខ្លួនឯង) ។

ភាពពិការមិនមែនដោយសារតែអំពើបាប ឬមកពីកុមារ ឬឪពុកម្តាយរបស់ក្មេងនោះខ្វះជំនឿនោះទេ ។ ប្រហែលអាចជាការបើកសម្តែងយ៉ាងអស្ចារ្យពីព្រះជាម្ចាស់ចំពោះកុមារដែលមានភាពមិនប្រក្រតីនោះ ដើម្បីឲ្យដឹងថាព្រះជាម្ចាស់ស្រឡាញ់ដល់គេដោយឥតលក្ខខ័ណ្ឌ ព្រមទាំងឲ្យគេដឹងទៀតថា គេអាចចូលទៅរកព្រះអង្គដោយសេចក្តីអធិស្ឋាន និងថ្វាយបង្គំព្រះអង្គដូចជាមនុស្សដទៃទៀតដែរ ។ ព្រះអម្ចាស់មានព្រះបន្ទូលថា៖ "អញបានហៅចំឈ្មោះឯង ឯងជារបស់ផងអញ" (អេសាយ ៤៣:១) ។[១១]

ព្រះយេស៊ូផ្ទាល់បានសម្រេចព្រះហឫទ័យបន្សល់ទុកស្លាកស្នាមនៃការជាប់ឆ្កាងបន្ទាប់ពីព្រះអង្គរស់ពីសុគតឡើងវិញ នៅក្នុងឋានៈដែលព្រះអង្គជាព្រះដែលមានរូបកាយល្អឥតខ្ចោះនោះ ព្រះអង្គមិនគួរទុកស្លាកស្នាមលើអង្គទ្រង់ឡើយ។ តែផ្ទុយទៅវិញព្រះយេស៊ូត្រាស់ហៅពួកសិស្សរបស់ព្រះអង្គឲ្យមកស្ទាបស្នាមរបួសដែលនៅជិតដាមលើអង្គទ្រង់ទៅវិញ ។ ការធ្វើបែបនោះ គឺព្រះអង្គកំពុង "ជំរុញលើកទឹកចិត្តដល់ពួកអ្នកដែលគ្មានភាពពិការឲ្យឈប់រើសអើងដល់ពួកអ្នកដែលមានភាពពិការនោះ"[១២] ។ "យើងទាំងអស់គ្នាបានជាដោយស្នាមរបួសនៅលើរូបអង្គទ្រង់" ។[១៣]

---

[១១] Faith Bowers, 1996.

[១២] Taylor & McCloughry, 1998.

[១៣] *អេសាយ ៥៣:៥*

ក្រុមជំនុំសម័យគម្ពីរសញ្ញាថ្មីបន្តនូវការជំរុញលើកទឹកចិត្តឲ្យចូលទៅជិតពួកអ្នកដែលតាមធម្មតាគេមិនចូលចិត្តនឹងពួកនោះ ហើយថែមទាំងជំរុញលើកទឹកចិត្តឲ្យស្រឡាញ់ពួកគេដោយឥតលក្ខខ័ណ្ឌទៀតផង ។ រឿងសាសន៍សាម៉ារីដ៏សប្បុរស នោះគឺជាគំរូមួយដ៏ល្អសំរាប់យើង ។ *ជីន វ៉ែនីយេ* (Jean Vannier) បានស្ថាបនាសហគមន៍មួយឈ្មោះថា *ឡាកស៍* (L' Arche) ដែលមានទាំងមនុស្សពិការ និងមនុស្សមិនពិការរស់នៅជាមួយគ្នាក្នុងសហគមន៍ ។ *វ៉ែនីយេ* បានសង្កេតឃើញថា "ការស្រឡាញ់អ្នកណាម្នាក់មិនមែនត្រូវធ្វើអ្វីសម្រាប់គេនោះឡើយ ប៉ុន្តែត្រូវឲ្យគេដឹងថាគេមានតម្លៃទៅវិញទេ ទើបបញ្ជាក់ថាយើងស្រឡាញ់គេ" ។ គឺជាការសំខាន់ណាស់ដែលកុមារមានភាពពិការមិនត្រូវបានគេមើលឃើញថា គេកើតឡើងមកនេះគ្រាន់តែធ្វើឲ្យអ្នកដទៃមានឱកាសបំរើព្រះឲ្យបានកាន់តែប្រសើរឡើងនោះប៉ុណ្ណោះទេ ។ ការយល់បែបនេះអាចបញ្ជាក់ឲ្យឃើញថា អ្នកបំរើនោះហាក់ដូចជាមានតម្លៃសំខាន់ជាងអ្នកដែលទទួលនូវការបំរើពីគេទៅវិញ ។

## តើអ្វីទៅជាវិធីសាស្ត្រដ៏ប្រសើរបំផុត ដើម្បីជួយដល់កុមារដែលមានភាពពិការ?

ប្រវត្តិសាស្ត្របានបង្ហាញឲ្យដឹងថា កុមារដែលមានភាពពិការ ជាពិសេសចំពោះអ្នកដែលមានបញ្ហាផ្នែក "សតិបញ្ញាល្ងួតលាស់មិនធម្មតា" ត្រូវបានគេយកទៅរក្សាទុកនៅក្នុងជំរំដ៏ធំមួយកន្លែង ។ ឧទាហរណ៍ នៅទីក្រុង *ឡុនដុន* មានមន្ទីរពេទ្យសំរាប់ថែរក្សាមនុស្សមានបញ្ហាផ្នែកសតិបញ្ញាអន់ថយជាច្រើនកន្លែងនៅពទ្ធជុំវិញ ។ ជំរើសដ៏ល្អដែលកុមារអាចទទួលបាននោះគឺគេដាក់កុមារទាំងនោះនៅក្នុងស្ថាប័នពិសេសមួយ ដូចជាសាលារៀនសំរាប់កុមារពិការភ្នែក ។ គំនិតយោបល់ទាំងនេះត្រូវគេចម្លងតគ្នាមកដល់ប្រទេសដែលកំពុងអភិវឌ្ឍ ហេតុដូច្នេះបានជាមកទល់ពេលនេះរដ្ឋាភិបាល និងអង្គការ

ត្រីស្តេបរិស័ទនានាមើលឃើញថាស្ថាប័នទាំងនេះជាមធ្យោបាយសំរាប់ដោះស្រាយជាមួយ "បញ្ហា" នៃការមានភាពពិការនេះ ។

តែទោះជាយ៉ាងណាក៏ដោយ រឿងរ៉ាវទាំងឡាយនោះចាប់ផ្តើមផ្លាស់ប្តូរបន្តិចម្តងៗ ។ ការស្រាវជ្រាវរបស់កម្មវិធីអភិវឌ្ឍន៍របស់អង្គការសហប្រជាជាតិបង្ហាញឲ្យឃើញថា[៩៤] សេវាកម្មដែលគេបញ្ជូនឲ្យទៅជួយដល់មនុស្សដែលមានភាពពិការនៅក្នុងបណ្តាប្រទេសដែលមិនទាន់មានការអភិវឌ្ឍន៍នៅឡើយ នោះនឹងអាចទទួលនូវអត្ថប្រយោជន៍ពីការរួមបញ្ចូលគោលការណ៍ដូចខាងក្រោមនេះ ៖

១. ធ្វើឲ្យគ្រួសារ និងសហគមន៍ចូលរួមគាំទ្រជាមួយគ្នា ។
២. ផ្តល់កម្លាំងចិត្តដល់អ្នកដែលមានភាវពិការ ឲ្យគេយល់ពីតម្លៃរបស់ខ្លួនគេផ្ទាល់ ។
៣. ផ្លាស់ប្តូរឥរិយាបថរបស់មនុស្សដែលធ្លាប់មានចំពោះអ្នកដែលមានភាពពិការ ។

គោលការណ៍ទាំងនេះជាកញ្ចក់ឆ្លុះបញ្ចាំងពីគោលការណ៍គាំទ្ររបស់គ្រួសារនៅក្នុងព្រះគម្ពីរដែលជួយគាំទ្រ និងលើកទឹកចិត្តដល់អ្នកដែលងាយទទួលនូវការរងគ្រោះ និងផ្តល់ការស្នាក់អាស្រ័យនៅដោយឥតមានការប្រកាន់ពណ៌សម្បុរនោះឡើយចំពោះអ្នកដែលមិនមែនដូចជារូបយើងនោះ ។

ការនេះគេសង្ឃឹមថា មានការស្ថាបនាសហគមន៍បានយ៉ាងល្អនឹងជួយផ្តល់សមត្ថភាពគ្រួសារជាច្រើន ដើម្បីថែរក្សាកូនដែលមានភាពពិការឲ្យរស់នៅជាមួយពួកគេផ្ទាល់ដោយធ្វើការរួមគ្នាជាសហគមន៍ ក្នុងការគាំទ្រគ្រប់មធ្យោបាយដើម្បីធ្វើការជាមួយកុមារដែលមានបញ្ហាបែបនោះ ។ ដោយធ្វើការងារបែបនោះ ពួកគេអាចមានបទពិសោធន៍ពីការទទួលផលប្រយោជន៍ និងក្តីអំណរ ព្រមទាំងទុក្ខលំបាក និងសេចក្តីបារម្ភជាមួយគ្នាផងចំពោះការបីបាច់

[៩៤] Helander, 1993.

ថែទាំកូនដែលមានភាពពិការ ។ មិនថាឡើយកុមារនោះអាចស្នាក់នៅឯផ្ទះ ឬមិនអាចនោះទេ គឺវាអាស្រ័យលើស្ថានភាពសេដ្ឋកិច្ចគ្រួសាររបស់គេ សេវាថែទាំនៅក្នុងសហគមន៍ដែលមនុស្សទាំងនោះគេបានដឹង ហើយជួនកាលវាអាស្រ័យលើអ្វីដែលវេជ្ជបណ្ឌិត ឬឆ្មបបានប្រាប់ដល់គ្រួសារនោះនៅពេលដែលទារកនោះកើតមក ។

ប្រហែលជាវាអាចអាស្រ័យលើទំហំនៃភាពទន់ខ្សោយរបស់គេ និងអាស្រ័យលើការទទួលខុសត្រូវថែទាំពីសំណាក់ បង ជីដូនជីតា ឬមនុស្សពេញវ័យដទៃទៀតនៅក្នុងគ្រួសារនោះទេវិញទេ ។ អ្នកដែលទទួលនូវការថែទាំជាសំខាន់នោះ គឺសាច់ញាតិជិតៗរបស់កុមារនោះ ។ សមត្ថភាពនៃការងារថែទាំដល់កុមារពិការនោះ គឺវាអាស្រ័យលើការងាររបស់គ្រួសារនោះ ដូចជាការងារផ្ទះ សេចក្តីត្រូវការផ្នែកការរៀនសូត្រជាដើម ។ ពួកគេប្រហែលជាត្រូវការការគាំទ្រពីសហគមន៍ និង កន្លែងដែលមានក្រុមជំនុំគ្រីស្ទបរិស័ទនៅក្នុងសហគមន៍របស់គេនោះ ។

មធ្យោបាយដទៃទៀតចំពោះបញ្ហានេះ អាចធ្វើទៅបានតាមរយៈការតស៊ូមតិដែលទាក់ទងទៅនឹងឥរិយាបថរបស់សាធារណៈជន ការថែទាំសុខភាព ការអប់រំ និងសេវាសង្គម/ក្រុមអ្នកដែលមានវិជ្ជាជីវៈដោយស្មគ្រ័ចិត្តដែលតាមពិតទៅឪពុកម្តាយត្រូវតែទទួលនូវការយល់ដឹងយ៉ាងច្បាស់ពីរឿងនេះ គឺត្រូវមើលឲ្យឃើញពីសមត្ថភាពរបស់កូននោះវិញ ជាជាងមើលឃើញតែភាពពិការរបស់គេ ។ ទោះបីជាយ៉ាងណាក៏ដោយ តាមធម្មតាឥរិយាបថទាំងឡាយនោះ ត្រូវតែចាប់ផ្តើមឡើងចេញពីយើងផ្ទាល់រួមជាមួយនឹងក្រុមជំនុំផង ។ តើយើងស្វាគមន៍ជនពិការឲ្យចូលរួមជាមួយយើងនៅក្នុងក្រុមជំនុំយ៉ាងកក់ក្តៅ ឬយើងមិនអើពើដាក់គេ និងប្រព្រឹត្តមិនសមរម្យតាមទម្លាប់ដែលយើងធ្លាប់ធ្វើពីមុនមកនោះ ឬយ៉ាងណា? យើងត្រូវតែទូលសូមឲ្យព្រះយេស៊ូជួយដោះឲ្យរួចនូវសេចក្តីភ័យខ្លាច និងការរើសអើងទាំងឡាយដែលយើងមាន ។

## References

Bowers, Faith. *Treat with Special Honour: People with Learning Difficulties in the Life of the Church*. Oxfordshire: Baptist House, 1996.

Hartley, Sally, and Sheilah Wirz. "Investing Models of Service Delivery for People with Communication Disorders in Anglophone Africa," *Work in Progress*, vol. 3. NHCSS. University of London, 1993.

Helander, E. *Prejudice and Dignity: an Introduction to Community Based Rehabilitation*. New York: UNDP, 1993.

Horne, Mel. "Did God Create Impairment? A Bible Study." *All People: the Magazine of Church Action on Disability* (1998).

Sidebotham, P. *Child Development and Disability*. Unpublished, 1998.

Taylor, M., and McLoughry. "A Disabled God." *Third Way* (October 1998).

Through the Roof "Roofbreaker Guides." *Guidelines for Involving Children with Disabilities into Church Life*. UK: Through the Roof Ministries, 1999.

Wirz, Shelagh, and Winyard. *Hearing and Communication Disorders*. London: Macmillan, 1993.

Young, F. *Encounter with Mystery: Reflections on L'Arche and Living with Disability*. Darton, Longman & Todd, 1997.
*A group of essays by theologians after visiting the L'Arche communities.*

## Key Resources

Coleridge, Peter. *Disability, Liberation and Development*. Oxford: Oxfam Publications, 1993.

Eiesland, Nancy L. *The Disabled God: Towards a Libertory Theology of Disability*. Nashville: Abingdon, 1994.
*Looks at Jesus being "disabled" on the cross, and then at the meeting with the disciples after the resurrection.*

Ingstad, B. and Whyte, SR, ed. *Disability and Culture*. Berkeley: University of California Press, 1995.

Potter D. *Am I Beautiful . . . or What?* Oxford: Scripture Union, 1998.
*Information about learning disability, training material for individual or group use, essential guidance on running meetings for people with learning difficulties, a course of teaching materials for such meetings.*

Ransom, Judy Griffith. *The Courage to Care: Seven Families Touched by Disability and Congregational Caring.* Nashville: Upper Room Books, 1994.
*Chronicles the stories of people whose lives were dramatically changed by the caring of congregations, friends, and family. Important book for churches wanting to understand why and how caring is part of what it means to be a community and to offer hospitality.*

Webb-Mitchell, Brett. *God Plays Piano Too: The Spiritual Lives of Disabled Children.* N.p.: Crossroads, 1993.
*The stories of children with disabilities who had wonderful, but often hidden, gifts. Webb-Mitchell shows the church how to welcome and receive the gifts and "reveals the hidden wholeness that lies beneath the broken surface of all our lives."*

Webb-Mitchell, Brett. *Unexpected Guests at God's Banquet: Welcoming People with Disabilities into the Church.* N.p.: Crossroads, 1994.
*This is concerned with learning how to welcome people with disabilities and why doing so is essential for the church. "For it is only when we learn how to be with those who are different from us, and learn how to accept the love of God that we all need, that we will be able to sustain a community that is capable of worshipping God."*

Werner, David. *Disabled Village Children: A Guide for Community Health Workers, Rehabilitation Workers and Families.* Palo Alto, California: Hesperian Foundation, 1994.

____________. *Nothing about Us Without Us.* Palo Alto, California: Hesperian Foundation, 1998.
*Explores innovative aids that can be made at low cost. It also considers how people with disabilities and those without them can learn together.*

**Christian Resource Organizations**

Church Action on Disability (CHAD), 50 Scrutton Street, London EC2A 4PH, UK. Tel: 44 171 452 2085; Fax: +44 171 452 2001; email: mlpcfm@aol.com
*Education and awareness raising of disability in churches. Produce access audit, resource pack, study pack and youth pack. Quarterly magazine* All people.

Deaf Christian Network, P.O. Box 212, Doncaster, South Yorkshire, DN2 5XA, UK Tel: +44 1302 369684 (Voice/Minicom); Fax: +44 1302 739660
*Resources for those working with profoundly deaf people.*

Disability Awareness and A Healing Ministry (The Rev. Dr. Nancy Lane). P. O. Box 274, Lansing, NY 14882-0274, USA. Tel: 607-533-4083 Email: nlane1@twcny.rr.com
*Resources for those working with women who have been abused or sexually exploited, including women with disabilities.*

Evangelical Alliance Disability Forum, 186 Kennington Park Road, London SE11 4BT, UK Tel: +44 171 207 2100; Fax: +44 171 207 2150
*Umbrella organization for Christian disability organizations.*

SPRED, Special Religious Education Department (Roman Catholic Church), c/o Brothers of Charity Services, Lissieux Hall, Whittle-le-Woods, Chorley, Lancashire PR6 7DX, UK. Tel: 44 1257 266 311
*Looks at spiritual needs of people with learning difficulties and provides suitable study and worship material.*

Through the Roof, P.O. Box 178, Cobham, Surrey, KT11 1YN Tel/Fax: +44 1932 866333; email: info@throughtheroof.org website: www.jafministries.com/throughtheroof
*The disability outreach of Joni Erickson Tada. Produces a series of one-page "Roofbreaker Guides" about including people with different types of disabilities in the church.*

Torch Trust for the Blind, Torch House, Hallaton, Market Harborough, Leicestershire, LE16 8UJ, UK. Tel: +44 1858 555301; Fax: +44 1858 555371
*Christian resources for blind and visually impaired people.*

HONEYCOMB 3/2 (April 2002): 75–83



# An Unexpectedly Precious Gift

*Susan CALDWELL*

Little did I know how God had been preparing me for his birth. Little did we know what this child would mean to our family.

Joshua is our fourth and youngest child, born over ten years ago with a medical problem known as Down syndrome. This condition affects him both physically and mentally. Shortly after Joshua's birth a doctor told us, "Your son will learn to do many of the things other children do ... but it will take him *longer*." It took him much longer than most children to learn to roll over, sit up, stand up, and walk. But eventually he did. Those were days of great rejoicing in our home!

Though now ten years old, Joshua looks and acts like a six-year-old and is in first grade. He is learning to read, write, and do arithmetic, but will never learn as quickly or as much as the average child.

Our story about Joshua began two years before he was born when I was pregnant with his brother, Caleb. In my home country, people commonly ask a pregnant woman, "What do you want—a boy or a girl?" A typical reply is, "I don't care, just as long as the baby is healthy." But I have never been able to say those words. First of all, I have a brother who has never been able to walk. Second, I knew that the God who made us and loves us has not *promised* that each child he

gives will be problem-free, either physically, mentally, emotionally, or spiritually.

Early in my pregnancy with Caleb, a blood test suggested I might be carrying a child with Down syndrome. For the next six months I fought with God in my heart. Like everyone else, I *wanted* a normal child, *not* one with Down syndrome. Only a few days before Caleb's birth did I experience a change of heart. While walking along the ocean near our home, the thought suddenly came to me, "If this child has some kind of problem, he *needs* me." My thoughts had turned from what *I* wanted to the needs of our child, and acceptance washed over my heart like the ocean waves sweeping over the sand before me. The fight was over. God won, and great was my joy. Not long after, Caleb was born, perfectly healthy.

While pregnant with Joshua two years later I refused the special blood tests, wanting to enjoy the pregnancy. And I did. How unexpectedly came the news only minutes after his birth: "He has Down syndrome." I could see in my mind a book on a shelf, once read. Taking the book in my hands, as it were, I opened it to the chapter and lesson learned two years earlier: This baby *needs* me. Our Father in Heaven had prepared me for his coming.

The morning after Joshua's birth, my husband Darrell came into the hospital room with a story. Our oldest son Luke, then nine years old, had asked his father on the way to school, "Dad, if God were to say to you, 'Which would you rather have—a child like Joshua or a normal child?' What would you say?"

Darrell's response: "What would you say, Luke?"

"I would say to God," Luke replied, 'Whatever *you* want, that's what *I* want."

Do you know what those words were to me? They were *just* what I needed to hear. No, more than that—they were just what my response needed to be: "Whatever *you* want, that's what *I* want." Joshua, like every child, was a gift from God,[1] and God was enabling us to accept his gift.

---

[1]Ps 127:3–5.

Still, we had to endure a "season" of grief and disappointment. It was as if the child we had been hoping for had died—we needed time to grieve the loss of that child. It was kind of like going through a storm that lasted for a while. Eventually, the storm passed, the sky cleared, and the sun shone once again.

Accepting the circumstances that God brought into our lives did not occur in a single moment, but over a long period of time. Many times God used his word to answer some of the deep questions of our hearts and to teach us truths that have instructed and guided us about having a child with special needs.

We have learned that God *takes responsibility* for how Joshua was made. One day while reading the story of Moses at the burning bush, I was struck with God's words to him: "Who gave man his mouth? Who makes him deaf or mute? Who gives him sight or makes him blind? Is it not I, Yahweh?"

Can you believe it? God was unashamedly taking responsibility for children who are born blind, deaf, and mute! It seemed reasonable to draw from that passage the truth that God was also taking responsibility for the way Joshua was formed in my womb. I cannot understand this. I only know that God can *never* be accused of doing wrong,[2] and that his will for us is "good, pleasing, and perfect."[3]

We also believe that there is *purpose* in Joshua's life. One day I read a question Jesus' disciples asked him about a certain blind man: "Who sinned, this man or his parents, that he was born blind?"

His disciples believed, like the people of that day, that there was a direct relationship between the man's or his parents' sin and this man's blindness. Jesus' answer must have surprised them: "Neither this man nor his parents sinned, but this happened so that *the work of God might be displayed in his life.*"

What wonderful news for that man and his family! The man's blindness was not a punishment for wrongdoing; instead, it was an opportunity for the work of God to be seen in his life. Likewise, there

---

[2]Deut 32:4.

[3]Rom 12:2.

is purpose in Joshua's having physical and mental problems—"that the work of God might be displayed in his life."

One way we have seen the work of God displayed in his life is in his personality and character. For example, he freely expresses *praise* to God. Sometimes while riding along on a moto, in the car, or playing at home, Joshua sings unaware and not caring that others may be watching and listening, and not attempting to draw attention to himself (though like every child, he is quite capable of doing that, too!). One day while walking along a road he sang over and over again, in a loud voice, "Oh the blood of Jesus, oh the blood of Jesus, it washes white as snow." Now there is a message that needs to be heard! The psalmist says, "From the lips of infants and children you have ordained praise."[4]

Joshua has a simple but strong *trust* in Jesus. One day last summer we were climbing a long, steep set of wooden stairs in the country. Joshua was getting tired, but we still had a long way to go. He started saying over and over, "Come on, Jesus; come on, Jesus...." until finally we reached the top. And then he burst into a heart-felt, "Praise the Lord!"

Another way we see the work of God in his life is through his *compassion* for people. One day while playing alone in our yard, he noticed a boy leading a blind man down our dirt road. Joshua ran to our bedroom, grabbed a twenty-dollar bill from our desk drawer (without permission) and ran to the front gate calling after them, "Boy! Boy!" His heart was touched by their need.

He is also very *patient*—both with himself and with others. His speech is not so clear as the normal child, and sometimes I cannot understand what he is saying. I may ask him again and again to repeat it, or to explain to me using other words. Joshua never shows impatience with this process. He keeps at it until I understand. I wish I were more like he.

He is very *friendly, accepting, and loving.* While riding by motodope on a Phnom Penh street, Joshua may call out a friendly, "Hello!" to some stranger. People are *attracted* to one whom they

---

[4]Ps 8:2.

sense loves and accepts them. Yes, he feels and expresses anger like the rest of us, but he is also very quick to forgive. These are some of the gifts that Joshua brings to the human family. And these are some of the ways in which, as different as he is from what we think of as normal, "the work of God [is displayed] in his life."

Over the years, on many occasions, God has shown his protection over this child who does not understand danger as well as other children. We have always had to be very careful about making sure that our home (and wherever else he may be) is a safe place for him.

In 1997 he found his way to the peak of a villa roof in Phnom Penh. Thankfully, he was discovered by another child and rescued, unhurt, by our oldest son. The message God communicated to my heart after that frightening experience was: "I am watching over Joshua." Is this not also "the work of God displayed in his life"?

In 1999 we were visiting our home country. I remember speaking in a church one Sunday in July about how God had proven his protection of our family. I went on to say with deep conviction, "And even if one of us were to be hurt or killed, *he is still God and we will still trust him.*"

That very afternoon about twenty of us were walking up and down the streets of that city, searching for Joshua. He had wandered away during a backyard picnic. The name of the city is Lynn, and a local proverb warns, "Lynn, Lynn, the city of sin. You don't come out the way you went in." As we searched I remembered what I had so boldly asserted in church that morning, and cried out to God, "Are you going to make me live out those words this very day?"

Thank God, he did not. After what seemed like an eternity, Joshua turned up at the police station. Someone had seen this little boy about to cross a busy street, took his hand, and led him to a safe place ... where his father found him and brought him back to his family.

When my husband came home with Joshua and I took him in my arms, I could not help but cry tears of utter relief. Joshua put his little arms around me and said a tender and heartfelt, "Sorry, Mom." We give glory to God who displays his work in the life of a child whose ability to understand is not as great as most children.

Quite honestly, Joshua's lowered mental ability has been the most difficult thing for me to accept. As I have considered the reason for this over the years, I believe it has to do with society's silent (though loud and clear) message that the mentally retarded are less valuable.

I needed the truths of God's word to battle this lie. Both the creation story in Genesis and the story of salvation throughout the Bible paint a clear picture: Human beings have far greater worth than anything else God has created. Only human beings were made in God's image and have the unique potential to have a relationship with their Creator. It was love for *people* that motivated God to send his son to die for *people*. People have value simply because their Creator has made it so.

Consider all the times Jesus spent healing people with needs in their bodies, minds, and spirits. He obviously did not consider them less valuable. He stopped, he noticed, he took the time to care for them. The message? People mattered to Jesus. And people with needs touched his heart.

Children also touched his heart. Although his disciples considered Jesus' time far too valuable to squander on little ones, Jesus made it perfectly clear that to him they mattered a great deal. "Let the children come to me, and do not hinder them, for the kingdom of God belongs to such as these."[5]

Joshua happens to be a child who is mentally retarded. But that is not a description of his worth. It just means his potential to learn is not as great as that of most children. However, he *can* learn and, in fact, has gone to school since he was three years old. He has always been in classes with "normal" children. This gives him the much-needed opportunity to be with other children, and gives his classmates the opportunity to relate to a person who is different from them. Of course, going to school also means that his teachers have to adjust their classroom goals and methods to fit Joshua's abilities. But Joshua's teachers have always been eager to do all they can to help him meet his potential. And that is what we see as the most important goal in formally educating him.

---

[5]Matt 19:14.

One of the most important aspects of educating Joshua is helping him learn good behavior. It perhaps takes more patience, persistence, and consistent effort to teach a child such as he how to conduct himself. But I have seen over the years that he can learn good behavior, and he has made much progress in this area. I am very grateful to all of his teachers who have exerted such a positive influence in this area of his life, and have helped us to expect a higher level of good behavior from him.

I remember when Joshua first went to school in Phnom Penh his teacher asked, "What do you do to help Joshua obey?" Thankfully, by that time I had learned that there was one thing Joshua disliked almost more than anything else, and that was a "consequence." Even at his young age he understood well its meaning: Something he would *not* want to experience.

A "consequence" might be having to sit alone for a while, not being allowed to play with a friend or his favorite toys, losing some special sweet cookie or cake after a meal, or not being able to watch television. The most important thing about a "consequence" is that it has to be something he would *not* want to endure. These particular "consequences" are meaningful for Joshua because he is a boy who loves being with people, playing with friends, playing with toys, eating sweets, and watching television.

An effective "consequence" not only has to be an undesired event, but it has to occur soon after the unacceptable behavior. For example, if Joshua is misbehaving *now*, the "consequence" must occur as soon as possible so that he understands the connection between his undesired behavior and the "consequence."

Whenever I say the words, "Joshua, do you want a consequence?" I better have one in mind in case his behavior does not improve. When I first started using this method of correction, I often had to impose a "consequence." It was as if Joshua were saying, "I don't really believe you will do anything that I don't like." Now he believes me and rarely tests me when I ask him the question.

However, he does have a stubborn streak. Occasionally, he acts like a cow that stands still and refuses to budge no matter how hard one tries to move it. In fact, the more one prods the cow, the

more firmly it resists! At such times, the best thing for Joshua is to be alone until his stubborn streak quiets down within him.

Finally, I must be careful not to overuse the "consequence" method. Like cloth that will wear out from constant use, this method of correcting his behavior will no longer be useful if I ask the question too frequently.

Sometimes I have to think about *why* Joshua's behavior is not appropriate on a given occasion. Recently his teacher called me from school at lunchtime. "Joshua and another boy were in the changing room after swimming," she said. "We heard Joshua screaming and ran inside. They had been hitting each other." We never learned from Joshua why he was so angry with the other boy. Joshua only said, "He hit me."

When his doctor heard this story several days later she asked, "Was the other boy a new student?"

Surprised, I replied, "Yes. How did you know?"

"Of course he was a new student," was all she said.

His teacher told me, "When Joshua is saying or doing something the other children know is naughty, his friends who know him well say, 'Don't pay any attention to him.' They understand at their young age that he just wants their attention, so they are making a very wise decision: Ignore him!"

When Joshua has a sudden, unusually strong outburst of improper behavior, I have learned to ask myself, "Is he getting sick?" I have observed this enough times to keep this question in the back of my mind. Of course, Joshua is also capable of becoming angry with another child just like all children. We try to understand the cause of the outburst. In the case of the changing room story, I learned a few days later that he had an ear infection and was, indeed, sick. That may have been the cause of his outburst of anger. And then again, maybe not. Sometimes we just don't know.

We simply do not have all the answers about how to raise this child ... or any of our children for that matter. We pray for God to give us wisdom. He loves to answer that request.[6]

---

[6]Jas 1:5.

We do not know Joshua's potential. God does. He knows his plans for our son.[7] We are filled with hope, not because of what he may accomplish in the eyes of men, but because we believe the words of Jesus: "This happened that the work of God might be displayed in his life."[8]

Now when I think of how I fought with God over receiving a child like Joshua ... well, I smile. He has turned out to be an unexpectedly precious gift. "As for God, His way is perfect."[9] To God be the glory!



---

[7]Jer 29:11.

[8]Jn 9:3.

[9]Ps 18:30.

សំណុំនិកឃុំ ៣/២ (មេសា ២០០២)៖ ៨៤-៩៩



# អំណោយទានដ៏មានតម្លៃ ដែលមិនបានគិតទុកជាមុន

*អ្នកស្រី ស៊ូសាន ខងវែល*

ខ្ញុំបានដឹងតិចតួចណាស់ថាព្រះជាម្ចាស់បានរៀបចំសំរាប់ឲ្យខ្ញុំត្រៀមទទួលនូវកំណើតរបស់កូននោះ ។ ខ្ញុំបានដឹងតិចតួចណាស់ថា តើកូននោះមានអត្ថន័យបែបណាចំពោះគ្រួសារយើង ។

*យ៉ូស្វេ* ជាកូនទីបួន និងជាកូនពៅរបស់យើងដែលបានកើតមកកាលពីជាង១០ឆ្នាំមុន ដោយមានបញ្ហាមួយដែលផ្នែកវេជ្ជសាស្ត្រគេឲ្យឈ្មោះថា Down syndrome (ភាពយឺតយ៉ាវខុសប្រក្រតី) ។ លក្ខណៈមិនប្រក្រតីនេះមានឥទ្ធិពលប៉ះពាល់ដល់កូននោះ ទាំងផ្នែករូបកាយ និងផ្នែកសតិបញ្ញា ។ មិនយូរប៉ុន្មានក្រោយមក វេជ្ជបណ្ឌិតបានប្រាប់យើងថា "កូនរបស់អ្នកនឹងរៀនធ្វើការជាច្រើន ដែលក្មេងដទៃទៀតត្រូវរៀននោះ... ប៉ុន្តែកូននេះនឹងត្រូវចំណាយពេលយូរទើបរៀនធ្វើការទាំងនោះបាន" ។ គឺវាត្រូវចំណាយពេលយូរជាងក្មេងដទៃជាច្រើនទៀត ដើម្បីរៀនក្រឡាប់ អង្គុយ ឈរ និងរៀនដើរ។ ប៉ុន្តែក្រោយមកវាបានមានឆ្លងកាត់ដំណាក់ការទាំងនោះរួច ។ យើងក៏មានថ្ងៃដ៏សប្បាយរីករាយបំផុតនៅក្នុងផ្ទះរបស់យើង!

មកដល់ឥឡូវនេះវាមានអាយុ១០ឆ្នាំហើយ *យ៉ូស្វេ* មើលទៅការប្រព្រឹត្តិរបស់វាហាក់បីដូចជាកូនក្មេងដែលមានអាយុ៦ឆ្នាំ និងដូចជាក្មេងដែលរៀននៅថ្នាក់ទីមួយ ។ វារៀនអាន សរសេរ និងធ្វើគណិតសាស្ត្រ ប៉ុន្តែវារៀនមិនលឿន ឬមិនបានច្រើនដូចក្មេងដទៃឡើយ ។

រឿងរបស់យើងស្តីអំពី*យ៉ូស្វេ*ចាប់ផ្តើមឡើងកាលពី ២ឆ្នាំ មុនពេលដែល*យ៉ូស្វេ*កើតមកនោះ គឺនៅពេលដែលបងរបស់វាឈ្មោះ *កាលែប* នៅក្នុងពោះ ។ នៅក្នុងប្រទេសរបស់ខ្ញុំ តាមធម្មតាគេតែងសួរដល់ស្ត្រីមានផ្ទៃពោះថា "តើអ្នកចង់បានកូនប្រុសឬកូនស្រី?" ចម្លើយដែលជាទូទៅ នោះគឺថា "ខ្ញុំមិនខ្វល់ឡើយ ឲ្យតែកូននោះមានសុខភាពល្អបានហើយ" ។ ប៉ុន្តែខ្ញុំមិនអាចនិយាយពាក្យទាំងឡាយនោះបានឡើយ ។ ដំបូងបង្អស់នោះ ខ្ញុំមានប្អូនប្រុសម្នាក់ដែលពិការមិនអាចដើរបានឡើយ ។ ទីពីរ ខ្ញុំបានដឹងថាព្រះជាម្ចាស់ដែលព្រះអង្គបង្កើតយើងមក និងស្រឡាញ់យើងនោះ មិនដែលសន្យាថា គ្រប់ក្មេងដែលព្រះអង្គបង្កើតមកនោះ សុទ្ធតែគ្មានបញ្ហានោះឡើយ គឺមានន័យថា អាចមានបញ្ហាផ្នែករូបកាយ ផ្នែកសតិបញ្ញា ផ្នែកផ្លូវចិត្ត ឬផ្នែកខាងវិញ្ញាណ ។

នៅពេលដែលខ្ញុំមានផ្ទៃពោះកូនខ្ញុំឈ្មោះ *កាលែប* ប៉ុន្មានខែដំបូង ការពិនិត្យឈាមបានបង្ហាញថា ខ្ញុំអាចកំពុងតែមានកូនដែលមានលក្ខណៈមិនប្រក្រតី ។ នៅក្នុងរយៈពេល៦ខែបន្ទាប់ពីពេលនោះមក ខ្ញុំបានឈ្លោះជាមួយព្រះជាម្ចាស់នៅក្នុងចិត្តរបស់ខ្ញុំ ។ ខ្ញុំក៏ដូចជាមនុស្សគ្រប់រូបដទៃទៀតដែរ ខ្ញុំចង់បានកូនដែលគ្រប់លក្ខណៈធម្មតា មិនមែនចង់បានកូនដែលមានលក្ខណៈមិនប្រក្រតីនោះឡើយ ។ ប៉ុន្មានថ្ងៃមុនថ្ងៃដែលត្រូវប្រសូតកូនរបស់ខ្ញុំឈ្មោះ កាលែប ខ្ញុំមានអារម្មណ៍នៅក្នុងខ្លួនថាខ្ញុំមានការផ្លាស់ប្តូរនៅក្នុងចិត្ត ។ នៅក្នុងខណៈពេលដែលខ្ញុំកំពុងតែដើរនៅតាមបណ្តោយឆ្នេរសមុទ្រនៅជិតផ្ទះរបស់យើង រំពេចនោះគំនិតមួយផុសនៅក្នុងចិត្តរបស់ខ្ញុំ "បើកូននេះមានបញ្ហាខ្លះៗនោះ គឺកូននេះត្រូវការខ្ញុំ" ។ គំនិតខ្ញុំប្តូរពីអ្វីដែលខ្ញុំចង់បានទៅជា

សេចក្ដីត្រូវការរបស់កូនយើងទៅវិញ ហើយការព្រមទទួលគំនិតនោះបាន លាងចិត្តរបស់ខ្ញុំប្រៀបដូចជារលកសមុទ្រដែលកំពុងបក់បោកលាងឆ្នេរខ្សាច់ នៅចំពោះមុខខ្ញុំដែរ ។ ការមានអារម្មណ៍ច្របូកច្របល់នៅក្នុងចិត្តរបស់ខ្ញុំបាន កន្លងផុតទៅ ។ ព្រះជាម្ចាស់ទទួលជ័យជម្នះ ហើយការអស្ចារ្យនោះគឺជាក្ដី អំណររបស់ខ្ញុំ ។ មិនយូរប៉ុន្មានបន្ទាប់ពី *កាលែប* កើតមកនោះយើងឃើញថា កូននោះមានសុខភាពល្អបំផុត ។

លុះដល់ពីរឆ្នាំក្រោយមកនៅពេលដែលខ្ញុំមានទម្ងន់ *យ៉ូស្វេ* ខ្ញុំ បដិសេធមិនព្រមទៅធ្វើពិសោធឈាមដើម្បីពិនិត្យថា តើកូននៅក្នុងផ្ទៃមាន លក្ខណៈបែបណា ព្រោះខ្ញុំចង់បាននូវអារម្មណ៍ស្ងប់សុខនៅពេលដែលខ្ញុំមាន ផ្ទៃពោះ ។ ខ្ញុំក៏សម្រេចធ្វើបែបនោះមែន ។ តែប៉ុន្មាននាទីក្រោយពីកូននោះ កើតមកមានដំណឹងមួយដែលស្មានមិនដល់បានឮមកដល់ខ្ញុំថា៖ "កូននោះ មានបញ្ហាគឺមានលក្ខណៈយឺតយ៉ាវខុសប្រក្រតី" ។ ខ្ញុំអាចស្រមៃនឹកឃើញនៅ ក្នុងគំនិតរបស់ខ្ញុំនូវសៀវភៅមួយក្បាលនៅលើធ្នើរ ដែលខ្ញុំធ្លាប់អានម្ដងរួចមក ហើយនោះ ។ ខ្ញុំបានយកសៀវភៅមកកាន់ជាប់នៅនឹងដៃរបស់ខ្ញុំដូចដែលខ្ញុំ ធ្លាប់កាន់នៅដៃពីមុន ខ្ញុំបានបើកទៅជំពូក និងមេរៀនដែលខ្ញុំបានរៀនកាលពី ២ឆ្នាំមុនដែលមានន័យថា៖ ទារកតូចនេះត្រូវការខ្ញុំ ។ ព្រះបិតារបស់យើងដែល គង់នៅឯស្ថានសួគ៌ព្រះអង្គបានរៀបចំឲ្យខ្ញុំទទួលយកការពិតនេះ ។

នៅពេលព្រឹកបន្ទាប់ពី *យ៉ូស្វេ* កើតមកនោះ *ដារ៉ែល* ជាប្ដីរបស់ខ្ញុំបាន មកក្នុងបន្ទប់នៅមន្ទីរពេទ្យដោយយករឿងមកនិយាយប្រាប់ខ្ញុំ ។ កូនប្រុស ច្បងរបស់យើង ឈ្មោះ *លូកា* មានអាយុទើបតែ៩ឆ្នាំ នៅតាមផ្លូវទៅសាលា រៀនវាបានសួរទៅឪពុករបស់គេថា "ប៉ា បើព្រះជាម្ចាស់មានបន្ទូលមកប៉ាថា៖ តើកូនមួយណាដែលឯងចង់បាន គឺកូនដូចជា *យ៉ូស្វេ* ឬជាកូនដែលមាន លក្ខណៈធម្មតា? តើប៉ានិយាយយ៉ាងម៉េចទៅ?"

*ដារ៉ែល* ឆ្លើយទៅ *លូកា* ថា៖ "តើកូននឹងឆ្លើយទៅព្រះវិញដូចម្ដេចទៅ *លូកា?*"

*លូកា* ឆ្លើយថា៖ "ខ្ញុំនឹងនិយាយទៅព្រះជាម្ចាស់វិញថា អ្វីក៏ដោយឲ្យតែព្រះអង្គសព្វព្រះហឫទ័យ នោះទូលបង្គំក៏នឹងចង់បានតាមនោះដែរ?" ។

តើលោកអ្នកដឹងទេថា ពាក្យទាំងនោះហើយដែលជាពាក្យសំរាប់ខ្ញុំ? ពាក្យទាំងនោះ គឺជាអ្វីដែលខ្ញុំជាត្រូវការពួ ។ ខ្ញុំមិនត្រូវការអ្វីលើសពីនោះឡើយ ។ ពាក្យនោះគឺជាអ្វីដែលខ្ញុំត្រូវការនៅក្នុងការឆ្លើយតបរបស់ខ្ញុំគឺ៖ "អ្វីក៏ដោយឲ្យតែព្រះអង្គសព្វព្រះហឫទ័យ នោះហើយជាអ្វីដែលខ្ញុំម្ចាស់ត្រូវការ"។ *យ៉ូស្វេ* ដូចជាក្មេងទូទៅដែរ គឺគេជាអំណោយទានមកពីព្រះជាម្ចាស់[១] ហើយព្រះជាម្ចាស់ផ្ដល់ឲ្យយើងអាចទទួលយកអំណោយទានរបស់ព្រះអង្គបាន ។

យើងនៅតែត្រូវទទួលរងនូវការ"រងទុក្ខព្រួយ" និងការខកចិត្តយូរៗម្ដងដែរ ។ គឺវាហាក់បីដូចជាកូនដែលយើងសង្ឃឹមចង់បាននោះ បានស្លាប់បាត់ទៅហើយ គឺបានសេចក្ដីថាយើងត្រូវការពេលវេលាដើម្បីសោកសង្រេងចំពោះការបាត់បង់កូននោះ ។ ចំពោះការនោះគឺវាហាក់បីដូចជាយើងកំពុងឆ្លងកាត់ព្យុះបក់បោកយ៉ាងខ្លាំងអស់រយៈពេលមួយស្របក់ ។ ទីបំផុត ព្យុះកំណាចនោះក៏បានកន្លងផុតទៅ ផ្ទៃមេឃក៏ស្រឡះ ហើយព្រះអាទិត្យក៏ជះរស្មីឡើងវិញម្ដងទៀត ។

ការព្រមទទួលយកកាលៈទេសៈទាំងឡាយ ដែលព្រះជាម្ចាស់បាននាំមកនៅក្នុងជីវិតរបស់យើងនោះ មិនមែនកើតឡើងទៅបានតែក្នុងមួយពេលព្រមគ្នានោះឡើយ ប៉ុន្តែត្រូវចំណាយពេលយ៉ាងយូរទើបយើងអាចទទួលយកបាន ។ ព្រះជាម្ចាស់ប្រើព្រះបន្ទូលរបស់ព្រះអង្គជាច្រើនដង ដើម្បីឆ្លើយទៅនឹងសំណួរទាំងឡាយដែលកប់ជ្រៅនៅក្នុងដួងចិត្តរបស់យើង ហើយដើម្បី

---

[១] *ទំនុក.១២៧:៣-៥*

បង្រៀនយើងនូវសេចក្ដីពិតដែលបង្អាក់យើង និងដឹកនាំឲ្យយើងដឹងពីការមានកូនដែលត្រូវការយើងជាពិសេស ។

២) *ការចាប់រំលោភនិងការសម្លាប់* : នៅក្នុងករណីខ្លះៗជនរងគ្រោះដែលត្រូវគេចាប់រំលោភរួចហើយ ត្រូវស្លាប់ គឺអាចបណ្តាលមកពីការរងគ្រោះលើរូបរាយកាយនៅពេលចាប់រំលោភ ឬអាចបណ្តាលមកពីជនល្មើសធ្វើឡើងដើម្បីបំបាត់ដាន ។ នៅក្នុងករណីមួយដែលអង្គការ *លីកាដូ* ធ្វើការស៊ើបអង្កេតនោះ គឺក្មេងស្រីម្នាក់ អាយុ៨ឆ្នាំត្រូវគេចាប់រំលោភ ហើយគេបានសម្លាប់ចោល ។

៣) *ការចាប់រំលោភដោយក្រុមជើងកាង* : ការចាប់រំលោភបែបនេះ គឺជាការចាប់រំលោភដែលមានជនល្មើសពីបីនាក់ ឬច្រើនជាងនេះ ការនេះបណ្តាលឲ្យមានការប៉ះទង្គិចធ្ងន់ធ្ងរកាន់តែខ្លាំងឡើងទៀត ។ បុគ្គលិកសិទ្ធិមនុស្សជឿថាករណីបែបនេះគឺកំពុងតែកើនឡើង ប្រហែលដោយសារតែការរីកផុលផុសនៃរូបភាពអាសអាភាស និងការកើនឡើងនៃពួកបងធំនៅក្នុងប្រទេសកម្ពុជា ។

៤) *ការចាប់រំលោភដែលទាក់ទងនឹងការចូលដៃជាមួយជនកំហូចដទៃទៀត* : ការនេះបង្ហាញឲ្យឃើញថា មានការកើនឡើងចំនួនស្ត្រីដែលជាប់ទាក់ទងយ៉ាងសកម្មជួយប្តី ជួយសង្សាររបស់ខ្លួន និងជួយដល់អ្នកដទៃទៀត ក្នុងការប្រើល្បិចបោកក្មេងស្រីៗ ដើម្បីឲ្យគេចាប់រំលោភបានដោយងាយ ប្រហែលបណ្តាលមកពីចង់ជួយការពារបុរសទាំងនោះមិនចង់ឲ្យគេទៅរកស្រីខូច ព្រោះខ្លាចឆ្លងរោគមកខ្លួនដែលជាប្រពន្ធ ឬជាសង្សារ ។

**តើនរណាជាជនល្មើស?**

កុមារគ្រប់អាយុទាំងអស់ និងគ្រប់សាវតារទាំងឡាយអាចក្លាយជាជនរងគ្រោះដោយសារការចាប់រំលោភបាន ជនល្មើសអាចចេញមកពីគ្រប់មជ្ឈដ្ឋានទាំងអស់ គឺបានសេចក្តីថា គ្រប់អាយុ គ្រប់មុខរបររកស៊ី និងគ្រប់តួនាទីនៅក្នុងសហគមន៍ ។ ចំពោះករណីជួញដូរកុមារ (ការជួញដូរសំរាប់ធ្វើការងារ ការបំរើផ្លូវភេទ ឬក្នុងគោលបំណងដទៃទៀត) ជនល្មើសតែងតែស្គាល់កុមារជាមុន គឺចេញមកពីរង្វង់គ្រួសារតែម្តង(ដូចជាឪពុក ពូ អ៊ុំ ឬសូម្បីតែបងប្អូនក៏សឹងតែមាន) ឬជនល្មើសអាចចេញពីសហគមន៍ដែលកុមាររស់នៅជាមួយ ដូចជាអ្នកជិតខាង ឬអ្នកដទៃដែលធ្វើការនៅជិតគ្នា ។ សូម្បីតែក្រុមជំនុំ ទាំងសមាជិក ទាំងអ្នកដឹកនាំ ក៏មិនអាចគេចផុតពីការជួយផ្តល់ការស្នាក់អាស្រ័យ ការលាក់ខ្លួនដល់អ្នកចាប់រំលោភដ៏មានសក្តានុពល ឬអ្នកចាប់រំលោភពិតប្រាកដ ហើយថែមទាំងជួយការពារដល់សមាជិករបស់ខ្លួនទៀតផង ។ ករណីភាគច្រើនដែលអង្គការ *លីកាដូ*[៦] បានស៊ើបអង្កេត នោះបានបង្ហាញឲ្យឃើញថា មានជនល្មើសជាកសិករ ឬអ្នកនេសាទ (៣០%) បន្ទាប់មកទៀតជាអ្នកបំរើការក្នុងរដ្ឋាភិបាល (នគរបាល ទាហាន ឬកងរាជអាវុធហត្ថ ១៧%) អ្នកមានមុខរបរផ្សេងៗ ទៀត (ម្ចាស់ផ្ទះជួល អ្នករត់ម៉ូតូឌុប វេជ្ជបណ្ឌិត ជាងមាស ជាដើម ១៤%) ។ ប្រការគួរឲ្យព្រួយបារម្ភនោះគឺ ចំនួនអ្នកចាប់រំលោភភាគច្រើន គឺជាកូនសិស្សសាលា (១៤%) ដែលខ្លះមានអាយុ១៣ឆ្នាំ ។ សារុបសេចក្តីមក ហេតុការណ៍ទាំងនោះបង្ហាញថា អាយុជាមធ្យមនៃជនល្មើសក្នុងការចាប់រំលោភនោះ គឺអាយុ២៥ឆ្នាំ ការនេះបញ្ជាក់ បង្ហាញឲ្យ

---

*[៦] ដរាបណាករណីទាំងឡាយត្រូវបានគេបង្ហាញឲ្យយើងដឹង ស្ថិតិទាំងអស់បានរៀបចំដកស្រង់ចេញពីករណីទាំងឡាយដែលបានស៊ើបអង្កេតដោយអង្គការលីកាដូ ក្នុងអំឡុងឆ្នាំ ១៩៩៩ និង ២០០០ ។*

ឪពុកម្តាយ គ្រូបង្រៀននៅតាមសាលា និងក្រុមជំនុំត្រូវការផ្តោតនូវការយកចិត្តទុកដាក់យ៉ាងប្រាកដប្រជា និងមិនឯអង់ឡើយក្នុងការបង្រៀនក្មេងប្រុស និងយុវជនទាំងនោះ ចំពោះការដែលគេត្រូវចេះគោរពដល់យុវនារី និងស្ត្រី។

## ច្បាប់ និងការដាក់ទោសដល់ការចាប់រំលោភ

នៅក្នុងប្រទេសកម្ពុជា ការចាប់រំលោភគឺជាបទឧក្រិដ្ឋមួយដែលគួរទទួលទោសតាមច្បាប់ ។ ជនរងគ្រោះបែបនោះ និងគ្រួសាររបស់គេមានសិទ្ធិប្តឹងចោទប្រកាន់ដល់ចំពោះជនល្មើស ដើម្បីផ្តល់យុត្តិធម៌ដល់ជនរងគ្រោះផង និងដើម្បីជួយការពារស្ត្រី និងកុមារដទៃទៀតមិនឲ្យមានការចាប់រំលោភនៅថ្ងៃអនាគតផង ។ ជនទាំងឡាយណាដែលគេរកឃើញថា មានពិរុទ្ធដោយសារការចាប់រំលោភគេនោះ ត្រូវទទួលទោសដោយជាប់ពន្ធធនាគារ ។ យោងតាមមាត្រា ៣៣ នៃច្បាប់ព្រហ្មទណ្ឌ ចំពោះការដាក់ទោសដល់ដល់ជនល្មើសដែលបានចាប់គេរំលោភនោះមានដូចតទៅ៖

*ការដាក់ទោសជាមធ្យម* : ត្រូវជាប់ពន្ធធនាគារ ពី៥-១០ ឆ្នាំ

*ការចាប់រំលោភដោយមានការបន្លំ ការប្រើអំពើហឹង្សា ឬការគំរាមកំហែង* : ត្រូវជាប់ពន្ធធនាគារពី ១០-១៥ ឆ្នាំ ។

*ការចាប់រំលោភដោយបុគ្គលដែលមានអំណាចគ្រប់គ្រងលើជនរងគ្រោះ (ដូចជា នគរបាល ចៅហ្វាយនាយនៅកន្លែងធ្វើការងារជាដើម)* : ត្រូវជាប់ពន្ធធនាគារពី ១០-១៥ ឆ្នាំ ។

*ការចាប់រំលោភដល់មនុស្សដែលមិនទាន់គ្រប់អាយុ (មនុស្សដែលមានអាយុក្រោម ១៦ឆ្នាំ)* : ត្រូវជាប់ពន្ធធនាគារទ្វេដងនៃចំនួនឆ្នាំ ដែលបានពោលខាងលើ ។

## ចូរប្រុងប្រយ័ត្ន

ពីព្រោះរឿងនេះគឺគ្រាន់តែជាការពិភាក្សាដ៏តូចតាច និងការដែលត្រូវយល់ដឹង នៅមានរឿងរ៉ាវជាច្រើនទៀត ដែលមានការយល់ច្រឡំចំពោះមូលហេតុនូវការចាប់រំលោភ និងឥទ្ធិពលនូវការចាប់រំលោភនោះប៉ះពាល់ធ្ងន់ធ្ងរចំពោះជនរងគ្រោះ ។ ហេតុដូច្នេះហើយមានមនុស្សជាច្រើន (សូម្បីតែឪពុកម្តាយ) ជាញឹកញយតែងតែចោទប្រកាន់ដល់ជនរងគ្រោះថា មានធ្វើអ្វីមួយដែលបណ្តាយ ឬអនុញ្ញាតឲ្យមានករណីចាប់រំលោភនេះកើតឡើង ។ ដោយហេតុនោះគេមិនបានដឹងពីអារម្មណ៍ និងសេចក្តីត្រូវការរបស់ជនរងគ្រោះ ហើយគេបែរទៅជាមិនជួយគាំទ្រ និងផ្តល់នូវសេចក្តីត្រូវការដែលជនរងគ្រោះត្រូវការដើម្បីជួសជុលផ្លូវចិត្តគេឡើងវិញ ។ ក្នុងនាមជាឪពុកម្តាយ គ្រូស្តូបរិស័ទ ជាសាច់ញាតិ ឬជាក្រុមជំនុំ និងសមាជិករស់នៅក្នុងសហគមន៍ជាមួយគ្នា យើងជាមនុស្សទាំងអស់គ្នាត្រូវតែយល់ និងមានចិត្តមេត្តាករុណាចំពោះជនរងគ្រោះ និងត្រូវដឹងនូវរបៀបដ៏សមរម្យផ្តល់នូវការគាំទ្រដល់គេ ។ ការនេះចាប់ផ្តើមឡើងជាមួយការយល់ដឹងនូវជំនឿមិនត្រឹមត្រូវខ្លះដែលមនុស្សទាំងឡាយមាន ចំពោះករណីនៃការចាប់រំលោភ ហើយនិងឥទ្ធិពលរបស់ជំនឿនោះដែលមានផលប៉ះពាល់ដល់ស្ត្រី និងកុមារ ។

## ទស្សនៈខុសឆ្គងបួនយ៉ាងដែលទាក់ទងទៅនឹងការចាប់រំលោភ

ទស្សនៈទី១: ស្ត្រីដែលទាក់ទាញឲ្យមានការចាប់រំលោភ ដោយការស្លៀកសម្លៀកបំពាក់លេចមុខលេចក្រោយមានអាការៈបង្ហាញឲ្យប្រុសស្រើបស្រាល ការដើរតែឯងនៅពេលយប់ស្ងាត់ជាដើម ។

*ការពិត : គ្មានសម្លៀកបំពាក់ ឬអាការៈណាមួយ ដែលផ្តល់សិទ្ធិឲ្យបុរសទៅចាប់ស្ត្រី ឬកុមាររំលោភនោះឡើយ ។*

ការនិយាយរឿងនេះ គឺជាការមួយខុសឆ្គង ដោយគេកំពុងបង្វែរការស្តី បន្ទោសពីជនល្មើស ទៅបន្ទោសលើជនរងគ្រោះទៅវិញ ហើយបែរទៅជាមិនបានអើពើ ចំពោះហេតុការណ៍ដែលថា កុមារវ័យក្មេងដែលត្រូវគេរំលោភនោះមិនទាន់ដឹងអ្វីថាការស្លៀកពាក់បែបនេះ ឬមានអាក្យកិរិយាបែបនោះបណ្តាយឲ្យមានការចាប់រំលោភនោះឡើយ ។

ទស្សនៈទី២: បុរសមិនអាចការពារឃុំគ្រងនូវបំណងប្រាថ្នាក្នុងការសេពសន្ធវៈរបស់ខ្លួនបានទេ ការចាប់រំលោភ គឺវាកើតឡើងឯងៗតែម្តង ។
*សេចក្តីពិត: តាមការសិក្សាស្រាវជ្រាវនៅសហរដ្ឋអាមេរិក និងនៅប្រទេសអង់គ្លេសបានបង្ហាញថា ការចាប់រំលោភភាគច្រើន គឺសុទ្ធតែរៀបគម្រោងទាំងស្រុង ឬរៀបចំផែនការផ្នែកខ្លះៗ មានតែ ១៥% ប៉ុណ្ណោះដែលកើតឡើងលក្ខណៈតម្រេកពុះកញ្ជ្រោលមិនដឹងខ្លួន ។*
តែមានមនុស្សជាច្រើនជឿថា អ្នកចាប់រំលោភទាំងឡាយ គឺជាមនុស្សមានតណ្ហាស្រេកឃ្លានហួសហេតុ យោងតាមការសិក្សាស្រាវជ្រាវទាំងនេះក៏បានបង្ហាញផងដែរថា ជនល្មើសភាគច្រើនអាចជាមនុស្សរៀបការរួច ឬជាមនុស្សធ្លាប់មានទំនាក់ទំនងជាមួយសង្សាររបស់ខ្លួន ធ្លាប់ជាមួយនឹងស្រីពេស្យាជាដើម ។

ទស្សនៈទី៣: អ្នកចាប់រំលោភភាគច្រើនគឺសុទ្ធសឹងតែជាមនុស្សមិនធ្លាប់ស្គាល់ជនរងគ្រោះ ។
*សេចក្តីពិត : ការចាប់រំលោភភាគច្រើន គឺធ្វើឡើងដោយមនុស្សដែលបានស្គាល់ជនរងគ្រោះ ។*
ចំពោះករណីទាំងអស់ដែលអង្គការ *លីកាដូ* បានស៊ើបអង្កេតឃើញនោះមាន ៦៨% នៃជនល្មើស គឺជាមនុស្សដែលស្គាល់ជនរងគ្រោះយ៉ាងច្បាស់ (សាច់ញាតិ ឬអ្នកដទៃដែលរស់នៅក្នុងផ្ទះជាមួយគ្នា ជាសង្សារ ជាអ្នកជិត

ខាង និងជាមិត្តសម្លាញ់) ចំណែកឯអ្នកចាប់រំលោភដែលមិនសូវស្គាល់ជនរងគ្រោះ ឬមិនសូវជិតដិតនឹងជនរងគ្រោះនោះ មានតែ ២៥% តែប៉ុណ្ណោះ ។

ទស្សនៈទី៤: ស្ត្រីភាគច្រើនចោទប្រកាន់បុរសដោយមិនត្រឹមត្រូវថាគេចាប់រំលោភខ្លួន ។

*សេចក្តីពិត : ការចាប់រំលោភ គឺជាបទឧក្រិដ្ឋមួយបែបក្នុងចំណោមបទឧក្រិដ្ឋធ្ងន់ធ្ងរបំផុត ដែលគេមិនសូវរាយការណ៍ឡើយ ។*

តាមការសិក្សាស្រាវជ្រាវនៅសហរដ្ឋអាមេរិកបង្ហាញឲ្យដឹងថា មានតែ២% នៃការរាយការណ៍ពីករណីចាប់រំលោភដែលបង្ហាញថាការអះអាងនោះមិនពិត ។ នៅក្នុងប្រទេសកម្ពុជា វាជារឿងមួយមិនទំនងឡើយដែលថាស្ត្រី ឬកុមារធ្វើការចោទប្រកាន់មិនត្រឹមត្រូវពីករណីចាប់រំលោភនោះ ព្រោះមានហេតុផលបីយ៉ាងគឺ៖ ទី១) មានការអៀនខ្មាសចំពោះការដែលទាក់ទងទៅនឹងការចាប់រំលោភ និងសកម្មភាពទាក់ទងនឹងផ្លែកភេទនេះនៅក្នុងទំនៀមទំលាប់ខ្មែរ គ្រួសារ និងសាច់ញាតិបងប្អូនមានការអៀនខ្មាសក្នុងការទទួលយកការនោះណាស់ ហើយម្យ៉ាងទៀតធ្វើឲ្យប៉ះពាល់ដល់កេរ្តិ៍ឈ្មោះរបស់ស្ត្រីនោះ និងធ្វើឲ្យប៉ះពាល់ដល់ឱកាសនៃការរៀបការរបស់នាងទៀតផង ។ ទី២) ការប្រព្រឹត្តិរបស់អាជ្ញាធរចំពោះករណីចាប់រំលោភនេះ មិនសូវចេះយោគយល់ទើបឲ្យមានការលំបាកក្នុងការចងក្រងពាក្យបណ្តឹង ហើយនិង ទី៣) ការភ័យខ្លាច និងការមិនទុកចិត្តដល់ប្រពន្ធ័ច្បាប់ បណ្តាលឲ្យស្ត្រីភាគច្រើនមិនជឿថា គេអាចទទួលបាន

នូវភាពយុត្តិធម៌ ។ ដោយសារតែការលំបាកទាំងនេះហើយដែលស្ត្រីខ្មែរ ឬកុមារខ្មែរមិនទំនងជាកុហកចំពោះបញ្ហាការចាប់រំលោភនេះឡើយ ។[៤]

ដោយសារតែទស្សនៈទាំងអស់ខាងលើនេះហើយ ទើបការចោទប្រកាន់លើករណីចាប់រំលោភតែងតែមិនសូវបានគេយកចិត្តទុកដាក់ប្រាកដប្រជានៅក្នុងគ្រួសារ ឬក្នុងសហគមន៍ឡើយ ។ តែទោះជាយ៉ាងក៏ដោយ *គឺថាការចាប់រំលោភនេះជាបទឧក្រិដ្ឋដែលមិនអាចដោះសាបាន និងជាអំពើបាបដ៏គួរឲ្យសោកស្ដាយដែលនាំមកនូវសេចក្ដីទុក្ខសោកទាស់នឹងព្រះជាម្ចាស់ ។*

**ឥទ្ធិពលនៃការចាប់រំលោភដែលប៉ះពាល់ដល់ជនរងគ្រោះ**

នេះគឺជារឿងពិតរបស់នាង "ថានី" (ឈ្មោះទាំងអស់នៅក្នុងករណីសំរាប់សិក្សានេះសុទ្ធតែត្រូវបានផ្លាស់ប្ដូរទាំងអស់ហើយ) គឺ៖

*នៅក្នុងឆ្នាំ ១៩៩៩ កុមារីអាយុ៧ឆ្នាំម្នាក់ ឈ្មោះ ថានី ត្រូវបានមិត្តភក្តិរបស់នាងឈ្មោះ ដារា បបួលឲ្យទៅលេងនៅផ្ទះអ្នកជិតខាងរបស់នាង ។ នាងមានចិត្តស្ទាក់ស្ទើរមិនចង់ទៅទេ ហើយក្រោយមកបាននិយាយថា បងប្រុសរបស់ ដារា អាយុ១៣ ឆ្នាំ បានចាប់រំលោភនាងថានី យ៉ាងហោចណាស់បីដងកាលពីពេលមុនៗ ។ ដោយសារម្ដាយចេះតែជំរុញឲ្យទៅ ថានី ក៏ព្រមទៅលេងជាមួយ ដារា ។ បន្ទាប់ពីរត់លេងមួយស្របក់ក្រោយមក ដារា ក៏បបួលទៅងូតទឹកលេងនៅឯស្រះទឹក ហើយនៅពេលដែលគេនាំគ្នាងូតទឹករួចហើយ ថានីក៏ប្រញាប់ប្រញាល់វិលត្រឡប់មកផ្ទះ ប៉ុន្តែ ដារា បានហៅបងប្រុសរបស់ខ្លួនដោយប្រាប់ថា ថានីកំពុងត្រឡប់ទៅវិញហើយ ។*

---

[៤] *ហេតុដូច្នេះហើយ បានជាស្ថិតិបង្ហាញថា ស្ត្រីខ្មែរមិនទំនងជានិយាយកុហក ដើម្បីចោទប្រកាន់ចំពោះបុរសនោះទេ ទោះបីការនេះវាអាចកើតឡើងក៏ពិតមែន ។ នៅទីនេះ ក៏ដូចនៅកន្លែងដទៃដែរ ជនចាប់ចោទតែងតែអះអាងថាខ្លួនគ្មានកំហុសអ្វីឡើយ រហូតដល់រកបានភស្តុតាងគ្រប់គ្រាន់ ទើបព្រមសារភាពនិងព្រមឡើងទៅតុលាការ ។*

បងប្រុសរូបនោះបានចេញមក ហើយចាប់ ថានី ដោយយកដៃបិទមាត់របស់នាង ហើយក៏អូសនាងទៅក្បែរគល់ត្នោតជិតនោះ ។ បន្ទាប់មកវាបានស្រែកប្រាប់ ដារា ឲ្យទៅរកកន្ទេលមួយ និងក្រមាបី(០៣)មកឲ្យវា ។ បន្ទាប់មកក្មេងប្រុសនោះបានប្រកួកហៅមិត្តភក្តិរបស់ខ្លួនពីរនាក់ទៀត ដែលមានអាយុ ១២ ឆ្នាំម្នាក់ និង១៣ ឆ្នាំម្នាក់ ។ នៅពេលដែល ដារា ក្រាលកន្ទេលរួចហើយ ក្មេងប្រុសទាំងបីបង្ខំ ថានី ឲ្យដេកនៅលើកន្ទេល ហើយពួកវាបានយកក្រមាចងបិទមាត់ ក្រោយមកទៀតចងដៃភ្ជាប់ទៅនឹងដើមឈើដែលនៅក្បែរនោះ។ ពួកវាបានចងជើងរបស់នាងឲ្យកន្ធែកពីគ្នា ហើយបន្ទាប់មកពួកវាចាប់ផ្តើមដំណើរការចាប់រំលោភម្តងម្នាក់ៗ គឺម្នាក់ៗបានសម្រេចពីរដងគ្រប់គ្នា ។ នៅពេលដែលក្មេងប្រុសទាំងនោះកំពុងចាប់រំលោភ ដារា កំពុងអង្គុយយាមផ្លូវមិនឆ្ងាយពីទីនោះប៉ុន្មានទេ ។

បន្ទាប់មកក្មេងប្រុសទាំងនោះបាននាំ ថានី ទៅឯស្រះទឹក ហើយចងពេងម្តងទៀត ហើយរំលោភនាងម្នាក់ៗពីរដងទៀត ។ នាង ថានី បានទទួលរងនូវការប៉ះពាល់យ៉ាងធ្ងន់ធ្ងរដោយសាររឿងនោះ និងមានបញ្ហាផ្នែកសតិអារម្មណ៍តាំងពីពេលនោះមក ។ នាងក៏មានរបួសធ្ងន់ធ្ងរ នៅត្រង់ប្រដាប់ភេទរបស់នាងផងដែរ ដែលត្រូវការការព្យាបាលពីសំណាក់គ្រូពេទ្យ ។ ពួកអ្នកស៊ើបអង្កេតរបស់អង្គការ លីកាដូ បានធ្វើអន្តរាគមន៍ ដើម្បីឲ្យនគរបាលចាប់ក្មេងប្រុសទាំងនោះដែរ ដែលមកទល់ពេលនេះ ក្មេងប្រុសនោះនៅតែរស់នៅយ៉ាងសុខសាន្តនៅក្នុងភូមិជិតនឹងជនរងគ្រោះ ។ នៅក្នុងពេលធ្វើការស៊ើបអង្កេតនោះ គេបានដឹងថាក្មេងប្រុសទាំងបីនាក់នោះបានមើលកុនរឿងកូនជ្រូក (រឿងអាសអាភាស) នៅកន្លែងបញ្ចាំងជិតនោះ ហើយការនោះបញ្ជាក់ឲ្យឃើញថា ក្មេងទាំងនោះរៀនតាមរូបអាសអាភាសនៅក្នុងវីដេអូ ដែលពួកគេបានមើលនោះយកមកធ្វើតាម ។

សូមគិតពិចារណាមួយស្របក់មើល តើលោកអ្នកមានអារម្មណ៍បែបណាដែរ បើសិនលោកអ្នកជា ថានីវិញនោះ គឺថា៖ ទី ១) នៅអំឡុងពេលចាប់រំលោភ ទី២ បន្ទាប់ពីការចាប់រំលោភ ហើយនិង ទី៣) នៅពេលដែលនាងប្រាប់ដល់សមាជិកគ្រួសារ ប្រាប់ដល់នគរបាល និង ប្រាប់ដល់តុលាការស្តីពីបទពិសោធន៍នោះ ។ តើលោកអ្នកគិតយ៉ាងណា ចំពោះខ្លួនលោកអ្នកផ្ទាល់ គិតពីជនល្មើស គិតពីមិត្តសម្លាញ់ដែលបានក្បត់លោកអ្នក និងបង្ខូចអនាគតរបស់លោកអ្នកនោះ?

ប្រហែលដោយសារតែទស្សនៈខុសឆ្គងដែលបានពណ៌នាខាងលើ និងដោយសារតែលក្ខណៈនៃបទឧក្រិដ្ឋនេះធ្ងន់ធ្ងរ ទើបមានមនុស្សជាច្រើនមិនបានសញ្ជឹងគិតឲ្យបានជ្រាលជ្រៅអំពីអារម្មណ៍របស់ជនរងគ្រោះដោយសារគេចាប់រំលោភនោះថាមានអារម្មណ៍យ៉ាងណាឡើយ ។ ដោយហេតុនោះទើបមានការខ្វះខាតយ៉ាងធ្ងន់ធ្ងរចំពោះការយល់ដឹងអំពីផលប៉ះពាល់ផ្នែកផ្លូវចិត្តដល់ជីវិតរស់នៅរបស់ជនរងគ្រោះដោយគេចាប់រំលោភនោះ ។ គ្រប់ផ្នែកទាំងអស់នៅក្នុងសង្គមត្រូវតែទទួលនូវការអប់រំឲ្យបានដឹងពីឥទ្ធិពលនៃការចាប់រំលោភដែលប៉ះពាល់ទាំងផ្លូវកាយ និងផ្លូវចិត្ត របស់ស្ត្រី និងកុមារ តួយ៉ាងដូចជានាងថានីនេះ ។ ការទាំងអស់នេះអាចគិតបញ្ចូលទាំងការងារដូចតទៅនេះ គឺ៖

១. ការប៉ះពាល់ផ្នែករាងកាយ

- ការរងរបួសផ្នែកផ្លូវកាយ ដោយសារការបង្ខំរបស់ជនល្មើស។
- ប្រហែលជាអាចឆ្លងមេរោគ HIV/AIDS
- ជម្ងឺកាមរោគដទៃទៀត (ប្រមះ ស្វាយក្រាប សិរមាន់ មានដំបៅក្លាយនៅតាមបំពង់បង្ហូរទឹកមូត្រ និងមានជម្ងឺដុះសាច់នៅលើប្រដាប់ភេទ)

- ការមានផ្ទៃពោះដែលមិនចង់បាន ឬការមានផ្ទៃពោះចំពោះស្ត្រីវ័យក្មេងពេក ។
- ការក្អួតចង្អោរ អស់កម្លាំង ឈឺក្បាលខ្លាំង ឈឺពោះ និងរបួសត្រង់ប្រដាប់ភេទ ។

២. **ការប៉ះពាល់ផ្នែកផ្លូវចិត្ត**

- មានការថប់បារម្ភធ្ងន់ធ្ងរ ភ័យខ្លាច ធ្លាក់ទឹកចិត្ត ជាប់ពិរុទ្ធក្នុងចិត្ត បន្ទោសខ្លួនឯង ឯកោ ត្រមង់ត្រមោច ខឹង មានអាការៈច្រងេងច្រងាង ។
- មានភាពអាម៉ាស់ ខ្មាសគេ ខ្វះទំនុកចិត្តខ្លួនឯង មើលមកខ្លួនឯងថាឥតប្រយោជន៍ ។
- មិនសូវឃ្លានអាហារ មានបញ្ហាដេកនោមយប់រាំរ៉ៃ ។
- ខូចចិត្តយ៉ាងខ្លាំង ។
- ចង់ធ្វើអត្តឃាត ។

*នៅក្នុងឆ្នាំ ២០០២ ចិន្តា អាយុ៨ឆ្នាំ ត្រូវអ្នកជិតខាងរបស់នាងចាប់រំលោភបានពីរដង ហើយអ្នកជិតខាងនោះបានប្រាប់នាងថា កុំឲ្យប្រាប់នរណាឲ្យសោះ បើពុំនោះទេគាត់នោះនឹងសម្លាប់នាងចោល ។ នៅថ្ងៃមួយម្ដាយរបស់នាងងូតទឹកឲ្យនាង ម្ដាយនាងសង្កេតឃើញថា មានអ្វីមួយដែលខុសធម្មតាក៏ឈ្លេចសួរកូនស្រីរបស់គាត់ ។ នៅពេលដែល ចិន្តា បដិសេធមិនព្រមប្រាប់ទាំងឪពុកទាំងម្ដាយរបស់នាងយកខ្សែភ្លើងមកវាយធ្វើបាបនាង ។ បន្ទាប់មកនាងក៏ព្រមសារភាពថានាងត្រូវគេចាប់រំលោភ ហើយពេលនោះនាងភ័យញ័រយ៉ាងខ្លាំងដោយព្រោះខ្លាចបុរសម្នាក់នោះមករកនាងឃើញ រួចធ្វើបាបនាងទៀត ។ គ្រួសាររបស់នាងបាននិយាយថា ឥឡូវនេះនាងភ័យខ្លាចយ៉ាងខ្លាំងចំពោះមនុស្សដទៃទៀតដែលដើរមកជិតនាង ហើយបានប្រាប់ទៀតថា គេចង់*

ឲ្យនាងទទួលបាននូវការប្រឹក្សា ផ្តល់យោបល់ ដើម្បីឲ្យបានរួចផុតពីសេចក្តីភ័យខ្លាចនេះ ។

នៅក្នុងឆ្នាំ ២០០១ ក្មេងស្រីម្នាក់ អាយុ៧ឆ្នាំ ឈ្មោះ សុផល ត្រូវគេចាប់រំលោភ៩ ទៅ៥ដង ត្រូវគេវាយដំ ហើយចាក់សោទុកនៅក្នុងកន្លែងសម្ងាត់មួយអស់រយៈពេលជាច្រើនថ្ងៃ ។ នៅពេលដែលគេទៅរកនាងឃើញ គឺនាងសន្លប់បាត់ស្មារតីទៅហើយ ព្រោះនាងបាត់បង់ឈាមច្រើនពេក ហើយនាងត្រូវការទទួលការថែទាំនៅមន្ទីរពេទ្យជាបន្ទាន់ ។ នៅពេលបច្ចុប្បន្ននេះនាងដេកយល់សប្តិអាក្រក់រៀងរាល់យប់ និងដេកនោមដាក់គ្រែរាល់យប់ នាងមានការភ័យខ្លាចចំពោះមនុស្សចម្លែក (ជាពិសេសមនុស្សប្រុស) មិនហ៊ានដើរទៅណាឡើយបើគ្មានម្តាយនាងទៅជាមួយ ហេតុដូច្នេះទើបនាងមិនអាចទៅរៀននៅឯសាលាបាន ។ នៅពេលដែលលេងជាមួយបងប្អូនរបស់នាង ស្រាប់តែមានបញ្ចេញអាការៈឃោរឃៅភ្លាម និងខឹងតួងតែម្តង ។ ពួកអ្នកផ្តល់ការប្រឹក្សាឲ្យយោបល់ដែលបានមកជួប សុផល បានសង្កេតឃើញថា នាងមិនបានទទួលនូវការបើកឱកាសនិយាយ និងបង្ហាញពីអារម្មណ៍របស់នាងដែលត្រូវគេចាប់រំលោភនោះ ទើបនាងត្រូវបញ្ចេញតាមផ្លូវផ្សេង ឧទាហរណ៍នៅពេលដែលនាងកំពុងលេងជាមួយបងប្អូន ។

នៅក្នុងឆ្នាំ ២០០០ ក្មេងស្រីម្នាក់អាយុ១៥ឆ្នាំ ឈ្មោះ សុភា ត្រូវពួកជើងកាងអាយុ១៨ឆ្នាំដែលនៅក្នុងភូមិជាមួយនាងដែរ ចាប់នាងរំលោភ ។ នាងត្រូវជនល្មើសវាយដំយ៉ាងខ្លាំង នៅក្នុងពេលដែលគេចាប់នាងរំលោភនោះ រាងកាយត្រូវជាំសព្វសាច់ និងមានរបួសនៅក្នុងប្រដាប់ភេទរបស់នាង ។ បន្ទាប់ពីទទួលរងនូវការឈឺចាប់នេះរួចមក សុភា ទទួលរងនូវការឈឺចាប់មួយបែបទៀត គឺការដេកយល់សប្តិអាក្រក់នៅពេលយប់ មានការភ័យខ្លាចយ៉ាងខ្លាំងនៅពេលដែលនាងនៅតែឯង និងយំភ្លាមមួយរំពេច ។

ការប៉ះពាល់រយៈពេលយូរនៃការចាប់រំលោភ អាចគិតបញ្ចូលទាំងការផ្លាស់ប្តូរបុគ្គលិកលក្ខណៈ ខ្វះការទុកចិត្តដល់អ្នកដទៃ មានទុទិដ្ឋិនិយមចំពោះថ្ងៃអនាគត បាត់បង់ការទុកចិត្តលើខ្លួនឯង ហើយនិងមិនទុកចិត្តចំពោះមនុស្សពេញវ័យទាំងអស់ ។ ទំនាក់ទំនងនៅក្នុងសហគមន៍ក៏មានការប៉ះពាល់ដែរ ក្នុងនាមជាក្មេងស្រីដែលបាត់បង់ភាពបរិសុទ្ធរបស់ខ្លួននោះ នៅក្នុងទំនៀមទំលាប់ខ្មែរទទួលរងនូវការខូចកេរ្តិ៍ឈ្មោះយ៉ាងខ្លាំងចំពោះការនោះ បានធ្វើឲ្យនាងបែងចែកវណ្ណៈ ពីសំណាក់មិត្តភក្តិ និងអ្នកជិតខាង ហើយថែមទាំងបន្ថយនូវឱកាសដែលអាចរៀបការនោះកាន់តែធ្ងន់ធ្ងរថែមទៀតផង ។ ការសិក្សាស្រាវជ្រាវក៏បង្ហាញផងដែរថា ជនរងគ្រោះដែលត្រូវគេចាប់រំលោភនោះមានការងាយរងគ្រោះថ្នាក់ខ្លាំងណាស់ក្នុងការចាប់រំលោភម្តងទៀត ឬត្រូវទទួលរងនូវការដែលគេយកទៅលក់ ឬត្រូវគេបង្ខំឲ្យធ្វើជាស្រីពេស្យាច្រើនជាងស្រីដទៃនៅក្នុងសហគមន៍ ។

ការទាំងនេះបង្ហាញយ៉ាងច្បាស់ពីការកែកុនជីវិតរស់នៅដែលមានការប៉ះពាល់លើជនរងគ្រោះនោះ ហើយថែមទាំងមានផលប៉ះពាល់ដល់គ្រួសាររបស់ជនរងគ្រោះផងដែរ ។ ទោះបីជាយ៉ាងណាក៏ដោយ គឺផលប៉ះពាល់ខាងលើនេះមិនទាន់បង្ហាញឲ្យឃើញភ្លាមនោះទេ តែមិនមែនបានសេចក្តីថា បញ្ហានោះមិនបានកើតឡើង ឬបានន័យថា ជនរងគ្រោះបានជានាឡើងដូចគេដូចឯងដែរនោះឡើយ ។ នាងប្រហែលជាអាចខំបំភ្លេច ឬខំលាក់ពីអារម្មណ៍ភ័យខ្លាចរបស់នាងមិនឲ្យនរណាយល់បាន ។ ទោះករណីណាក៏ដោយ គឺជាការសំខាន់ណាស់ក្នុងនាមយើងជាសមាជិកគ្រួសារ អ្នករស់នៅក្នុងសហគមន៍ និងក្នុងនាមជាសមាជិកក្រុមជំនុំ ត្រូវដឹងពីអារម្មណ៍របស់ជនរងគ្រោះដូចជានាង ថានី ហើយត្រូវបង្ហាញពីសេចក្តីស្រឡាញ់ដ៏ឥតលក្ខខ័ណ្ឌរបស់គ្រីស្តបរិស័ទ ត្រូវព្រមទទួលរាប់អាន និងផ្តល់ការគាំទ្រដល់នាង ។

## ត្រូវប្រុងជើងការចំពោះរឿងនេះ

"ការប្រុងជើងការ" មានន័យថា លោកអ្នកត្រូវធ្វើអ្វីមួយ ដើម្បីការពារបញ្ហានោះមុនពេលវាកើតឡើង ឬបើសិនជាវាកើតឡើងរួចហើយនោះ ត្រូវយកការទទួលខុសត្រូវផ្ទាល់ខ្លួនមកដោះស្រាយបញ្ហានោះឲ្យបានប្រសើរបំផុតតាមលទ្ធភាពរបស់ខ្លួន ។ ចំពោះបញ្ហាដែលប៉ះពាល់នឹងដួងចិត្ត និងធ្វើឲ្យខ្វល់ខ្វាយដូចជាករណីចាប់រំលោភនោះ គឺវាងាយធ្វើឲ្យយើងបដិសេធ ឬមិនអើពើចំពោះបញ្ហានោះជាជាងការដែលយើងត្រូវទៅប្រឈមមុខ និងត្រូវមានការចូលរួមក្នុងការគាំពារដល់កុមាររងគ្រោះ ។ ប៉ុន្តែក្នុងនាមយើងជាគ្រីស្តបរិស័ទ ព្រះជាម្ចាស់បានត្រាស់ហៅយើងមក ឲ្យយើងយកព្រះបន្ទូលរបស់ព្រះអង្គទៅជួយដោះស្រាយបញ្ហាលោកីយ៍ យើងត្រូវតែមានស្មារតីប្រុងជើងការ(ត្រៀមខ្លួនជាស្រេច) និងផ្តល់នូវសេចក្តីត្រូវការដ៏គ្រប់ជ្រុងជ្រោយដល់កុមារ និងមនុស្សពេញវ័យទាំងឡាយដែលត្រូវការយើង ។ សូមព្រះអង្គប្រទានពរនូវគតិបណ្ឌិត អំណោយទានផ្សេងៗរបស់ព្រះវិញ្ញាណ លើសពីនោះទៅទៀតនោះ គឺជាអំណោយទាននៃសេចក្តីស្រឡាញ់ គឺព្រះជាម្ចាស់បានប្រដាប់កាយយើងឲ្យមានគ្រប់យ៉ាង ដើម្បីឲ្យយើងអាចឆ្លើយតបចំពោះបញ្ហាការចាប់រំលោភកុមារនេះ ។ យើងទាំងអស់គ្នា ក្នុងតួនាទីជា ឪពុកម្តាយជាសាច់ញាតិ ជាក្រុមជំនុំ ឬជាសមាជិករស់នៅក្នុងសហមគមន៍ ជាមួយគ្នាយើងអាចផ្តល់នូវស្មារតីប្រុងជើងការតាមមធ្យោបាយដូចខាង ក្រោមនេះគឺ៖

### ឪពុកម្តាយ និងសមាជិកក្នុងគ្រួសារ

- ចូរពិភាក្សាជាមួយកូនរបស់លោកអ្នក តាមរបៀបមួយដែលសមរម្យនឹងអាយុ ហើយនិងស៊ីនឹងការយល់ដឹងរបស់គេ ស្តីពីបញ្ហាដែលទាក់ទងទៅនឹងការចាប់រំលោភ ។ ចូរប្រាប់ឲ្យគេបានដឹងថា គឺជាការ

មិនត្រឹមត្រូវឡើយ បើមានមនុស្សណាម្នាក់មកប៉ះពាល់ ឬធ្វើការឃាយីដល់ផ្នែកភេទ ត្រូវឲ្យគេចេះប្រយត្ន័ខ្លួននៅពេលចេញដើរទៅណាមកណាតែម្នាក់ឯងនៅក្នុងកន្លែងដែលស្ងាត់នោះ ហើយត្រូវរត់រកឲ្យគេជួយ បើសិនជាគេមានការភ័យខ្លាចថា មានគេបំរុងនឹងធ្វើបាបតាមរបៀបណាមួយនោះ ។

- ចូរប្រាប់ដល់កូនថាគេមានសេរីភាពគ្រប់គ្រាន់ ក្នុងការនិយាយប្រាប់ពីបញ្ហារបស់គេប្រាប់មកលោកអ្នកគ្រប់ពេលវេលា និងប្រាប់កូនឲ្យដឹងថាសូម្បីតែកូននោះត្រូវគេចាប់រំលោភក៏ដោយ លោកអ្នកនៅតែអះអាងឲ្យគេដឹងថាលោកអ្នកនៅតែស្រឡាញ់គេដដែល ព្រមស្តាប់ និងផ្តល់ការគាំទ្រដល់គេដោយឥតមានលក្ខខ័ណ្ឌឡើយ ។
- ចូររៀនសំគាល់ និងសង្កេតមើលពីសញ្ញាទាំងឡាយដែលទាក់ទងនឹងផ្នែករាងកាយ ឬផ្នែកផ្លូវចិត្តកូនរបស់លោកដែលអ្នកត្រូវគេចាប់រំលោភ (ដូចមានចែងក្នុងបញ្ជីខាងលើ) ហើយបើសិនលោកអ្នកមានការសង្ស័យថា មានគេចាប់រំលោភ ចូរលួងលោមកូន ដោយផ្តល់ឱកាសឲ្យកូនអាចនិយាយប្រាប់លោកអ្នកពីការទាំងនោះ ។ ចូរកុំបង្ខំកូន ព្រោះការនោះអាចបន្ថែមនូវការប៉ះពាល់ផ្នែកផ្លូវចិត្តកាន់តែធ្ងន់ធ្ងរថែមទៀត ។ កូននោះគង់តែនឹងប្រាប់លោកអ្នក ឬមនុស្សណាម្នាក់ដែលគេទុកចិត្ត បើសិនយើងផ្តល់ឱកាសគ្រប់គ្រាន់ឲ្យដល់គេ ។
- ចូរពិចារណាមើលឲ្យមានល្អិតល្អន់ បន្ទាប់ពីពិភាក្សាជាមួយកូនរបស់លោកអ្នករួចហើយនោះ ចូររាយការណ៍ការនេះទៅនគរបាល ក្រសួងកិច្ចការនារី និងអតីតយុទ្ធជន ក្រុមអង្គការសិទ្ធិមនុស្ស ដូចជាអង្គការ *លីកាដូ* ឬអង្គការក្រៅរដ្ឋាភិបាលដទៃទៀត ដូចជា មជ្ឈ

មណ្ឌលស្តារវិបត្តិស្ត្រីកម្ពុជា[៦] ។ ចូរធ្វើពាក្យបណ្តឹងជូនទៅកន្លែងទាំងអស់នេះ ដើម្បីអាចឈានទៅរកការចាប់ខ្លួនជនល្មើស និងជួយការពារកុមារដទៃទៀតឲ្យរួចពីការរងឈឺចាប់ដោយការចាប់រំលោភនេះនៅថ្ងៃក្រោយទៀត ។

## ក្រុមជំនុំ

- ចូរប្រកាសប្រាប់ដល់សមាជិកក្រុមជំនុំដទៃទៀតពីបញ្ហានោះ តាមរបៀបមួយដ៏សមរម្យ តាមពេលវេលា និងកន្លែងដែលសមរម្យ ប្រាប់ពីរឿងដែលគេនិយាយតៗគ្នា ប្រាប់ពីរឿងរ៉ាវពិតប្រាកដ និងឥទ្ធិពលដែលប៉ះពាល់ចំពោះការចាប់រំលោភនេះដល់ស្ត្រី និងកុមារ។ ឧទាហរណ៍ ដូចជាការនាំគ្នាអានផ្នែកខ្លះៗនៃអត្ថបទនេះ នៅក្នុងក្រុមតូចរបស់ស្ត្រី ហើយបន្ទាប់មកពិភាក្សាគ្នា នេះគឺជាមធ្យោបាយមួយដែលយើងអាចធ្វើបានចំពោះការនេះ ។
- បង្ហាញពីសេចក្តីស្រឡាញ់របស់គ្រីស្តបរិស័ទ និងផ្តល់នូវការគាំទ្រគ្រប់យ៉ាងទាំងអស់ដល់ជនរងគ្រោះដែលត្រូវគេចាប់រំលោភ។ ចូរធ្វើការនេះដោយគ្មានការនិយាយខ្សិបខ្សៀវពីរឿងរ៉ាវអាស្រូវរបស់គេ ឬនិយាយអ្វីដែលធ្វើឲ្យគេមានការអាម៉ាស់ឡើយ គ្រាន់តែបង្ហាញពី

---

*[៦]ប៉ុស្តិ៍នគរបាលជាតិ: ០២៣ ៧២០៥៥៥; អង្គការទស្សនៈពិភពលោកមជ្ឈមណ្ឌលនារាំថ្មី: ០២៣ ៨៨០៣៤២; មជ្ឈមណ្ឌលស្តារវិបត្តិស្ត្រីកម្ពុជា: ០២៣ ៩៨២១៥៨ ឬ ០១២ ៨៤០៥០៧; អង្គការលីកាដូ: ភ្នំពេញ: ០២៣ ៣៦០៩៦៥/២១៧៦២៦; បន្ទាយមានជ័យ: ០៥៤ ៩៥៨៨៦១; បាត់ដំបង: ០៥៣ ៩៥២៨២៨; កោះកុង: ០៣៥ ៩៣៦១១៦; កំពង់ចាម: ០៤២ ៩៤១៤៦៤; កំពង់ឆ្នាំង: ០២៦ ៩៨៨៦៣៧; កំពង់ស្ពឺ: ០២៥ ៩៨៧២២០; កំពង់ធំ: ០៦២ ៩៦១២៩២; កំពត: ០៣៣ ៩៣២៦៦៣; ព្រៃវែង: ០៤៣ ៩៤៤៥២៧; ពោធិ៍សាត់: ០៥២ ៩៥១៤៩៦; ក្រុងព្រះសីហនុ: ០៣៤ ៩៣៣៧១៦; ស្វាយរៀង: ០៤៤ ៩៤៥៨៣៣; តាកែវ: ០៣២ ៩៣១៣៦០ ។*

សេចក្តីស្រឡាញ់ដល់កូន និងឲ្យតម្លៃដល់គេនោះ គឺគ្រប់គ្រាន់ណាស់ទៅហើយនៅក្នុងករណីនេះ ។ ក្នុងការធ្វើបែបនេះ គេនឹងដឹងថាក្រុមជំនុំគឺជាកន្លែងផ្តល់នូវការប្រោសឲ្យជាពីស្នាមរបួសដួងចិត្ត និងជាកន្លែងដែលមានគេទទួលរាប់អាន ហើយកុមារក៏បានទទួលនូវសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ តាមរយៈក្រុមជំនុំនៃគ្រួសាររបស់គេ ។

## សហគមន៍

- ចូរប្រាប់អ្នកជិតខាងរបស់លោកអ្នក ប្រធានភូមិ ចៅសង្កាត់ និងអាជ្ញាធរមានសមត្ថកិច្ចនៅក្នុងសហគមន៍នោះ ឲ្យគេបានដឹងពីបញ្ហា តែត្រូវនិយាយប្រាប់ដោយរើសរកវិធីដ៏សមរម្យដូចមុនទៀត ប្រាប់រឿងរ៉ាវដែលនិយាយតៗគ្នា ប្រាប់ពីរឿងពិត និងប្រាប់ពីឥទ្ធិពលដែលប៉ះពាល់ដោយសារការចាប់រំលោភនោះ ។ បន្ទាប់ពីគេបានយល់នូវបញ្ហានោះហើយ គេអាចចូលរួមជាមួយលោកអ្នកក្នុងការទប់ស្កាត់ និងគាំទ្រដល់កុមារដែលរងគ្រោះដោយសារគេចាប់រំលោភនោះ ។
- ចូរឃ្លាំមើលកុមារនៅក្នុងសហគមន៍របស់លោកអ្នក ដោយជួយមើលថែគេដោយមិនឲ្យគេប្រថុយគ្រោះថ្នាក់ដោយការចេញដើរហើរទៅណាមកណាតែម្នាក់ឯងនៅកន្លែងដែលស្ងាត់ ឬដោយការចេញដើរលេងជាមនុស្សប្រុស ឬយុវជនដែលគួរឲ្យសង្ស័យនោះ ។
- បើលោកអ្នកបានឮថា មានកុមារណាម្នាក់ត្រូវគេចាប់រំលោភ ចូរពិភាក្សាដោយសម្ងាត់ជាមួយកុមារនិងឪពុកម្តាយរបស់នាង ស្តីពីរបៀបដែលត្រូវរាយការណ៍ប្រាប់ទៅនគរបាល ប្រាប់ទៅអង្គការសិទ្ធិមនុស្សនានា ដូចជា អង្គការ *លីកាដូ* ឬអង្គការក្រៅរដ្ឋាភិបាល

ដទៃទៀតដែលធ្វើការជាមួយស្ត្រី ឬកុមារ ។ ចូរអនុញ្ញាតឲ្យពួកគេបានដឹងថា ជំនួយផ្នែកច្បាប់ និងផ្នែកសង្គមគឺគេអាចរកបានតាមរយៈអង្គការទាំងអស់នោះ ហើយសូមលើកទឹកចិត្តដល់គេឲ្យស្វែងរកយុត្តិធម៌ និងជួយការពារដល់កុមារដទៃទៀត ដោយការធ្វើពាក្យបណ្តឹងចោទប្រកាន់លើជនល្មើសដែលបានប្រព្រឹត្តការនោះ កុំឲ្យថ្ងៃក្រោយគេប្រព្រឹត្តការដដែលនេះតទៅទៀត ។

ការនេះម្តងទៀតគឺជាការសំខាន់បំផុត គឺត្រូវបង្ហាញនូវសេចក្តីស្រឡាញ់ និងការទទួលរាប់អានចំពោះជនរងគ្រោះដែលត្រូវគេចាប់រំលោភនៅក្នុងសហគមន៍របស់លោកអ្នក ដោយមិនមានការនិយាយខ្សិបខ្សៀវអំពីរឿងអាស្រូវរបស់គេ ឬក៏ធ្វើអ្វីមួយដែលនាំឲ្យគេមានការអាម៉ាស់ ឬបាត់បង់តម្លៃថ្លៃថ្នូរនោះឡើយ ។ ចូរឲ្យតម្លៃដល់គេដូចដែលលោកអ្នកផ្តល់តម្លៃដល់កុមារដទៃដែរ ដ្បិតព្រះជាម្ចាស់ស្រឡាញ់កុមារទាំងអស់ដោយឥតលក្ខខ័ណ្ឌ មិនថាឡើយកុមារនោះមានបញ្ហាអ្វីកើតឡើងឡើយ ។

នៅក្នុងការសរុបសេចក្តី ក្នុងនាមយើងគ្រីស្ទបរិស័ទដែលប្រកបដោយគតិបណ្ឌិត អំណោយទាន និងដោយជំនឿ យើងទាំងអស់គ្នាជាមនុស្សដែលប្រុងជើងការនៅក្នុងការទប់ស្កាត់កូនរបស់យើងពីការទទួលរងគ្រោះដោយសារការចាប់រំលោភ ហើយយើងត្រូវតែមានសេចក្តីស្រឡាញ់ និងផ្តល់នូវការគាំទ្រជនរងគ្រោះនៅក្នុងតំណាក់ការដែលជនរងគ្រោះកំពុងតែខំតាំងជំហរឡើងវិញ ។ បើសិនយើងចេះប្រាប់ពីពត៌មានផ្សេងឲ្យគេដឹង ធ្វើការនោះដោយប្រុងប្រយ័ត្ន និងដោយការប្រុងជើងការ ព្រោះវាជារឿងងាយនឹងប៉ះពាល់ផ្លូវចិត្ត ហើយព្រមទាំងសុំជំនួយពីព្រះអម្ចាស់នៅក្នុងកិច្ចខំប្រឹងប្រែងរបស់យើង នោះយើងអាចធ្វើការនេះទៅបានដោយអាងលើអំណាចចេស្តា និងព្រះគុណរបស់ព្រះអង្គ ។

HONEYCOMB 3/2 (April 2002): 134–138



# Confronting Pornography: Choosing Life

*Glenn MILES*

Pornography is one of those things hard for Christians in the West to get upset about. It's a bit like drinking alcohol. Although it is acceptable for an anti-smoker to politely ask someone else to refrain from smoking, a person who admits to being a teetotaler is considered rather uptight. Similarly, if someone says something against pornography he or she might be considered prudish. In postmodern America and Europe, women's magazines increasingly urge women to get used to the fact that their boyfriends use pornography, and not get too upset by it. Viewing "girlie" magazines is considered a normal part of growing up. "Boys will be boys." So fathers are reluctant to educate their children on the dangers of pornography, even if they are aware of the pull and pain it causes even themselves.

Sex sells, and it's here to stay. MTV, spread by satellite and cable to the most remote corners of the earth, not only globalizes a culture of music and fashion, but normalizes a culture in which sex is a commodity that can be demanded.

In many cultures traditional values have kept sex secret, and in many Muslim countries modesty is considered so sacred that the whole female body, apart from slits for the eyes, is covered in a *bourdkar*. The Western media is horrified, but advocates of the system say that it honors women and provides them a form of protection.

In a country like Cambodia it is difficult to accurately estimate the effect of pornography on the culture, but it could be one of the reasons why sexual abuse and exploitation are so rampant. When I first visited the country in 1990 there were no billboards anywhere that did not promote a political agenda. But now advertising is ubiquitous, and billboards promote cigarettes and alcohol, promising success, health, and sex thereby. Unfortunately for the poor the opposite more likely results, as they use up precious resources. Furthermore the image of a perfect body that even those of us with normal healthy bodies envy is promoted. What must it do to the self-image of a person with a disability? Pornography not only exploits the person being photographed, but the viewer as well.

In the markets of Phnom Penh pirated sex videos are available for two dollars. These include not only soft porn, but portray every conceivable sexual act that most Christians have only known through descriptions in the Bible. Vendors make them less or more available depending on whether the authorities are clamping down, but everyone knows that anything can be resolved with some money under the table. Tourists are some of the customers, but more and more young people can be seen rummaging through cardboard boxes of explicit videos and VCDs.

It is difficult to prove that pornography leads to an increase in rape and sexual exploitation, but scripture indicates that it leads the voyeur down a slippery slope. Proverbs describes a set of doors. One is the doorway of a prostitute, where she calls out to those who pass by with promises of secret delights, but the guests who have entered the doorway are described as "dead" and "in the depths of Sheol."[1]

A different doorway can be chosen for those who listen to the Lord.[2] Those who watch daily at these doors can find wisdom, and "whoever finds me finds life." One door leads to life, the other to death. The passage goes on to describe some of the other consequences of choosing the wrong door—"those who miss me injure themselves, all who hate me love death." Pornography leads to death.

---

[1]Prov 9:13–18.

[2]Prov 8:32–36.

Christians may convince themselves that pornography is better than adultery because it affects only them, but those who have slowly, unwittingly become addicted to pornography will tell you how it destroyed their marriages and other relationships. I would suggest that missionaries and Christian workers are particularly vulnerable to this misconception and, using the excuse of needing to obtain information from the internet, are vulnerable to entering the private fantasy world of internet pornography.

So what does pornography do to a society? Although it is difficult to prove, I would suggest the following results stem from people wanting to experiment with sexual behavior they have seen:

- An increase in rape and sexual abuse in and outside the home
- An increase in the use of prostitutes
- An increase in the incidence of HIV/AIDS.

At the 2001 Evangelical Fellowship of Cambodia Youth Conference, one hundred forty-five attendees completed a survey on pornography, though each respondent did not necessarily answer all the questions. One hundred one males and forty-four females participated in the survey; forty-four were age 18 or under, fifty-three were age 19–21, and thirty-six were over age 22. Twelve respondents did not state their age.

The survey was completely confidential; completed forms were dropped anonymously in a box. The group was informed that the overall results would be made available to pastors and others involved in sex education after they had been analyzed.

One of the most interesting results of this survey concerned pornography. The number of males who have looked at pornographic literature *increased* according to age—from 27% below 18 years, to 38% at 19–21 years, to 47.2% at 22 years or over. However, among the females we find a different but disturbing trend—29.5% of girls under 18 years say they have read pornographic literature, compared to 6% for ages 19–21, and 3% for ages 22 and over. This may indicate that the aggressive advertising campaigns and lowering costs of literature aimed at girls may be proving successful.

Here are some further results of the survey:

| | Males | Females |
|---|---|---|
| Have viewed pornographic video | 33% | 3.5% |
| Have viewed pornography on the web | 2% | 0% |
| Have previously attended a sex education seminar | 28% | 14.5% |
| Source of sex education | | |
| parents | 34% | 12% |
| another relative | 19% | 5.5% |
| teachers | 50% | 17.2% |
| friends | 28% | 2% |
| pastor | 43% | 19% |
| magazines | 17% | 3.5% |
| videos | 14.5% | 2% |
| Know others their age who have had sex before marriage | 35% | 13% |
| Have had sex outside of marriage before becoming a Christian | 16% | 2% |
| Have had sex outside marriage since becoming a Christian | 4% | 1.5% |

Comparing statistics in the last two rows would seem to indicate that young people are influenced by their belief in Christianity. However it should be noted that the number of young people who refused to answer the last question was 22%, compared to 7.3% for the previous question.

It may be instructive to repeat this survey in future conferences, compare results, and note trends. This information could be used in the development of curriculum by the EFC Youth Commission and Servants, both of which are partners of Tearfund.

The results should stimulate pastors both to provide education themselves and to encourage Christian parents to do so. But they should also urge us to do something about the pornography industry.

In Cambodia, the Prime Minister has expressed concern about the growth of pornography, and the Evangelical Fellowship of Cambodia is planning a march against pornography later this year. They are also conducting Ruth and Boaz seminars for church youth on sexual awareness and appropriateness in relationships.

One problem with sexual exploitation here is that Cambodians sometimes blame either the UN soldiers in 1993 or today's tourists for the current level of sexual abuse and exploitation. But the fact is that it is happening in average "normal" Cambodian villages. It is probably also happening in Christian churches. It is easy to point the finger at others, but arguably more profitable to first remove the planks from our own eyes.

On an individual level we all need to take responsibility to protect ourselves and others. Internet screening is possible with software and programs that can be downloaded from the internet, e.g. surfonthesafeside.com. We can choose where we go and what we read. We can educate our children about sex before someone else does it for us. We can be role models in our relationships with our spouses and the way that we develop and maintain relationships with the opposite sex. We can lobby against child pornography through organizations such as Childnet (nigel@childnet-int.org). In short, we can choose life.

សំណុំនីកឃ្មុំ ៣/២ (មេសា ២០០២)៖ ១៣៩-១៤៧



# ការជ្រើសរើសយកជីវិតជាកិច្ចប្រឈមមុខធល់នឹងរូបអាសអាភាស

*លោក គ្លេន ម៉ែល*

រឿងអាសអាភាសជាបញ្ហាមួយក្នុងបញ្ហាជាច្រើនដែលបង្កការលំបាកដល់គ្រីស្តបរិស័ទនៅបណ្តាប្រទេសនានាប៉ែកខាងបស្ចិមប្រទេសដែលធ្វើឲ្យមានការមិនសប្បាយចិត្តពីការមើលរឿងអាសអាភាសនោះ ។ គឺវាប្រហាក់ប្រហែលគ្នាទៅនឹងការផឹកស្រាដែរ ។ ទោះបីជាយ៉ាងណាក៏ដោយចំពោះអ្នកមិនជក់បារីដែលនិយាយទៅកាន់អ្នកជក់ថា ខ្ញុំមិនចេះជក់ទេ សូមទៅជក់នៅកន្លែងផ្សេងទៅ នោះគេរាប់ថាជាការគួរសមដែលនិយាយបែបនោះទៅអ្នកជក់បារី តែបើមនុស្សណាម្នាក់និយាយថា ខ្ញុំមិនចេះផឹកស្រាទេ នោះគេរាប់មនុស្សនោះទុកថាជាមនុស្សព្រួយជ្រុលពេក ។ ការនេះស្រដៀងគ្នាទៅនិងការមើលរឿងអាសអាភាសដែរ បើសិនលោកអ្នកនិយាយអ្វីមួយដែលប្រឆាំងទាស់នឹងរូបអាសអាភាសនោះ គេអាចគិតថាអ្នកនោះប្រហែលជាបរិសុទ្ធពេក ។ នៅក្នុងសម័យចុងក្រោយនេះនៅសហរដ្ឋអាមេរិកនិងនៅអឺរ៉ុប ទស្សនាវដ្តីរបស់ស្ត្រីបានជំរុញលើកចិត្តស្ត្រីឲ្យស៊ាំនឹងហេតុការណ៍ដែលសង្សាររបស់គេបានមើលរូបអាសអាភាស ហើយបានលើក

ទឹកចិត្តដល់ស្ត្រីកុំឲ្យប្រកាន់ខឹងនឹងការបព្រឹត្តិរបស់សង្សាររបស់គេធ្វើអ្វី ។ ការមើលរូបភាពនៅក្នុង "ទស្សនាវដ្ដីបង្ហាញសាច់ស្រស់" របស់ស្ត្រីនោះ គឺគេរាប់ថាជារឿងធម្មតាក្នុងផ្នែកមួយនៃការចំរើនលូតលាស់របស់មនុស្ស ។ "កើតមកជាប្រុសត្រូវមានលក្ខណៈជាប្រុស" ។ ដូច្នេះឪពុកទាំងឡាយមានការអល់ឯកក្នុងការស្ដីប្រដៅដល់កូនរបស់ខ្លួនស្ដីពីគ្រោះថ្នាក់នៃការមើលរូបអាសអាភាសនោះ សូម្បីតែគេបានដឹងថាមានការទាក់ទាញទឹកចិត្ត និងធ្វើឲ្យមានការឈឺចាប់ដោយព្រោះការមើលរូបភាពទាំងនោះក៏ដោយចុះ ក៏គេមិនបានស្ដីប្រដៅដល់កូនដែរ ។

ការលក់ខ្លួន គឺនៅជាប់ជាប្រចាំនៅទីនេះទៅហើយ ។ *អ៊ីមធីវី* សាយភាយដោយសារប្រពន្ធផ្កាយរណប និងទូរទស្សន៍ខ្សែកាប ក៏សាយភាយគ្រប់ទីកន្លែងទាំងអស់នៅក្នុងលោកយើងនេះ មិនគ្រាន់តែជាវប្បធម៌នៃតន្ត្រី និងការបង្ហាញម៉ូតទូទាំងសកលលោកប៉ុណ្ណោះទេ ប៉ុន្តែវាក្លាយជាទម្លាប់ធម្មតាមួយដែលសេចក្ដីត្រូវការផ្នែកភេទក្លាយទៅជាពាណិជ្ជកម្មមួយបែបដែលអាចទាមទារយកបាន ។

នៅក្នុងទំនៀមទម្លាប់វប្បធម៌ដែលឲ្យតម្លៃលើភេទ គឺជាការមួយដែលគួររក្សាទុកជាការសម្ងាត់ ហើយនៅក្នុងបណ្ដាលប្រទេសដែលកាន់សាសនាអ៊ីស្លាមជាច្រើន ការមិនបង្ហាញខ្លួនឲ្យគេឃើញនោះរាប់ទុកជាការដ៏ពិសិដ្ឋបំផុត ហេតុដូច្នេះហើយបានជារូបកាយរបស់ស្ត្រីទាំងមូលត្រូវតែគ្របបិទបាំងយ៉ាងជិតដោយប្រើស្បៃរុំមុខទុកតែប្រឡង់ភ្នែកតែប៉ុណ្ណោះ ។ ប្រព័ន្ធផ្សព្វផ្សាយរបស់ពួកលោកខាងលិចចម្លែកនៅក្នុងចិត្តយ៉ាងខ្លាំង ប៉ុន្តែគេគាំទ្រប្រព័ន្ធនោះជាសាធារណៈថា ការនោះបានផ្ដល់កិត្តិយសដល់ស្ត្រី និងផ្ដល់កិច្ចការពារដល់ពួកគេបានមួយបែបដែរ ។

នៅក្នុងប្រទេសមួយដូចជាប្រទេសកម្ពុជា មានការពិបាកណាស់ដើម្បីធ្វើការប៉ាន់ប្រមាណមើលឲ្យបានដឹងពិតប្រាកដពីផលប៉ះពាល់នៃរូប

អាសអាភាសទៅលើទំនៀមទម្លាប់នោះ ប៉ុន្តែវាអាចជាហេតុផលមួយដែលប្រាប់ឲ្យយើងដឹងថា ហេតុអ្វីបានមានការចាប់រំលោភ និងការជួញដូរផ្លូវភេទកើតឡើងផុលផុសខ្លាំងម្ល៉េះ ។ នៅពេលដែលខ្ញុំបានមកលេងប្រទេសនេះដំបូងកាលពីឆ្នាំ ១៩៩០ គ្មានឃើញមានផ្ទាំងរូបភាពធំៗតាំងនៅតាមផ្លូវ ហើយក៏គ្មានការឃោសនាពីការងារផ្នែកនយោបាយឡើយ ។ ប៉ុន្តែឥឡូវនេះមានផ្ទាំងរូបភាពធំៗផ្សព្វផ្សាយពាណិជ្ជកម្មគ្រប់ទីកន្លែងទាំងអស់ ហើយមានទាំងការផ្សព្វផ្សាយលក់បារី ស្រា សន្យាផ្តល់រង្វាន់ ឃោសនាផ្នែកសុខភាព និងថែមទាំងឃោសនាផ្នែកភេទផង ។ គួរឲ្យសោកស្តាយណាស់ការឃោសនាទាំងនោះហុចលទ្ធផលផ្ទុយទៅវិញទេចំពោះអ្នកក្រ ព្រោះគេខំចំណាយធនធានអស់ពីខ្លួនព្រោះតែចង់ដេញតាមសំណាងទាំងឡាយដែលមាននៅក្នុងការឃោសនានោះ ។ លើសពីនោះទៅទៀត រូបភាពដ៏ស្រស់ស្អាតដែលគេបានផ្សព្វផ្សាយឃោសនានោះ សូម្បីតែយើងមានសុខភាពល្អមាំមួនទៅហើយនោះ ក៏មានអារម្មណ៍ច្រណែនហើយប្រាថ្នាចង់បានរូបរាងដូចរូបដែលគេឃោសនានោះដែរ ។ ចុះទម្រាំបើអ្នកដែលមានភាពពិការវិញ តើតូចចិត្តនឹងខ្លួនឯងប៉ុណ្ណាទៅ? រឿង ឬរូបភាពអាសអាភាសនោះមិនគ្រាន់តែកេងប្រវ័ញ្ចមនុស្សដែលគេយកទៅថតរូបនោះទេ តែមនុស្សដែលអង្គុយមើលរូបនោះក៏ត្រូវគេកេងប្រវ័ញ្ចដែរ ។

នៅក្នុងផ្សារនានាក្នុងទីក្រុងភ្នំពេញ កាសែតវីដេអូរឿងអាសអាភាសដែលលួចចម្លងលក់នោះ មានតម្លៃតែ២ដុល្លារសហរដ្ឋអាមេរិកតែប៉ុណ្ណោះ ។ រូបភាពនោះមិនគ្រាន់តែជារូបភាពអាសអាភាសតិចតួចប៉ុណ្ណោះទេ តែវាបង្ហាញពីរបៀបរួមភេទគ្រប់បែបស្ទើរតែមិនអាចជឿបានដែលគ្រីស្តបរិស័ទភាគច្រើនបានដឹងការទាំងអស់បានតាមតែរយៈការបកស្រាយពីព្រះគម្ពីរប៉ុណ្ណោះ ។ អ្នកលក់រូបអាសអាភាសទាំងនោះអាចលក់បានតិច ឬច្រើនគឺវាអាស្រ័យលើអាជ្ញាធរដែលត្រួតត្រាមើលដោយរិតត្បិតចំពោះការនោះ

ប៉ុន្តែមនុស្សគ្រប់រូបដឹងថា អ្វីក៏ដោយគឺត្រូវតែមានច្រកចេញទៅបានដោយសារលុយដែលគេប្រើដើម្បីសូកប៉ាន់នោះ ។ អ្នកទេសចរណ៍ទាំងឡាយគឺជាម៉ូយសំខាន់ចំពោះរឿងនេះ ប៉ុន្តែគេសង្កេតឃើញយុវជនកាន់តែច្រើនឡើងៗបាននាំគ្នាមករើជជុះរកមើលកាសែតវីដេអូ និងវីស៊ីឌីទាំងឡាយណាដែលប្រអប់ខាងក្រៅបង្ហាញយ៉ាងច្បាស់អំពីរឿងអាសអាភាសនោះ ។

គឺមានការពិបាកណាស់ដើម្បីបង្ហាញថា ការមើលរូបអាសអាភាសនោះបណ្តាលឲ្យមានការចាប់រំលោភ និងការកេងប្រវ័ញ្ចផ្នែកភេទ ប៉ុន្តែបទគម្ពីរបានបង្ហាញថា ការនោះនាំឲ្យអ្នកមើលធ្លាក់ក្នុងចម្រេះភ្នំដ៏រអិលខ្លាំងមួយដែលមិនអាចឡើងរួចបានឡើយ ។ គម្ពីរសុភាសិតពណ៌នាអំពីច្រកទ្វារជាច្រើន ។ មានច្រកផ្លូវមួយនាំទៅរកកន្លែងស្រីពេស្យា ជាកន្លែងដែលនាងអង្គុយហៅអស់អ្នកដែលដើរកាត់តាមទីនោះដោយសន្យាថានឹងបានទទួលនូវការសប្បាយជាទីសម្ងាត់ ប៉ុន្តែភ្ញៀវដែលបានចូលតាមច្រកទ្វារនោះរាប់ទុកថាជាពួកអ្នក "ស្លាប់" និងសុទ្ធតែនៅក្នុងទីជម្រៅនៃស្ថានឃុំព្រលឹងមនុស្សស្លាប់ទេ" [១] ។

ចំពោះអស់អ្នកដែលព្រមស្តាប់ព្រះអម្ចាស់ មានច្រកទ្វារផ្សេងអាចជ្រើសរើសយកបាន[២] ។ អស់អ្នកដែលសម្លឹងមើលទ្វារនេះរាល់ថ្ងៃអាចនឹងស្វែងរកបាននូវប្រាជ្ញា និង "អ្នកណាដែលរកខ្ញុំឃើញ នោះនឹងរកបានជីវិត" ។ មានទ្វារមួយដែលនាំទៅរកជីវិត និងទ្វារមួយទៀតនាំទៅរកសេចក្តីស្លាប់ ។ អត្ថបទនេះបន្តទៀតថា អ្នកណាដែលជ្រើសរើសទ្វារខុស នោះគឺ "អស់អ្នកដែលរកខ្ញុំមិនឃើញ អ្នកនោះធ្វើបាបខ្លួនឯង ហើយអស់អ្នកណាដែលស្អប់ខ្ញុំ អ្នកនោះស្រឡាញ់សេចក្តីស្លាប់វិញ" ។ ការមើលរូបអាសអាភាសនាំទៅរកសេចក្តីស្លាប់ ។

---

[១] *សុភាសិត ៩:១៣-១៨*

[២] *សុភាសិត ៨:៣២-៣៦*

គ្រីស្ទបរិស័ទអាចនិយាយអះអាងថា ការមើលរូបអាសអាភាសនោះគឺវាគ្រាន់បើជាងការប្រព្រឹត្តិអំពើផិតក្បត់ ព្រោះមានតែអំពើផិតក្បត់ទេដែលអាចមានឥទ្ធិពលលើជីវិតគ្រីស្ទបរិស័ទបាន ប៉ុន្តែចំពោះអស់អ្នកដែលចាប់ផ្តើមបន្តិចម្តងៗដោយគ្មានបំណងនឹងមើលសោះ ក៏ចាប់ផ្តើមញៀនចំពោះការមើលរូបអាសអាភាសនឹងប្រាប់លោកអ្នកឲ្យដឹងថា តើការមើលរូបភាពអាសអាភាសវាបំផ្លាញជីវិតអាពាហ៍ពិពាហ៍ និងទំនាក់ទំនងដទៃទៀតរបស់គេខ្លាំងប៉ុណ្ណានោះ ។ ខ្ញុំសូមផ្តល់នូវយោបល់ណែនាំថា បណ្ឌាបេសកជន និងបុគ្គលិកបំរើការងារគ្រីស្ទបរិស័ទ គឺជាជនងាយរងគ្រោះចំពោះការយល់ច្រឡំបែបនេះ ហើយប្រើពាក្យដោះសាថា ចង់បានពត៌មានបន្ថែមពីប្រព័ន្ធអ៊ិនធើណិតក៏ឆ្លៀតឱកាសទៅមើលពិភពអាថ៌កំបាំងនៃរូបអាសអាភាសនៅក្នុងប្រព័ន្ធអ៊ិនធើណិតនោះទៅវិញ ។

ដូច្នេះតើការមើលរូបអាសអាភាសនោះ មានឥទ្ធិពលប៉ះពាល់យ៉ាងណាចំពោះសង្គម? ទោះបីមានការពិបាកក្នុងការបង្ហាញពីផលប៉ះពាល់យ៉ាងណាក៏ដោយ ខ្ញុំសូមបង្ហាញពីលទ្ធផលដូចខាងក្រោមដែលមនុស្សជាច្រើនចង់ដកពិសោធន៍នូវរបៀបរួមភេទ ដែលគេបានឃើញតាមរឿងអាសអាភាសនោះគឺ៖

- មានការកើនឡើងនៃការចាប់រំលោភ និងការចាប់បង្ខំយ៉ាងកំរោលទាំងនៅក្នុងផ្ទះ និងនៅក្រៅផ្ទះ ។
- មានការកើនឡើងចំពោះការទៅរកស្រីបន ។
- មានការកើនឡើងចំពោះការឆ្លងជម្ងឺអេដស៍ ។

នៅពេលសន្និសីទរបស់យុវជនប្រិយសម្ព័ន្ធគ្រីស្ទបរិស័ទកម្ពុជាឆ្នាំ ២០០១ អ្នកចូលរួមចំនួនមួយរយសែសិបប្រាំនាក់ បានបំពេញលើក្រដាសស្ទង់មតិស្តីពីការមើលរូបអាសអាភាស អ្នកឆ្លើយនីមួយៗមិនចាំបាច់ឆ្លើយគ្រប់សំណួរទាំងអស់ក៏បាន ។ មានយុវជនមួយរយមួយនាក់ និងយុវនារីសែសិប

បួននាក់ ដែលបានចូលរួមឆ្លើយនូវសំណួរទាំងអស់នោះ គឺមានសែសិបបួននាក់ អាយុ ១៨ឆ្នាំ ឬក៏ក្រោម១៨ មានហាសិបបីនាក់ អាយុពី ១៩-២១ឆ្នាំ ហើយសាមសិបប្រាំមួយនាក់ អាយុ២២ឆ្នាំ ។ មានដប់ពីរនាក់ មិនបានប្រាប់ពីអាយុរបស់ខ្លួនឡើយ ។

ការស្ទង់មតិបានធ្វើដោយសម្ងាត់បំផុត គឺនៅពេលដែលគេបំពេញរួចហើយ ក្រដាសស្ទង់មតិនោះត្រូវយកទៅទម្លាក់ដាក់ក្នុងប្រអប់មួយ ។ យើងបានប្រកាសដល់ក្រុមអ្នកបំពេញលើក្រដាសស្ទង់មតិឲ្យដឹងថា លទ្ធផលសរុបនឹងត្រូវជូនទៅគ្រូគង្វាល និងអ្នកដទៃទៀតដែលធ្វើការងារទាក់ទងនឹងការហ្វឹកហ្វឺនផ្នែកភេទបន្ទាប់ពីការស្ទង់មតិនេះបានទទួលនូវការវិនិច្ឆ័យយ៉ាងល្អិតល្អន់រួចមក ។

លទ្ធផលមួយដែលគួរឲ្យចាប់អារម្មណ៍ជាងគេនៅក្នុងការស្ទង់មតិនេះ គឺទាក់ទងទៅនឹងរឿងអាសអាភាស ។ ចំនួនយុវជនដែលបានមើលរូបអាសអាភាសកើនឡើង យោងតាមអាយុរបស់គេគឺមានន័យថា មាន២៧% អាយុក្រោម១៨ឆ្នាំ មាន៣៨% អាយុចាប់ពី ១៩-២១ឆ្នាំ មាន៤៧% អាយុ២២ឆ្នាំឡើងទៅ ។ តែទោះជាយ៉ាងណាក៏ដោយ នៅក្នុងចំណោមយុវនារីយើងឃើញថាមានការខុសប្លែក ប៉ុន្តែគួរឲ្យកត់សំគាល់យ៉ាងខ្លាំង គឺមាន ២៩.៥% អាយុក្រោម១៨ឆ្នាំ ធ្លាប់អានរឿងអាសអាភាស ប្រៀបទៅ៦% មានអាយុពី១៩-២១ឆ្នាំ ហើយ៣% អាយុពី ២២ឆ្នាំឡើងទៅ ។ ការនេះអាចបង្ហាញថា យុទ្ធនាការនៃការផ្សព្វផ្សាយពាណិជ្ជកម្ម និងការដាក់តម្លៃរឿងទាំងនោះឲ្យទាបដើម្បីដៅចំពោះយុវនារីនោះ អាចបង្ហាញថានឹងទទួលបានជោគជ័យ ។

នេះគឺជាលទ្ធផលបន្ថែមរបស់ការស្ទង់មតិនោះគឺ៖

| | យុវជន | យុវនារី |
|---|---|---|
| ធ្លាប់មើលវីដេអូរឿងអាសអាភាស | ៣៣% | ៣.៥% |
| ធ្លាប់មើលវីដេអូរឿងអាសអាភាសតាមអ៊ិនធើណិត | ២% | ០% |
| ធ្លាប់ចូលរៀនសិក្ខាសាលាអប់រំផ្លូវភេទ | ២៨% | ១៨.៥% |
| ប្រភពដែលបានទទួលការអប់រំផ្លូវភេទ | | |
| ពីឪពុកម្តាយ | ៣៨% | ១២% |
| សាច់ញាតិបងប្អូន | ១៩% | ៥.៥% |
| គ្រូបង្រៀន | ៥០% | ១៧.២% |
| មិត្តភក្តិ | ២៨% | ២% |
| គ្រូគង្វាល | ៤៣% | ១៩% |
| ទស្សនាវដ្តី | ១៧% | ៣.៥% |
| វីដេអូ | ១៨.៥% | ២% |
| ស្គាល់អ្នកដទៃដែលមានអាយុស្របាលៗគ្នាដែលបានរួម-ភេទមុនរៀបការ | ៣៥% | ១៣% |
| ធ្លាប់រួមភេទមុនរៀបការ មុនក្លាយជាគ្រីស្ទបរិស័ទ | ១៦% | ២% |
| ធ្លាប់រួមភេទមុនរៀបការ តាំងពីក្លាយជាគ្រីស្ទបរិស័ទ | ៤% | ១.៥% |

តាមការប្រៀបធៀបតាមចំនួនតួលេខនៅជួរចុងក្រោយ ហាក់បីដូចជាបង្ហាញថា យុវជនមានការប្រែប្រួលចំពោះការប្រព្រឹត្តិរបស់គេដោយសារតែជំនឿគ្រីស្ទបរិស័ទរបស់ខ្លួន ។ តែទោះជាយ៉ាងណាក៏ដោយ គួរឲ្យកត់សំគាល់ដែរថា យុវជនមួយចំនួនដែលបានបដិសេធមិនព្រមឆ្លើយនូវសំណួរចុងក្រោយ គឺមាន ២២% ប្រៀបទៅនឹង ៧.៣% ចំពោះសំណួរមុនសំណួរចុងក្រោយ ។

ការនេះគួរតែធ្វើសំណួរអំពីការស្ទង់មតិបែបនេះទៀតនៅពេលធ្វើសន្និសីទនាពេលអនាគត ដើម្បីប្រៀបធៀបនូវលទ្ធផលដែលទទួលបាន

និងកត់សំគាល់មើលពីសន្ទុះឈានទៅរកការអ្វីមួយដែលយើងត្រូវតែដឹង ។ ពត៌មានដែលយើងទទួលបានទាំងនោះអាចយកទៅប្រើសំរាប់បង្កើតកម្មវិធីសិក្សាដោយស្ទង់ការយុវជនប្រិយសម្ព័ន្ធគ្រីស្តបរិស័ទកម្ពុជា និងអង្គការបំរើជនក្រីក្រ ដែលទាំងពីរគឺសុទ្ធតែជាដៃគូជាមួយអង្គការ *ធាហ្វាន់* ដូចគ្នា ។

លទ្ធផលដែលយើងទទួលបាននោះអាចពញ្ញាក់ស្មារតីដល់គ្រូគង្វាលទាំងឡាយ ដើម្បីផ្តល់នូវការអប់រំដោយខ្លួនឯងផ្ទាល់ និងជំរុញឲ្យឪពុកម្តាយគ្រីស្តបរិស័ទធ្វើការអប់រំដល់កូនចៅរបស់គេដែរចំពោះបញ្ហានេះ ។ ប៉ុន្តែការប្រមូលពត៌មានទាំងនោះនឹងជំរុញឲ្យយើងធ្វើអ្វីមួយចំពោះបញ្ហាឧស្សាហកម្មផ្លែករឿងអាសអាភាស ។

នៅក្នុងប្រទេសកម្ពុជា នាយករដ្ឋមន្ត្រីសម្តែងនូវការខ្វាយខ្វល់ចំពោះការកើតឡើងផុលផុសនូវរូបអាសអាភាស ហើយប្រិយសម្ព័ន្ធគ្រីស្តបរិស័ទកម្ពុជានឹងរៀបចំក្បួនដង្ហែមួយដើម្បីប្រឆាំងនឹងរូបភាពអាសអាភាសនៅចុងឆ្នាំនេះ ។ គេក៏បានរៀបចំសិក្ខាសាលា នាងរស់ និងបូអូស ដើម្បីអប់រំផ្នែកភេទ និងអប់រំផ្នែកទំនាក់ទំនងដ៏សមរម្យដល់យុវជន និងយុវនារី ។

បញ្ហាមួយនៅក្នុងចំណោមបញ្ហាទាំងអស់នៃការកេងប្រវ័ញ្ចផ្នែកភេទ គឺថាជនជាតិខ្មែរ ជួនកាលបន្ទោសដល់ពួកទាហានអង្គការសហប្រជាជាតិកាលពីឆ្នាំ ១៩៩៣ ឬដល់ពួកទេសចរណ៍នាពេលបច្ចុប្បន្ននេះ ចំពោះការកើតឡើងនូវការចាប់រំលោភ និងការកេងប្រវ័ញ្ចផ្លូវភេទនេះឯង ។ ប៉ុន្តែហេតុការណ៍នោះគឺថា រឿងរ៉ាវវាកំពុងតែកើតឡើងជាមធ្យម នៅក្នុងចំណោមមនុស្សសាមញ្ញធម្មតាដែលរស់នៅតាមភូមិនានានៃប្រទេសកម្ពុជា ។ រឿងនេះប្រហែលជាអាចកំពុងកើតឡើងតាមបណ្តាក្រុមជំនុំគ្រីស្តបរិស័ទដែរ ។ វាជាការងាយណាស់ដែលយើងចង្អុលដាក់អ្នកដទៃ ប៉ុន្តែការដែលប្រសើរនោះគឺយើងត្រូវដកយកធ្នឹមចេញពីភ្នែករបស់យើងជាមុនសិន ។

យើងម្នាក់ៗត្រូវទទួលខុសត្រូវចំពោះការការពារខ្លួនយើងផ្ទាល់ និងការការពារដល់អ្នកដទៃ ។ ដើម្បីច្រោះប្រព័ន្ធ អ៊ិនធើណិត យើងអាចប្រើកម្មវិធី និង សហ្វវែរ (Software) មួយបែបយកមកបញ្ចូលនៅក្នុងប្រព័ន្ធអ៊ិនធើណិតរបស់យើង ឧទាហរណ៍ដូចជា surfonthesafeside.com. ។ យើងអាចជ្រើសរើសកន្លែងដែលយើងត្រូវទៅ និងអ្វីដែលយើងត្រូវអាន ។ យើងអាចអប់រំកូនរបស់យើងអំពីរឿងភេទឲ្យបានមុនពេលអ្នកផ្សេងទៀតមកអប់រំជំនួសយើង ។ យើងអាចធ្វើជាគំរូនៅក្នុងទំនាក់ទំនងជាប្ដីនិងប្រពន្ធរបស់យើង ហើយបង្ហាញពីរបៀបដែលយើងអាចបង្កើតទំនាក់ទំនង និងរក្សានូវទំនាក់ទំនងនោះជាមួយនឹងអ្នកដែលមានភេទផ្ទុយពីយើង ។ យើងអាចរៀបចំការប្រឆាំងទំនាស់ជាមួយនឹងការធ្វើពាណិជ្ជកម្មរឿងអាសអាភាសចំពោះកុមារតាមរយៈអង្គការនានាដូចជា អង្គការ Childnet (nigel@childnet-int.org) ។ និយាយឲ្យខ្លីគឺ យើងអាចជ្រើសយកជីវិត មិនជ្រើសយកសេចក្ដីស្លាប់ទេ ។